ឆ្នាំទី១ លេខ១០០៤ ចេញផ្សាយប្រចាំខែធ្នូ ឆ្នាំ២០១១

# ព្រឹត្តិបត្រការងារ

# Labour Bulletin

ជាស្ពានឆ្ពោះទៅកាន់ ♦ឱកាសការងារ ♦កម្លាំងពលកម្ម ♦ព័ត៌មានទីផ្សារការងារ ⌖ Gateway to ♦Jobs ♦Labour Forces ♦Labour Market Information



រៀបចំ និងបោះពុម្ពផ្សាយដោយ ទីភ្នាក់ងារជាតិមុខរបរ និងការងារ នៃគណៈកម្មាធិការជាតិបណ្តុះបណ្តាល

- ជំនាញនៃភាពទទួលបានការងារ
- ទិន្នន័យសិស្សមធ្យមសិក្សាទុតិយភូមិ និងឧត្តមសិក្សា
- កិច្ចសន្យាការងារ
- ទស្សនៈពីជ្រុងមួយនៃការសិក្សាជំនាញបច្ចេកទេស
- ការរៀបចំខ្លួនសម្រាប់ចូលសម្ភាសន៍ការងារ
- ការជ្រើសរើសអាជីពដែលសមស្រប

# មាតិកា

## ព្រឹត្តិបត្រការងារ

### ទីភ្នាក់ងារជាតិមុខរបរ និងការងារ

ទំព័រ


◈ សកម្មភាពថ្មីៗពាក់ព័ន្ធនឹងវិស័យការងារ និងការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ៣

◈ មគ្គុទេសក៍អាជីព ៦

➢ ជំនាញនៃភាពទទួលបានការងារ (Employability skills) ៦

➢ ការពិនិត្យ និងជ្រើសរើសអាជីពដែលសមស្រប ៩

➢ ការរៀបចំមូលដ្ឋានគ្រឹះក្នុងការស្វែងរកការងារធ្វើ ២១

➢ ការរៀបចំខ្លួនសម្រាប់ចូលសម្ភាសន៍ការងារ ២៥

◈ លិខិតបទដ្ឋានគតិយុត្តការងារ ២៩

➢ កិច្ចសន្យាការងារ ២៩

◈ ព័ត៌មានទីផ្សារការងារនៅកម្ពុជា ៣១

➢ ទិន្នន័យសង្ខេបសំខាន់ៗស្តីពីចំនួនសិស្សដែលបានប្រលងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ និងនិស្សិតដែលបានសិក្សានៅគ្រឹះស្ថានឧត្តមសិក្សា ៣១

◈ ព័ត៌មានជ្រើសរើសបុគ្គលិក ៣៧

◈ បទពិសោធន៍ក្នុងការស្វែងរកការងារធ្វើ ៤៣

◈ ទស្សនៈពីជ្រុងមួយនៃការសិក្សាជំនាញផ្នែកបច្ចេកទេស ៤៥



ព្រឹត្តិបត្រការងារ លេខ១


ព្រឹត្តិបត្រការងារ លេខ២


ព្រឹត្តិបត្រការងារ លេខ៣


ព្រឹត្តិបត្រការងារ លេខ៤


ព្រឹត្តិបត្រការងារ

**គណៈគ្រប់គ្រង**

ឯកឧត្តម ពេជ សោភ័ន

ឯកឧត្តម ប៉ុក ប៉ាន់

ឯកឧត្តម ឡៅ ហ៊ីម

ឯកឧត្តម ហេង សួរ

**នាយកគ្រប់គ្រងទូទៅ**

ឯកឧត្តម ហុង ជឿន

**និពន្ធនាយក**

លោក សាម៉េន សុខា

**និពន្ធនាយករង**

លោក ហៃ ហ៊ុនឡេង

លោក សួង សង្ហារុទ្ធី

លោក ទូច សុផាត

**អ្នកនិពន្ធ**

លោក សុកខុន ដាវីដ

លោក តាំង ហ៊ាងថារិទ្ធ

លោកស្រី លី វួចចេង

លោក ជឹម សុជាតិ

លោក ហួត សុគន្ធា

លោក ខាន់ ចិន្តា

លោក តាំង ផេងរិទ្ធី

លោក សុជាតិ កញ្ញារិទ្ធ

មន្ត្រីទីភ្នាក់ងារជាតិមុខរបរ និងការងារ

នាយកគ្រប់គ្រងការផ្សាយ

លោក ខេង សុគន្ធា

នាយកគ្រប់គ្រងការបោះពុម្ព

លោក គឹម កែវស្មី

នាយកគ្រប់គ្រងផ្នែករូបភាព និងកុំព្យូទ័រ

លោក ផូរ ឧស្សាហ៍រចនា

អ្នករចនាអត្ថបទ

កញ្ញា ឈា បញ្ញារី

អ្នកកែសម្រួលអក្ខរាវិរុទ្ធ

មន្ត្រី ទីភ្នាក់ងារជាតិមុខរបរ និងការងារ

# សួស្តីឆ្នាំថ្មី ឆ្នាំ២០១២

**សូមគោរពប្រសិទ្ធពរជ័យ បវរសួស្តី សិរីមង្គល វិបុលសុខ មហាប្រសើរ**

**ជូនចំពោះ**



**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**សម្តេចពញាចក្រី ហេង សំរិន**

ដែលជាអគ្គមគ្គុទ្ទេសក៏ និងប្រមុខដឹកនាំដ៏ឆ្នើមនៃព្រឹទ្ធសភា រាជរដ្ឋាភិបាល រដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

**ក្នុងឱកាសដ៏មហានក្ខត្តឫក្សនៃពិធីចូលឆ្នាំថ្មីឆ្នាំសកល ២០១២**

សូមបួងសួងដល់វត្ថុស័ក្តិសិទ្ធក្នុងលោកតាមជួយបីបាច់ថែរក្សាសម្តេចទាំងបីប្រកបដោយពលានុភាពខ្លាំងក្លា បញ្ញាញាណឈ្លាសវៃ

សុខភាពល្អបរិបូរណ៍ ជន្មាយុយឺនយូរ ដើម្បីដឹកនាំប្រទេស និងប្រជាពលរដ្ឋកម្ពុជាឆ្ពោះទៅកាន់ភាពសម្បូរណ៍រុងរឿង

ការអភិវឌ្ឍ សន្តិភាព សុភមង្គល និងសេចក្តីចម្រុងចម្រើនជានិច្ចនិរន្តរ៍ៗ

ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងដ៏ឈ្លាសវៃរបស់សម្តេចទាំងបី

បានធ្វើឱ្យប្រទេស និងប្រជាពលរដ្ឋកម្ពុជាទទួលបាននូវ

ការរីកចម្រើនសម្បូរណ៍សប្បាយ ជីវភាពធូរធារ សន្តិភាពពេញលេញ ព្រមទាំងមានមោទនភាពជាតិខ្ពស់ៗ

គោរពជូនពរដោយសេចក្តីស្មោះអស់ពីដួងចិត្តពី

ប្រធានទីភ្នាក់ងារជាតិមុខរបរ និងការងារ ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រោមឱវាទទាំងអស់

# សួស្តីឆ្នាំថ្មី ឆ្នាំ២០១២

## សូមគោរពប្រសិទ្ធពរជ័យ បវរសួស្តី សិរីមង្គល វិបុលសុខ មហាប្រសើរ
## ជូនចំពោះ



### ឯកឧត្តមបណ្ឌិតសភាចារ្យ សុខ អាន

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
និងជាប្រធានគណៈកម្មាធិការជាតិបណ្តុះបណ្តាល

**ក្នុងឱកាសដ៏មហានក្ខត្តឫក្សនៃពិធីចូលឆ្នាំថ្មីឆ្នាំសកល ២០១២**

សូមបួងសួងដល់វត្ថុស័ក្តិសិទ្ធក្នុងលោកជួយប្រសិទ្ធពរជ័យ សិរីមង្គល វិបុលសុខគ្រប់ប្រការជូនដល់
ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ អាន** ដែលជាកុលបុត្រខ្មែរដ៏មានប្រាជ្ញាឈ្លាសវៃមួយរូប បានចំណាយកម្លាំងកាយចិត្តក្នុង
ការចូលរួមចំណែកដឹកនាំ រាជរដ្ឋាភិបាល និងប្រទេសកម្ពុជាឆ្ពោះទៅកាន់ភាពរីកចម្រើនរុងរឿងថ្កុំថ្កើងៗ
សូមឯកឧត្តមបណ្ឌិតសភាចារ្យ និងលោកជំទាវ ព្រមទាំងក្រុមគ្រួសារពើបប្រទះតែពុទ្ធពរទាំងបួនប្រការគឺ
អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយៗ

គោរពជូនពរដោយសេចក្តីស្មោះអស់ពីដួងចិត្តពី
ប្រធានទីភ្នាក់ងារជាតិមុខរបរ និងការងារ ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រោមឱវាទទាំងអស់



# សកម្មភាពថ្មីៗពាក់ព័ន្ធនឹងវិស័យការងារ និងការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

## កិច្ចប្រជុំគណៈកម្មាធិការជាតិបណ្តុះបណ្តាលលើកទី ៧



**វិមានមិត្តភាពៈ** កាលពីថ្ងៃទី ២៣ ខែធ្នូ ឆ្នាំ២០១១ កន្លងទៅនេះ មាន **កិច្ចប្រជុំគណៈកម្មាធិការជាតិបណ្តុះបណ្តាលលើកទី ៧** ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្រ្តី រដ្ឋមន្រ្តីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្រ្តី និងជាប្រធានគណៈកម្មាធិការជាតិបណ្តុះបណ្តាល ដោយមានការចូលរួមពីក្រសួង ស្ថាប័ន តំណាងនិយោជក សហជីព អង្គការមិនមែនរដ្ឋាភិបាល ដែលជាសមាជិករបស់គណៈកម្មាធិការជាតិបណ្តុះបណ្តាល ព្រមទាំងតំណាងស្ថាប័ន និងភ្នាក់ងារពាក់ព័ន្ធជាច្រើនទៀត។ ថ្លែងក្នុងអង្គពិធីនោះ **ឯកឧត្តមបណ្ឌិតសភាចារ្យ** បានគូសបញ្ជាក់ និងសង្កត់ធ្ងន់ទៅលើការពង្រឹង និងការរៀបចំការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងជំនាញចាំបាច់ផ្សេងៗទៀត ដើម្បីតម្រូវទៅនឹងតម្រូវការនៃទីផ្សារការងារនាពេលបច្ចុប្បន្ន និងអនាគត។ ឆ្លៀតក្នុងឱកាសនោះ **ឯកឧត្តមបណ្ឌិតសភាចារ្យ** ក៏បានលើកទឹកចិត្តឱ្យទីភ្នាក់ងារជាតិមុខរបរ និងការងារបង្កើននូវមធ្យោបាយផ្សព្វផ្សាយអំពីសេវា និងសកម្មភាពរបស់ខ្លួនឱ្យកាន់តែបានច្រើន និងទូលំទូលាយជាងមុន ជាពិសេសតាមរយៈបណ្តាញទូរទស្សន៍នានា ដើម្បីធានាឱ្យបាននូវការបម្រើសេវា និងការជួយស្វែងរកការងារឱ្យបានបរិមាណច្រើន និងមានគុណភាពកាន់តែប្រសើរ។



## ការងារ និងវិជ្ជាជាទ្រព្យជាប់ប្រាណ

«ការអប់រំ និងការបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈគឺជាគន្លឹះដើម្បីបង្កើត ឬបង្កើនចំណូល និងរក្សាស្ថិរភាពការងារដែលជាលទ្ធផលគឺនឹងជួយសម្រាលបន្ទុកចំណាយ និងការគាំពារសង្គម។ »

ខ្លឹមសារខាងលើនេះគឺយោងដល់ប្រសាសន៍របស់ឯកឧត្តមបណ្ឌិត **ពេជ សោភ័ន** រដ្ឋលេខាធិការនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាអនុប្រធានគណៈកម្មាធិការជាតិបណ្តុះបណ្តាល ថ្លែងក្នុងឱកាសនៃ ***វេទិកាជាតិស្តីពីការផ្សព្វផ្សាយយុទ្ធសាស្រ្តជាតិគាំពារសង្គមសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះនៅកម្ពុជា*** ដែលបានប្រារព្ធឡើងនៅវិមានសន្តិភាព នាថ្ងៃទី ១៥-១៦ ខែធ្នូ ឆ្នាំ២០១១ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្រ្តីនៃព្រះរាជាណាចក្រកម្ពុជា។



ឯកឧត្តមរដ្ឋលេខាធិការបានមានប្រសាសន៍សង្កត់ធ្ងន់ថា *«ការអប់រំ និងបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ គឺជាគន្លឹះដ៏សំខាន់ និងមានប្រសិទ្ធភាពក្នុងការចូលរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ តាមរយៈការទទួលបានការងារសមរម្យ បង្កើនប្រាក់ចំណូល មានសុខុមាលភាពសង្គម និងភាពសប្បាយ រីករាយនៅក្នុងជីវភាពប្រចាំថ្ងៃ។»*



## ពិព័រណ៍ការងារថ្នាក់ជាតិឆ្នាំ ២០១១ បានបិទបញ្ចប់ប្រកបដោយជោគជ័យ



**វិទ្យាស្ថានជាតិអប់រំ:** ពិព័រណ៍ការងារថ្នាក់ជាតិឆ្នាំ ២០១១ រយៈពេល ២ថ្ងៃ បានប្រព្រឹត្តិទៅប្រកបដោយភាពអធិកអធមក្រោមការរៀបចំដោយ NEA សហការឧបត្ថម្ភដោយ ILO UNESCO និង UNDP។ ពិព័រណ៍នេះបានប្រកាសបើក និងកាត់ខ្សែបូសម្ពោធក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិត ពេជ សោភ័ន** រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាប្រធានគណៈកម្មាធិការជាតិ-បណ្តុះបណ្តាល (NTB) ដែលមានការចូលរួមពីគណៈអធិបតី ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ និយោជក ក្រុមហ៊ុន តំណាងភ្នាក់ងារផ្តល់ការអប់រំបណ្តុះបណ្តាល អ្នកស្វែងរកការងារធ្វើ ព្រមទាំងសិស្ស និស្សិត និងសាធារណជនទូទៅយ៉ាងច្រើនកុះករ។ ពិព័រណ៍នោះបានរៀបចំដោយផ្តោតលើគោលបំណង: ផ្តល់នូវឱកាសនៃការជួបគ្នារវាងនិយោជក អ្នកផ្តល់ការអប់រំបណ្តុះបណ្តាល និងអ្នកស្វែងរកការងារធ្វើ ដើម្បីឈានទៅដល់ការបំពេញការងារឱ្យគ្នាទៅវិញទៅមក។ ម្យ៉ាងទៀត គឺការផ្តល់នូវបទពិសោធន៍ការងារ និងមគ្គុទេសក៍អាជីពដល់សិស្ស និស្សិត និងអ្នកស្វែងរកការងារធ្វើ។

**លទ្ធផល:**

- ✦ អ្នកចូលរួមបើកពិធីសម្ពោធពិព័រណ៍មានចំនួន ៩៥០នាក់
- ✦ ស្ថាប័ន ក្រុមហ៊ុនចូលរួមក្នុងការតាំងបង្ហាញមានចំនួន ៣៥
- ✦ អ្នកចូលរួមស្តាប់ការធ្វើបទបង្ហាញពីសំណាក់វាគ្មិនកិត្តិយសមានចំនួន ១៧០០នាក់
- ✦ អ្នកស្វែងរកការងារធ្វើដែលបានចុះឈ្មោះនៅនឹងបញ្ជររបស់ NEA រួមមាន៖
    - ចុះឈ្មោះលើទម្រង់ក្រដាសមានចំនួន ២៣២នាក់
    - ទទួលបានប្រវត្តិរូបសង្ខេបមានចំនួន ១៣ច្បាប់
- ✦ ប្រមូលព័តមានជ្រើសរើសបុគ្គលិកពីបញ្ជរចំនួន ១៦ មានចំនួន ១០០ មុខតំណែង (៩៨៧កន្លែង)

## តើ NEA បានត្រៀមខ្លួនយ៉ាងណាសម្រាប់ឆ្លើយតបទៅនឹងតម្រូវការកម្លាំងពលកម្មពីនិយោជក និងវិនិយោគិនបរទេស




**សណ្ឋាគារ Inter-Continental:** កាលពីព្រឹកថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១១ មានការប្រារព្ធ **«សិក្ខាសាលាស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា-ជប៉ុន»** ដែលមានការចូលរួមពីសំណាក់ស្ថាប័នអភិវឌ្ឍនានារបស់រាជ រដ្ឋាភិបាល ព្រមទាំងវិនិយោគិនជប៉ុនមកពីក្រុមហ៊ុនជាច្រើនផងដែរ។

ជាវាគ្មិនដែលថ្លែងក្នុងបទបង្ហាញនៅក្នុងឱកាសនោះ **ឯកឧត្តម ហុង ជឿន** ប្រធានទីភ្នាក់ងារជាតិមុខរបរ និងការងារ បានជម្រាបជូនអង្គពិធី ជាពិសេសតំណាងវិនិយោគទុនជប៉ុនជាច្រើនរូបដែលមានបំណងមកវិនិយោគនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឱ្យបានជ្រាបថា បច្ចុប្បន្ន កម្ពុជាមិនមានបញ្ហាកង្វះខាតកម្លាំងពលកម្មសម្រាប់ផ្គត់ផ្គង់ឱ្យទីផ្សារការងារនោះទេ ប្រសិនយោងទៅដល់កត្តាប្រជាសាស្ត្រ និងអត្រាកំណើនដ៏ច្រើនរបស់យុវជនក្នុងវ័យបំពេញការងារ។ បន្ថែមលើនេះ **ឯកឧត្តមប្រធាន** ក៏បានផ្តល់នូវការលើកទឹកចិត្ត និងជំរុញឱ្យវិនិយោគិនជប៉ុនទាំងអស់ដែលមានបំណងមកដាក់ទុនវិយោគនៅកម្ពុជា មានទំនុកចិត្ត និងសាកល្បងប្រើប្រាស់សេវាការងារ និងព័ត៌មានទីផ្សារការងាររបស់ NEA ដែលជានិច្ចកាលនៅរង់ចាំបម្រើនិយោជក និងក្រុមហ៊ុនទាំងអស់ក្នុងការជួយស្វែងរក និងផ្តល់នូវតម្រូវការកម្លាំងពលកម្មដែលមាននៅក្នុងមូលដ្ឋានទិន្នន័យរបស់ខ្លួន។



## មជ្ឈមណ្ឌលការងារថ្មីមួយនឹងចាប់កំណើតនៅខេត្តស្វាយរៀង នៅចុងឆ្នាំ ២០១១ នេះ

យោងតាមសេចក្តីត្រូវការ ក៏ដូចជាស្របពេលដែលលំហូរនៃកម្លាំងពលកម្ម និងសកម្មភាពសេដ្ឋកិច្ចនៅប៉ែកខាងកើតនៃប្រទេសកំពុងតែមានសន្ទុះរីកចំរើន ព្រមទាំងមានការយកចិត្តទុកដាក់តាមរយៈគោលការណ៍ និងអនុសាសន៍ពីថ្នាក់ដឹកនាំនៃគណៈកម្មាធិការជាតិបណ្តុះបណ្តាល និងថ្នាក់ដឹកនាំនៃទីភ្នាក់ងារជាតិមុខរបរ និងការងារ មជ្ឈមណ្ឌលការងារថ្មីមួយនៅក្នុងខេត្តស្វាយរៀង ត្រូវបានសម្រេចបង្កើត និងដាក់ឱ្យដំណើរការ។ រួមបញ្ចូលទាំងមជ្ឈមណ្ឌលមួយនេះផង ទ.ជ.ម.ក នឹងមានមជ្ឈមណ្ឌលការងារសរុបចំនួន ៥ បន្ថែមលើមជ្ឈមណ្ឌលការងារចំនួន ៤ ផ្សេងទៀតដែលកំពុងដំណើរការនៅរាជធានីភ្នំពេញ បាត់ដំបង សៀមរាប និងកំពត។

បច្ចុប្បន្ន មជ្ឈមណ្ឌលការងារខេត្តស្វាយរៀងស្ថិតក្នុងតំណាក់កាលនៃការសិក្សារៀបចំ កែសម្រួលទីតាំង និងបំពាក់នូវគ្រឿងបរិក្ខាការិយាល័យដើម្បីឈានទៅដាក់ឱ្យសម្ពោធជាផ្លូវការក្នុងពេលដ៏ខ្លីខាងមុខ។

### មជ្ឈមណ្ឌលការងារខេត្តស្វាយរៀង

ស្ថិតនៅក្នុងបរិវេណមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តស្វាយរៀង
អាសយដ្ឋាន៖ ភូមិមេភ្លើង សង្កាត់ស្វាយរៀង ក្រុងស្វាយរៀង

ទូរស័ព្ទលេខ: ០៤៤-៩៤៩-២៧៥ ឬ ០១៦-៦៤៦-៦៥៥

អ៊ីម៉ែល: jc_svayrieng@nea.gov.kh




## ទ.ជ.ម.ក ចូលរួមក្នុងកិច្ចប្រជុំស្តីពីយុវជន និងសហគ្រិនភាព




ពិព័រណ៍ចល័តរបស់ NEA ដើម្បីផ្សព្វផ្សាយអំពីសេវាការងារ និងព័ត៌មានទីផ្សារការងារ ត្រូវបានរៀបចំឡើងក្នុងឱកាសនៃកិច្ចប្រជុំកំពូលស្តីពីយុវជន និងសហគ្រិនភាព "ការចាប់ផ្តើមអាជីវកម្ម" នៅមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជាជប៉ុន (CJCC) កាលពីថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១១ កន្លងទៅនេះ។

ក្នុងកិច្ចប្រជុំនោះ **ឯកឧត្តម ហុង ជឿន** ប្រធាន NEA បានធ្វើបទបង្ហាញអំពីសេវាការងាររបស់ NEA ជូនដល់អង្គពិធីដើម្បីស្វែងយល់ និងជ្រាបជាព័ត៌មានផងដែរ។ ជាលទ្ធផល នៃការធ្វើពិព័រណ៍ NEA បានចែកខិត្តប័ណ្ណផ្សព្វផ្សាយចំនួន **២៥០**សន្លឹក ទម្រង់អ្នកស្វែងរកការងារធ្វើចំនួន **៣០**ច្បាប់ ទម្រង់អ្នកផ្តល់ការងារចំនួន **០៦**ច្បាប់ ទម្រង់អ្នកផ្តល់ការអប់រំបណ្តុះបណ្តាលចំនួន **០៥**ច្បាប់ និងព្រឹត្តិបត្រការងារចំនួន **៧៧**ក្បាល៕






មគ្គទេសក៍អាជីព

# ជំនាញនៃភាពទទួលបានការងារ

## Employability Skills/Generic Skills

នៅក្នុងស្ថានភាពនៃការប្រកួតប្រជែងកម្លាំងពលកម្មក្នុងទីផ្សារការងារ និយោជក (ផ្នែកតម្រូវការកម្លាំងពលកម្ម) ហាក់លែងពោលដោយចំពោះ ឬរំពឹងទទួលបានភាពមានគុណវុឌ្ឍិគ្រប់គ្រាន់ (The right qualification) ឬការមានជំនាញបច្ចេកទេសតែមួយមុខដែលអាចនាំឱ្យបុគ្គលម្នាក់ (អ្នកស្វែងរកការងារធ្វើ) ទទួលបានការងារដ៏ស្ថិតស្ថេរទៀតហើយ។ ផ្ទុយទៅវិញ ប្រការដែលគេតែងលើកយកមកគិតពិចារណាបំផុតនោះ គឺប្រភេទនៃជំនាញបែបអន្តរបុគ្គល (Interpersonal skills) បានន័យថាជាជំនាញដែលអនុញ្ញាតឱ្យបុគ្គល ឬបុគ្គលិកម្នាក់ៗក្នុងក្រុមការងារអាចមានការប្រាស្រ័យទាក់ទងគ្នាដោយទូលំទូលាយដើម្បីឈានទៅទទួលបានជោគជ័យក្នុងការងារទាំងពួង។

តើមនុស្សម្នាក់អាចមានមធ្យោបាយទំនាក់ទំនងបែបណាទៅកាន់មនុស្សដទៃ នេះគឺជាអ្វីដែលទាក់ទាញការចាប់អារម្មណ៍របស់និយោជកជាដំបូងគេបង្អស់ចំពោះបេក្ខជន ឬបុគ្គលិកដែលអាចទទួលឱ្យចូលបម្រើការងារ។ ទោះបីជាយ៉ាងដូច្នេះក្តី និយោជកហាក់មានអារម្មណ៍ និងក្តីសង្ស័យថាបេក្ខជនមួយរូបៗទំនងជាមិនមានជំនាញ បែបទំនាក់ទំនងឱ្យពូកែមាំទាំសម្រាប់បំពេញការងារនោះឡើយ។

ប្រការនេះគឺស្របគ្នាទៅនឹងស្ថានភាពនៃសេដ្ឋកិច្ចនាពេលបច្ចុប្បន្ន នៅទីកន្លែងការងារ ឬទីផ្សារការងារក៏មានការវិវឌ្ឍ និងប្រែប្រួលឥតឈប់ឈរផងដែរ ហើយជាលទ្ធផលនៃដំណើរការបែបនេះ និយោជកតែងតែរំពឹងសម្លឹងរកបុគ្គលិកនិយោជិតណាដែលអាចមានភាពងាយបត់បែន និងភាពងាយសម្របខ្លួនទៅក្នុងការងារបន្ថែមពីលើជំនាញបច្ចេកទេស ពួកគេម្នាក់ៗមាន។ កន្លងមក នៅប្រទេស កម្ពុជានៅក្នុង



តទៅទំព័របន្ទាប់

*អត្ថបទនេះដកស្រង់ និងប្រែសម្រួលដោយ លោក* ***ហៃ ហ៊ុនឡេង***។ *ប្រសិនលោកអ្នកចង់ទទួលបានព័ត៌មានលម្អិតបន្ថែមអំពីអាជីព និងការងារសូមអញ្ជើញអាន និងស្រាវជ្រាវនូវឯកសារដ៏សម្បូរបែបនានាផ្សេងទៀតដែលមានតម្កល់ទុកនៅក្នុង* **«បណ្ណាល័យការងារ»** *របស់ទីភ្នាក់ងារជាតិមុខរបរ និងការងារ ។*

# ហេតុអ្វីជំនាញមូលដ្ឋានមានសារសំខាន់?

Why are generic skills important?

«បណ្តុំជំនាញមូលដ្ឋាន» មានសារសំខាន់ដោយហេតុថា បច្ចុប្បន្ននេះស្ទើរគ្រប់ការងារទាំងអស់តម្រូវឱ្យមានភាពងាយបត់បែន គំនិតផ្តួចផ្តើម ព្រមទាំងលទ្ធភាពនៃការអាចអនុវត្តកិច្ចការបានច្រើនដំពូកៗ បានន័យថារាល់កិច្ចការទាំងអស់ត្រូវពង្រីកវិសាលភាពរបស់ខ្លួនឱ្យបានទូលំទូលាយ និងមានសារប្រយោជន៍ដោយផ្តោតជាសំខាន់ទៅលើការបម្រើសេវា ការបង្កើតព័ត៌មាន និងបំប៉នជំនាញផ្នែកសង្គមឱ្យបានកាន់តែច្រើនៗ ប្រការម្យ៉ាងទៀត សព្វថ្ងៃនេះ និយោជកបានកំពុងផ្តោតទៅលើការសម្របខ្លួនទៅតាមការប្រែប្រួលក្នុងសង្គម និងសេដ្ឋកិច្ច ការកាត់បន្ថយចំណាយ ការបង្កើនផលិតភាពពលកម្ម និងស្វែងរកទីផ្សារថ្មីៗ ក៏ដូចជាការពង្រីងខាងកិច្ចបម្រើសេវាផងដែរ។ ចំពោះនិយោជិតវិញ ពួកគេត្រូវអនុវត្តនូវការងារឱ្យបានកាន់តែប្រសើរតាមរយៈការបង្កើតនូវបរិយាកាសការងារជាក្រុម ការដោះស្រាយបញ្ហា ព្រមទាំងព្យាយាមបំប៉នសមត្ថភាពរបស់ពួកគេឱ្យមានភាពសមស្របទៅតាមការវិវឌ្ឍនៃបរិបទការងារ ក៏ដូចជាបំពេញឱ្យបានជោគជ័យនូវការងារថ្មីៗដែលពុំធ្លាប់ជួបប្រទះពីមុនមកៗ បន្ថែមលើនេះ ពួកគេក៏គួរមានលទ្ធភាពក្នុង ការធ្វើសេចក្តីសម្រេចចិត្ត ការហ៊ានទទួលកិច្ចការ ឬមានទំនួលខុសត្រូវ ព្រមទាំងអាចធ្វើការទំនាក់ទំនងនៅក្នុងក្របខណ្ឌការងារ ជាមួយមជ្ឈដ្ឋានខាងក្រៅឱ្យមានប្រសិទ្ធភាពខ្ពស់។

បច្ចុប្បន្ន ដោយសារតែទីផ្សារការងារនៅកម្ពុជាកាន់តែមានភាពប្រកួតប្រជែង និងមានភាពសាំញ៉ាំក្នុងក្របខណ្ឌការងារក្នុងស្រុក និងការងារពីការវិនិយោគទុនបរទេស ដូច្នេះបែបបទនៃការបំពេញការងារបានប្រែមុខមាត់ទៅកាន់ភាពជឿនលឿនតាមបទដ្ឋានថ្មីផងដែរ។ មានន័យថា វិស័យការងារទាំងនិយោជក និងនិយោជិតហាក់បានផ្តោតសំខាន់តែលើជំនាញបច្ចេកទេស (Hard skills) និងបទពិសោធន៍ច្រើនក្នុងការងារ ដោយមើលរំលងចំណុច សំខាន់ៗនៃជំនាញបែបទំនាក់ទំនង (Communication skills/Soft skills)។ ប្រការបែបនេះហាក់បានដាក់បន្ទុកជាខ្លាំងទៅលើបេក្ខជន ឬអ្នកទើបស្វែងរកការងារធ្វើលើកដំបូង (First time jobseekers) ដោយហេតុថាពួកគេអាចមានជំនាញបច្ចេកទេស ប៉ុន្តែខ្វះបទពិសោធន៍ការងារ។ ករណីនៅប្រទេសជឿនលឿនមួយចំនួន ដូចជាប្រទេសជប៉ុនជាដើម ការស្វែងរកការងារ និងទទួលបានការងារលើកដំបូងត្រូវបានផ្តោតជាសំខាន់ទៅលើ Communication skills និង Soft skills បន្ថែមទៅលើជំនាញបច្ចេកទេស បានន័យថាការអប់រំ និងជំនាញដែលបានហ្វឹកហ្វឺននៅក្នុងគ្រឹះស្ថានអប់រំគឺគ្រាន់តែជាមធ្យោបាយមួយសំខាន់វាស់កម្រិតអប់រំតែប៉ុណ្ណោះ។ រីឯការដាក់ពាក្យសុំការងារជាក់ស្តែងមួយចំនួនធំអាចមិនសូវផ្តោតខ្លាំងទៅលើភាពត្រូវគ្នារវាងជំនាញដែលមានសម្រាប់ប្រើបំពេញការងារនោះទេ ប៉ុន្តែ និយោជកផ្តោតជាចាំបាច់ទៅលើចំណូលចិត្ត និងការតាំងចិត្តរបស់បុគ្គលចំពោះការងារ និង Soft skills របស់បេក្ខជន ពីព្រោះនិយោជក គង់នឹងផ្តល់លទ្ធភាពឱ្យបេក្ខជនហ្វឹកហ្វឺនក្នុងពេលបំពេញការងារ (On-the-job -training)។

សូមបញ្ជាក់ថាជំនាញនៃភាពទទួលបានការងារមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹង **«បណ្តុំនៃជំនាញមូលដ្ឋាន** (Generic skills)» ។ ហេតុនេះ គេគួរពិនិត្យមើលអំពីសារសំខាន់នៃជំនាញមូលដ្ឋានដើម្បីស្វែងយល់ពីធាតុផ្សំនានារបស់វា។



និយោជក ក្រុមហ៊ុន ឬស្ថាប័នផ្តល់ការងារបានគិតអំពីតម្រូវការជាមូលដ្ឋាន និងចាំបាច់នៃ Generic skills ។ ពោលម្យ៉ាងទៀត និយោជកមានទំនោរស្វែងរកជ្រើសរើស និងរក្សាទុកបុគ្គលិកណាដែលមានជំនាញបែប Generic skills ដូចបានពោលពីខាងដើម។

យើងក៏មានការរំពឹងផងដែរថា ក្នុងចំណោមអ្នកផ្តល់ការអប់រំបណ្តុះបណ្តាលនឹងចាប់ផ្តើមគិតបញ្ចូលនូវ Generic-skills ទៅក្នុងកម្មវិធីសិក្សាជំនាញដល់សិស្ស-និស្សិត ដើម្បីជាការផ្តល់នូវលទ្ធភាពបន្ថែមដល់ពួកគេឱ្យមានការស្វែងយល់និងត្រៀមខ្លួនសម្រាប់ទីផ្សារការងារប្រកបដោយសមត្ថភាព និងការប្រកួតប្រជែង។



## ការកំណត់អំពីបណ្តុំជំនាញមូលដ្ឋាន

Defining generic skills

នៅតាមប្រទេសជឿនលឿនដែលមានការប្រកួតប្រជែងផ្នែកទីផ្សារការងារខ្លាំងក្លា ការកំណត់អំពីជំនាញនៃភាពទទួលបានការងារគឺ «មិនសំដៅចំពោះតែជំនាញដែលត្រូវការសម្រាប់បំពេញការងារ និងការទទួលបានការងារតែមួយមុខប៉ុណ្ណោះទេ ប៉ុន្តែក៏ជាការសំដៅទៅដល់ភាពចម្រុងចម្រើននៅក្នុងស្ថាប័ន ឬសហគ្រាស ដើម្បីនឹងទទួលបាននូវជោគជ័យនិងសក្តានុពលរបស់បុគ្គលិក ឬបុគ្គលម្នាក់ក្នុងការចូលរួមចំណែកកំណត់ទិសដៅយុទ្ធសាស្ត្ររបស់សហគ្រាសផងដែរ។

តាមរយៈការសិក្សាស្រាវជ្រាវនៅបណ្តាប្រទេសជឿនលឿនមួយចំនួន ការកំណត់អំពី Generic skills ត្រូវបានសំដៅលើជំនាញសំខាន់ៗចំនួន៦បែបគឺ៖

**១. ជំនាញមូលដ្ឋាន៖** មានដូចជាការចេះអាន ចេះសរសេរ ការចេះបូកដកលេខ និងចេះផ្នែកបច្ចេកទេសខ្លះ

**២. ជំនាញពាក់ព័ន្ធនឹងសង្គម ឬមនុស្ស៖** មានដូចជា ការទំនាក់ទំនង ទំនាក់ទំនងអន្តរបុគ្គល បំពេញការងារជាក្រុម និងជំនាញបម្រើសេវាកម្មដល់អតិថិជន

**៣. ជំនាញក្នុងការគិតពិចារណា៖** មានដូចជា ការប្រមូលនិងរៀបចំព័ត៌មាន ការដោះស្រាយបញ្ហា ការរៀបចំផែនការ និងចាត់ចែង ការសិក្សាអ្វីថ្មីៗ ការគិតបែបច្នៃប្រឌិត និងគិតជាលក្ខណៈប្រព័ន្ធ

**៤. ជំនាញបែបចូលរួមទទួលខុសត្រូវ៖** មានដូចជាការចេះទទួលខុសត្រូវចំពោះការងារ ផ្តល់ព័ត៌មានដែលមានប្រយោជន៍ ភាពងាយបត់បែន អាចគ្រប់គ្រងពេលវេលារបស់ខ្លួន និងមានការតាំងចិត្តដោយខ្លួនឯង

**៥. ជំនាញទាក់ទងនឹងកិច្ចការជំនួញ៖** មានដូចជាការច្នៃប្រឌិតគំនិត ឬវត្ថុថ្មីៗ និងការចេះធ្វើជំនួញ

**៦. ជំនាញទាក់ទងនឹងសហគមន៍៖** មានដូចជាការស្វែងយល់ និងអាចផ្តល់ព័ត៌មានពីសង្គម មហាជន ជាដើម។



តទៅទំព័របន្ទាប់...

# តើអ្នកណាទទួលខុសត្រូវចំពោះការអភិវឌ្ឍន៍ទូរបណ្តុំជំនាញមូលដ្ឋាន?

ស្ថិតក្នុងដំណើរការនៃការអភិវឌ្ឍនេះ គេសម្គាល់ឃើញថាមានភាពជាដៃគូក្នុងចំណោមភាគីពាក់ព័ន្ធសំខាន់ៗចំនួន៣គឺៈ អ្នកសិក្សា (សិស្ស និស្សិត) អ្នកផ្តល់ការអប់រំបណ្តុះបណ្តាល និងនិយោជក (កន្លែងធ្វើការងារ)។

## តួនាទីរបស់អ្នកសិក្សា

អ្នកសិក្សាម្នាក់ៗត្រូវទទួលស្គាល់ពីសារសំខាន់នៃ generic skills ហើយត្រូវមានការជំរុញទឹកចិត្តនៅក្នុងការរៀនសូត្រ ព្រមទាំងចេះធ្វើការវាយតម្លៃដោយខ្លួនឯង។ ចំពោះអ្នកដែលបានកំពុងបំពេញការងាររយៈពេលខ្លី និងក្រៅម៉ោងត្រូវមានការទទួលខុសត្រូវចំពោះការអភិវឌ្ឍខ្លួន និងការកំណត់ពីមាគ៌ានៃអាជីពដោយខ្លួនឯង។ ក្រៅពីនេះ បុគ្គលគ្រប់រូបក៏ត្រូវចេះសម្របសម្រួលក្នុងការប្រើប្រាស់នូវជំនាញប្រមូលផ្តុំរបស់ខ្លួនដើម្បីអនុវត្តនូវកិច្ចការថ្មីៗនានា។ ពួកគេគួរតែចេះធ្វើការវាយតម្លៃនូវជំនាញទាំងឡាយរបស់ខ្លួន បង្កើតនិងគ្រប់គ្រងនូវបទពិសោធន៍សម្រាប់ការអភិវឌ្ឍជំនាញ រៀបចំកត់ត្រានូវជំនាញ និងលទ្ធផលដែលខ្លួនទទួលបាននាពេលបំពេញការងារកន្លងមក។



## តួនាទីរបស់គ្រូ ឬអ្នកបណ្តុះបណ្តាល

តាមការសិក្សាបង្ហាញឱ្យដឹងថា ភ្នាក់ងារផ្តល់ការអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ គឺជាបុគ្គលគន្លឹះដ៏សំខាន់ក្នុងការបង្កើនចំណេះដឹងផ្នែកជំនាញ generic skills។ ជម្មតា សិស្សមានក្តីរំពឹងក្នុងចិត្តថា គ្រូបង្រៀនរបស់ពួកគេជាមនុស្សដែលធ្លាប់មានពិសោធន៍ជាក់ស្តែងក្នុងជីវិតប្រចាំថ្ងៃ ដោយហេតុថាគ្រូបង្រៀនមិនត្រឹមតែបង្ហាត់នូវជំនាញបច្ចេកទេសតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអាចផ្តល់នូវជំនាញដ៏ទូលំទូលាយនានាពាក់ព័ន្ធនឹងការរស់នៅទៀតផង។



ជាការពិតណាស់ថា គ្រូបង្រៀនផ្នែកការអប់រំបច្ចេកទេសវិជ្ជាជីវៈមិនគ្រាន់តែជាអ្នកដែលផ្តល់នូវគម្រូដ៏ល្អសម្រាប់សិស្សក្នុងការទទួលបានការងារណាមួយនោះទេ ប៉ុន្តែត្រូវតែជាប្រភេទការងារបែបបច្ចេកទេសដែលបានសម្រេចជ្រើសរើស។ ម្យ៉ាងទៀតការងារនោះត្រូវតែជាការងារដែលធ្វើឱ្យសិស្សមានការស្រឡាញ់ចូលចិត្តចង់ធ្វើ មានការសប្បាយ ទទួលបានបទពិសោធន៍ អាចស្វែងរកបាន និងមានការរៀបចំបានល្អ។

តទៅទំព័របន្ទាប់

## តួនាទីរបស់និយោជក និងកន្លែងការងារ

ក្រៅតែពីតួនាទីរបស់អ្នកសិក្សា អ្នកផ្តល់ការអប់រំ គេឃើញថានិយោជកក៏មានភារៈក្នុងការចូលរួមចំណែកជួយសម្រួល ឬដាក់បន្ទុកការងារបែបពិបាកទៅដល់អ្នកដែលទើបបំពេញការងារថ្មីថ្មោងដើម្បីឱ្យពួកគេរៀនសម្របសម្រួលទៅនឹងជីវិតការងារ។ ក្នុងដំណាក់កាលដំបូងនៃជីវិតការងារ និយោជកអាចនឹងប្រើនូវវិធីនៃការធ្វើតេស្តសាកល្បងសមត្ថភាពក្នុងការងារទៅដល់បុគ្គលិកធ្វើការថ្មីនៅក្នុងស្ថាប័ន។

ហេតុនេះ ការអភិវឌ្ឍ ការរក្សា និងការបង្កើនជំនាញបែបប្រមូលផ្តុំនៅក្នុងកន្លែងការងារគឺជាតួនាទីដ៏ចម្បងដែលតម្រូវឱ្យមានការយោគយល់គ្នា ព្រមទាំងមានការចូលរួមពីនិយោជក និងនិយោជិត ទោះបីជាជំនាញបែបនេះអាចហាត់រៀន ឬអនុវត្តបាននៅក្រៅវង្វង់នៃការបំពេញការងារយ៉ាងណាក្តី។



## សរុបសេចក្តី

ហេតុនេះ យើងសង្កេតឃើញថាដើម្បី «អាចទទួលបានការងារសមរម្យ» ដែលបុគ្គលម្នាក់ៗប្រាថ្នាចង់បាន និងចូលចិត្ត គេត្រូវការជាចម្បងនូវជំនាញសំខាន់ៗពីរគឺ: ជំនាញបច្ចេកទេស (Hard skills) និងជំនាញអាចផ្ទេរ ឬជំនាញទន់ (Transferable/Soft skills)។ ប៉ុន្តែ អ្វីដែលនិយោជក និងទីផ្សារការងាររំពឹងចង់បាន និងកំពុងមានការខ្វះខាត នោះគឺជំនាញអាចផ្ទេរ ឬជំនាញទន់ ហើយដែលជំនាញប្រភេទនេះមានការរួមបញ្ចូល ប្រមូលផ្តុំទៅដោយចង្កោមនៃជំនាញមូលដ្ឋានជាច្រើន (Generic skills)។

ក្រៅពីនេះ តម្រូវការបណ្តុំជំនាញមូលដ្ឋាន (Generic skills) សម្រាប់ភាពទទួលបានការងារ (Employability) ក៏មានទំនាក់ទំនងយ៉ាងជិតស្និទ្ធរវាងភាគីពាក់ព័ន្ធនានានៅក្នុងទីផ្សារការងារពោលគឺ សិស្ស និស្សិត អ្នកស្វែងរកការងារធ្វើ និយោជក និងអ្នកផ្តល់ការអប់រំបណ្តុះបណ្តាលផងដែរ។

អាស្រ័យដូចបានជម្រាបមកនេះ លោកអ្នកដែលមានបំណងស្វែងរកការងារធ្វើ និងសិស្ស និស្សិត គួរយកចិត្តទុកដាក់អភិវឌ្ឍនូវជំនាញមូលដ្ឋាននានារបស់ខ្លួន ដើម្បីប្រែក្លាយតម្លៃនៃការសិក្សាផ្នែកជំនាញបច្ចេកទេសឱ្យកាន់តែមានប្រសិទ្ធ និងអាចក្លាយខ្លួនជាបុគ្គលដែលមានសក្តានុពលសម្រាប់បំពេញការងារប្រកបដោយភាពប្រកួតប្រជែង ងាយសម្របទៅនឹងការវិវឌ្ឍនៃទីផ្សារការងារ ក៏ដូចជាពង្រីកលទ្ធភាព និងត្រៀមខ្លួនសម្រាប់ការកើតឡើង ឬការផ្លាស់ប្តូរនូវការងារថ្មីៗ។



សម្តីជាឯក លេខាជាទោ អក្សរជាត្រី

## ពិចារណាអំពីការងារតាមលក្ខណៈអាជីព



# ការពិនិត្យ និងជ្រើសរើសអាជីពដែលសមស្រប

## គណនេយ្យករ

( Accountants )

### សង្ខេបអំពីជំនាញ

### តើគណនេយ្យករធ្វើការងារអ្វីខ្លះ?

- វាយតម្លៃ និងគ្រប់គ្រងព័ត៌មាន
- ជួយក្នុងកិច្ចបម្រើសេវាអតិថិជន ឬភ្ញៀវជ្រើសរើស
- និងដាក់ឱ្យអនុវត្តនូវឧបករណ៍ប្រើប្រាស់ ឬបច្ចេកវិទ្យាផ្សេងៗ

### ជំនាញដែលត្រូវការប្រើ៖

- គណិតវិទ្យា
- ការចេះសម្របសម្រួលរវាងផ្នែកផ្សេងៗនៃការងារ
- មានភាពស្មោះត្រង់
- ការចេះដោះស្រាយបញ្ហាដែលកើតមានចំពោះមុខ

## តើគណនេយ្យករបំពេញកិច្ចការអ្វីខ្លះ?

គណនេយ្យករជាប្រភេទមនុស្សដែលធ្វើការពាក់ព័ន្ធជាមួយនឹងបញ្ជីស្នាម ឬការងារគន់គូរលេខនព្វន្ត។ ពួកគេទទួលខុសត្រូវ ឬទទួលបន្ទុករាល់គ្រប់កិច្ចការទាំងឡាយណាដែលតម្រូវឱ្យមានការរៀបចំ វិភាគ ផ្ទៀងផ្ទាត់នូវរបាយការណ៍ ឬបញ្ជីស្នាមផ្នែកហិរញ្ញវត្ថុសម្រាប់បុគ្គល កិច្ចការជំនួញ ព្រមទាំងស្ថាប័នផ្សេងៗជាច្រើនទៀត។ ឧទាហរណ៍ គណនេយ្យករធ្វើការគិតគូរ និងកំណត់ប៉ាន់ប្រមាណអំពីប្រាក់ចំណូលរបស់ក្រុមហ៊ុន (Revenue) ដែលទទួលបានពីការចំណេញនៅក្នុងរយៈពេលជាក់លាក់មួយដោយគិតជាខែ ឬឆ្នាំ។ ក្រៅពីនេះ គណនេយ្យករ ក៏មាននាទីធ្វើបញ្ជីការចំណាយសរុប (Complete cost) ដែលក្រុមហ៊ុនបានប្រើប្រាស់ ដើម្បីការផលិតទំនិញ ឬក្នុងការបម្រើសេវានានាក្នុងពេលកន្លងមកដូចគ្នាទៅនឹងរយៈពេលនៃការទទួលប្រាក់ចំណេញផងដែរ។

បន្ទាប់ពីបានគិតបញ្ជីអំពីប្រាក់ចំណាយ និងប្រាក់ចំណូលរបស់ក្រុមហ៊ុន ឬស្ថាប័នរួចមក គណនេយ្យករនឹងរៀបចំជារបាយការណ៍សរុប នឹងធ្វើសេចក្តីរាយការណ៍ពីលទ្ធផលទៅជូនប្រធាន ឬនាយកក្រុមហ៊ុន ដើម្បីពិនិត្យថាតើ



តទៅទំព័របន្ទាប់

ក្នុង រយៈពេលដាក់លាក់ណាមួយ ក្រុមហ៊ុនបានទទួលប្រាក់ចំណេញប៉ុន្មាន។ លើសពីនេះ គណនេយ្យករ ក៏ត្រូវការរៀបចំជាប្រព័ន្ធនៃការគ្រប់គ្រង និងថែរក្សារបាយការណ៍ ឬសំណុំឯកសារនានាដែលបានធ្វើ ឬប្រើប្រាស់រួច ដើម្បីជាប្រយោជន៍ក្នុងការពិនិត្យតាមដានអំពីចរន្ត ឬលំហូរនៃការប្រើប្រាស់សាច់ប្រាក់នៅក្នុងក្រុមហ៊ុន ឬស្ថាប័នផងដែរ។ ជាទូទៅ គណនេយ្យករតែងបានប្រើប្រាស់កុំព្យូទ័រ ឬប្រព័ន្ធកុំព្យូទ័រ ដើម្បីរៀបរក្សាទុករបាយការណ៍ហិរញ្ញវត្ថុ ព្រមទាំងប្រើជាមធ្យោបាយក្នុងការដោះស្រាយចំណោទ ឬបញ្ហាពាក់ព័ន្ធនឹងគណិតវិទ្យា និងការគន់គូរលេខ។

## ការអប់រំ និងការបណ្តុះបណ្តាល

ក្នុងអំឡុងពេលសិក្សានៅសាលា ឬមហាវិទ្យាល័យ សិស្ស-និស្សិតតែងត្រូវបានលើកទឹកចិត្ត ឬជំរុញឱ្យខិតខំប្រឹងលើមុខវិជ្ជាគោលសំខាន់មួយចំនួនដូចជា: គណិតវិទ្យា ភាសាបរទេស (ឧទា: អង់គ្លេស) ការរៀបចំរក្សាទុកសៀវភៅ ឬក៏មុខវិជ្ជាបែបជំនួញផ្សេងៗ ប្រសិនពួកគេមានបំណងក្លាយខ្លួន ឬចង់បំពេញការងារជាគណនេយ្យករនាពេលអនាគត។

យ៉ាងណាមិញ សិស្ស-និស្សិតដែលមានមុខជំនាញសិក្សាផ្នែកគណនេយ្យ នឹងមានសក្តានុពលជាពិសេសក្នុងការក្លាយជាគណនេយ្យករ ឬមានការត្រៀមខ្លួននឹងទទួលយកការងារបែបនោះ។ សព្វថ្ងៃនេះ នៅប្រទេសកម្ពុជា គេឃើញមានសាលា ឬមហាវិទ្យាល័យឯកជនជាច្រើនដែលបានបង្រៀន និងផ្តល់ការអប់រំជំនាញគណនេយ្យ ដែលក្នុងការសិក្សាជំនាញប្រភេទនេះ សិស្ស-និស្សិតត្រូវរៀនមុខវិជ្ជាសំខាន់ៗមួយចំនួនដូចជា គណិតវិទ្យា វិធីសាស្ត្រគណនេយ្យ និងកុំព្យូទ័រផងដែរ។

### គួរយល់ដឹង!

✦ **មុខវិជ្ជាសិក្សាក្នុងសាលា:**

ជំនួញ (ធុរកិច្ច) និងគណិតវិទ្យា

✦ **កម្រិតអប់រំទាបបំផុត:**

បរិញ្ញាបត្រ

✦ **ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នា:**

អ្នកបម្រើសេវាកម្មផ្នែកធនាគារ

អ្នកសេដ្ឋកិច្ច

អ្នករៀបចំតារាងពន្ធ ។ល។

### តើអ្នកដឹងឬទេ?

តាមប្រវត្តិសាស្រ្ត បានបង្ហាញភ័ស្តុតាងថាកិច្ចការបែបគណនេយ្យបានចាប់ផ្តើមជាដំបូងគេបំផុតនៅតំបន់មជ្ឈឹមបូព៌ា នាសម័យបុរាណក្នុងអំឡុងឆ្នាំប្រមាណ ៣៦០០ មុនគ្រឹស្តសករាជ។

តទៅទំព័របន្ទាប់

*អត្ថបទដកស្រង់ និងប្រែសម្រួលចេញពីឯកសារ* Career Discovery Encyclopedia. Infobase Publishing. Seven Edition, 2009. *ដោយ ហៃ ហ៊ុនឡេង។ ប្រសិនលោកអ្នកចង់ជ្រាបនូវព័ត៌មានបន្ថែមស្តីពីឯកសារនេះសូមអញ្ជើញរកអាននៅ «បណ្ណាល័យការងារ» របស់ទីភ្នាក់ងារជាតិមុខរបរ និងការងារដោយមេត្រី។*

# ស្ថាបត្យករ

( Architects )

## សង្ខេបអំពីជំនាញ

### តើស្ថាបត្យករធ្វើការងារអ្វីខ្លះ?

- ✦ វាយតម្លៃ និងគ្រប់គ្រងព័ត៌មាន
- ✦ ជួយដល់កិច្ចការរបស់ភ្ញៀវ ឬអតិថិជន
- ✦ ធ្វើកិច្ចការជាក្រុម

## ជំនាញដែលត្រូវការប្រើ៖

- ✦ និយាយពិគ្រោះ និងស្តាប់នូវយោបល់
- ✦ ការពិចារណាបែបបង្កើតថ្មី
- ✦ ការដោះស្រាយបញ្ហា

## តើស្ថាបត្យករបំពេញកិច្ចការអ្វីខ្លះ?

ស្ថាបត្យករធ្វើកិច្ចការដែលពាក់ព័ន្ធនឹងការរៀបគម្រោង និងគូររចនាប្លង់របស់អគារ ដែលរួមបញ្ចូលទាំងបរិវេណខាងក្រៅ ឬទេសភាពជុំវិញផងដែរ។ នៅជុំវិញខ្លួនយើងទាំងអស់គ្នាដែលយើងឃើញ ប្រើប្រាស់ ធ្វើការ និងរស់នៅក្នុងនោះមានដូចជា៖ អគារផ្សារទំនើប សាលារៀន អាកាសយានដ្ឋាន ការិយាល័យ រោងចក្រ និងគេហដ្ឋាន ទាំងអស់នេះសុទ្ធសឹងចាប់ផ្តើមពីគំនិត និងកិច្ចការដែលមាននៅលើតុរបស់ស្ថាបត្យករ។ ធម្មតាស្ថាបត្យករគ្រប់រូបមិនមានជំនាញ ឬឯកទេសដូចគ្នានោះទេ គឺម្នាក់ៗមានជំនាញឯកទេសរៀងៗខ្លួនដូចជា រចនាប្លង់ផ្ទះ ប្លង់ការិយាល័យ ប្លង់កីឡាដ្ឋាន ប្លង់មហោស្រព ប្លង់វត្តអារាម និងប្លង់រោងចក្រជាដើម។ ពេលខ្លះ មានស្ថាបត្យករផ្សេងទៀតផ្តោតលើឯកទេសខាងការរចនាផ្នែកខាងក្នុងនៃអគារ (Interior design) ឬការជួលជុលកែលំអសំណង់អគារចាស់ៗដែលទ្រុឌទ្រោម ឧទា៖ អគារចាស់ៗសល់ពីសម័យអាណានិគមបារាំង។

ជាទូទៅ ស្ថាបត្យករចាប់ផ្តើមធ្វើកិច្ចការរបស់គេជាដំបូងដោយពិគ្រោះយោបល់ជាមួយម្ចាស់សំណង់ ឬអតិថិជនរបស់ខ្លួន។ តាមរយៈការពិភាក្សានេះ ម្ចាស់ ឬអតិថិជននឹងប្រាប់ស្ថាបត្យករ ថាតើពួកគេមានប្រាក់ប៉ុន្មានសម្រាប់ការសាងសង់ រយៈពេលដែលចង់ឱ្យបញ្ចប់ការសាងសង់ និងទទួលយកសំណង់មកប្រើប្រាស់។ បន្ទាប់ពីដឹងនូវសេចក្តីត្រូវការរបស់អតិថិជនខ្លួនរួចហើយ ស្ថាបត្យករនឹងចាប់ផ្តើមធ្វើការសិក្សា និងគូរគំនូរព្រាងដាក់បង្ហាញម្ចាស់សំណង់។ ក្រោយពីពិនិត្យពិភាក្សា កែសម្រួល ព្រមព្រៀង និងធ្វើគំនូរព្រាងជាច្រើនលើកច្រើនសាររួចហើយ ស្ថាបត្យករនឹងរៀបចំគូរសម្រេចនូវប្លង់ និងវង្វាស់ខ្នាតលំអិតរបស់អគារ និងក្រឡាផ្ទៃទៅតាមស្ថានភាព និងការព្រមព្រៀងគ្នា។ ពេលខ្លះ ស្ថាបត្យករនឹងគូរឱ្យឃើញពីលក្ខណៈពិតជាក់ស្តែងរបស់សំណង់អគារ ដើម្បីឱ្យម្ចាស់ងាយមើល និងងាយយល់ពីរូបរាងរបស់អគារ ហើយពេលខ្លះទៀត ប្រសិនសំណង់អគាធំៗ ហើយសាំញ៉ាំ ស្ថាបត្យករនឹងបង្កើតជាគំរូម៉ូត (Model) ខ្នាតតូចនៃសំណង់ អគារនោះផងដែរ មុននឹងចាប់ផ្តើមការសាងសង់។



តទៅទំព័របន្ទាប់

បន្ថែមលើនេះ ស្ថាបត្យករត្រូវយល់ដឹងពីទិដ្ឋភាពច្បាប់ និងបទប្បញ្ញត្តនៃសំណង់របស់ថ្នាក់មូលដ្ឋាន និងកម្រិតជាតិផងដែរ ដោយរួមបញ្ចូលទាំងការតបណ្ដាញទឹក ភ្លើង និងបរិក្ខាអគ្គិសនីផ្សេងៗទៀត។ ស្ថាបត្យករចាំបាច់ត្រូវតែយល់ដឹងអំពីវិធីសាស្ត្រ និងគោលការណ៍នៃវិស្វកម្ម។ ម្យ៉ាងវិញទៀត ពួកគេក៏ត្រូវសិក្សាផងដែរទៅលើកត្តាទីតាំង អាកាសធាតុ ប្រភេទដី ព្រមទាំងបរិដ្ឋានដែលសំណង់អគារត្រូវសាងសង់។ ជួនកាល ស្ថាបត្យករធ្វើការពិភាក្សា ឬពិគ្រោះយោបល់ជាមួយស្ថាបត្យករដទៃទៀតអំពីសំណង់អគារដែលបានសាងសង់ពីមុនមក ដើម្បីពិនិត្យ និងសិក្សាទៅលើវិធីល្អៗក្នុងការដោះស្រាយបញ្ហាអំពីការរចនាប្លង់ ឬការសាងសង់ជាដើម។

## ការអប់រំ និងការបណ្ដុះបណ្ដាល

ដើម្បីអាចចាប់យកអាជីពជាស្ថាបត្យករ គេត្រូវរៀនមុខវិជ្ជាផ្នែកសិក្សាគម្រោងព្រាងរបស់ប្លង់ គណិតវិទ្យា និងសិល្ប:គំនូរស្ថាបត្យកម្ម (បែបគូរឃ្លៀសដោយដៃ មិនមែនគំនូរថ្នាំពណ៌ទេ)។ ក្រៅពីនេះ គេគួររៀនមុខវិជ្ជាសំខាន់ៗមួយចំនួនផ្សេងទៀតដូចជា ប្រវត្តិសាស្ត្រ ភាសាបរទេស ការសរសេរ និងប្រវត្តិសិល្ប:។ តាមរយៈការសិក្សាលើមុខវិជ្ជាដូចបានពោលមកនេះ អាចធ្វើឱ្យគេអភិវឌ្ឍន៍ជំនាញផ្នែកគណិតវិទ្យា ផ្នែកការស្រមៃបង្កើតរបស់អ្វីមួយឱ្យចេញជារូបរាង ផ្នែកទំនាក់ទំនង ដើម្បីក្លាយខ្លួនជាស្ថាបត្យករដ៏ពូកែ និងមានការគាំទ្រ។

មហាវិទ្យាល័យផ្នែកស្ថាបត្យកម្ម តម្រូវឱ្យមានការរៀនរយ:ពេល ៤ ឬ៥ឆ្នាំ ដើម្បីទទួលបានបរិញ្ញាបត្រស្ថាបត្យកម្ម។ ប្រសិន គេចង់បន្តយកបរិញ្ញាបត្រជាន់ខ្ពស់ (Master degree) ផ្នែកនេះ គេត្រូវការពេលវេលាបន្ថែមទៀត។ ក្រៅពីនេះ ស្ថាបត្យករ ក៏តម្រូវឱ្យមានអាជ្ញាបណ្ណក្នុងការធ្វើអាជីវកម្មលើជំនាញឯកទេសរបស់ខ្លួនផងដែរ។ បញ្ញត្តិពាក់ព័ន្ធនឹងអាជ្ញាបណ្ណនេះត្រូវបានកំណត់ដោយក្រសួង ឬស្ថាប័នជំនាញ ឧទាហរណ៍ ក្រសួងដែនដី នគរូបនីយកម្ម និងសំណង់។

### គួរយល់ដឹង!

✦ **មុខវិជ្ជាសិក្សាក្នុងសាលា:**

សិល្ប:គំនូរ និងគណិតវិទ្យា

✦ **កម្រិតអប់រំទាបបំផុត:**

បរិញ្ញាបត្រ

✦ **ព័ត៌មានគួរអានបន្ថែមស្ដីពីអ្នកមានជំនាញស្រដៀងគ្នា:**

អ្នកបច្ចេកទេសផ្នែករចនាប្លង់ក្នុងកុំព្យូទ័រ

អ្នកសិក្សាគម្រោងព្រាងរបស់ប្លង់

ស្ថាបត្យករផ្នែកទេសភាព ឬ សោភ័ណភាពស្ថិតនៅជុំវិញសំណង់អគារ

អ្នកបច្ចេកទេសខាងផែនទី ។ល។

### តើអ្នកដឹងឬទេ?

ដើម្បីអាចក្លាយខ្លួនជាស្ថាបត្យករ និងអាចស្នើសុំអាជ្ញាបណ្ណ នោះគេគួរតែចាប់ផ្ដើមចេញពីការសាកល្បងធ្វើកិច្ចការតូចៗ និងសាមញ្ញនានា ដូចជាស្ថាបនាគំរូផ្ទះតូចៗ ជាដើម។ ម្យ៉ាងវិញទៀត ដើម្បីអាចសិក្សាផ្នែកស្ថាបត្យកម្មឱ្យកាន់តែមានភាពទាក់ទាញ និងបង្កើនចំណេះដឹង គេគួរតែឧស្សាហ៍ពិនិត្យអង្កេតទៅលើសំណង់ស្ថាបត្យកម្មនានាដែលមាននៅក្នុងទីក្រុង ឬទីកន្លែងដទៃទៀតបន្ថែមលើការសិក្សាទ្រឹស្ដីនៅក្នុងសាលា។

តទៅទំព័របន្ទាប់

# ជាងជួសជុលយានយន្ត

( Automobile Mechanics )

## សង្ខេបអំពីជំនាញ

### តើជាងជួសជុលយានយន្តធ្វើការងារអ្វីខ្លះ?

- វាយតម្លៃ និងគ្រប់គ្រងព័ត៌មាន
- ជួយក្នុងសេវាបម្រើអតិថិជន និងភ្ញៀវ
- ជ្រើសរើស និងប្រើប្រាស់ឧបករណ៍ ឬបច្ចេកវិទ្យា

## ជំនាញដែលត្រូវការប្រើ៖

- គណិតវិទ្យា
- ការដោះស្រាយបញ្ហា
- ការទទួលខុសត្រូវ

## តើជាងជួសជុលយានយន្តបំពេញកិច្ចការអ្វីខ្លះ?

ជាងជួសជុលយានយន្ត ឬអ្នកបម្រើសេវាបច្ចេកទេសនៅតាមយានដ្ឋាន ធម្មតាបំពេញការងារតាមរយៈការជួស-ជុល និងបម្រើគ្រប់សេវាកម្មសម្រាប់យានយន្តគ្រប់ប្រភេទមានដូចជា រថយន្ត ឡានក្រុង រថយន្តដឹកទំនិញ ជាដើម។ ពួកគេត្រូវពិនិត្យតាមដាន និងរកឱ្យឃើញពីមូលហេតុ ឬបញ្ហាដែលបណ្តាលឱ្យយានយន្តមិនដំណើរការ ឬខូច ដូច្នេះពួកគេត្រូវបញ្ចេះសាកល្បង និងស្តាប់រាល់គ្រប់ចលនារបស់ម៉ាស៊ីនដើម្បីកំណត់ពីបញ្ហារបស់ម៉ាស៊ីន និងប្រព័ន្ធភ្លើងនៅក្នុងយានយន្តទាំងមូល។

បន្ទាប់ពីកំណត់មុខសញ្ញានៃបញ្ហា ឬភាពមិនប្រក្រតីនានារួចហើយ ជាងជួសជុលត្រូវធ្វើការសម្រេចចិត្តជួសជុលត្រង់ផ្នែកដែលចាំបាច់បំផុត។ ប្រសិន ការជួសជុលមិនអាចធ្វើទៅបានដោយសារតើការខូចខាតមានសភាពធ្ងន់ធ្ងរ ឬបាក់បែកខ្លាំង នោះតម្រូវឱ្យមានការផ្លាស់ប្តូរផ្នែក ឬគ្រឿងណាមួយក៏មិនដឹង។ កិច្ចការចាំបាច់ដែលជាងជួសជុលត្រូវពិគ្រោះជាមួយអតិថិជន ឬម្ចាស់យានយន្ត គឺការរាយការណ៍ពន្យល់ពីមូលហេតុ និងបញ្ហាដែលកើតឡើងចំពោះយាន វិធីជួស-ជុល ឬគួរជួសជុលបែបណា ជាពិសេសត្រូវប្រាប់ពីតម្លៃជួស-ជុល និងថ្លៃឈ្នួលកម្លាំងពលកម្ម។

ជាងជួលជុលក៏មានភារៈជម្រាបជូនភ្ញៀវ ឬម្ចាស់អំពីវិធីនៃការថែទាំយានយន្ត ជៀសវាងការរងាយរងការខូចខាត ឬពោលម្យ៉ាងទៀត ការពារប្រសើរជាងជួសជុល។ នៅពេលពិនិត្យយានយន្តជាងជួសជុលត្រូវតែធ្វើតារាង ឬកត់សម្គាល់រាល់ផ្នែកសំខាន់ៗរបស់យាន ឧទាហរណ៍ ខ្សែក្រវ៉ាត់សុវត្ថិភាពបំពង់ទុយោ ប្រព័ន្ធចង្កូត ប្រព័ន្ធហ្វ្រាំង កង់ ។ល។ ជាទូទៅជាងជួសជុលតែងប្រើប្រាស់ឧបករណ៍ច្រើនប្រភេទសម្រាប់បម្រើឱ្យការជួសជុលរបស់ខ្លួនក្នុងការងារប្រចាំថ្ងៃ។ បច្ចុប្បន្នអាស្រ័យដោយបច្ចេកវិទ្យាមានភាពទំនើប ដូច្នេះជាងជួសជុលអាចប្រើប្រាស់ឧបករណ៍ជាច្រើនរាប់តាំងពីប្រភេទសាម-ញ្ញរហូតដល់ឧបករណ៍បែបកុំព្យូទ័រផងក៏មាន។

ជាងជួសជុល ឬអ្នកបច្ចេកទេសខ្លះ មានជំនាញតែលើយានយន្តតែមួយប្រភេទ ដូចជាឯកទេសខាងជួសជុលឡានក្រុង ម៉ូតូ ជាដើម។ ខ្លះទៀតជំនាញខាងគ្រឿងភ្លើង និងម៉ាស៊ីនត្រជាក់ ហ្វ្រាំង។ ខ្លះមានជំនាញខាងបាញ់ថ្នាំ ប៉ូលា



តទៅទំព័របន្ទាប់

និងគោនតួរថយន្តជាដើម។ ជាងជួសជុលច្រើនតែបម្រើការងារនៅក្នុងយានដ្ឋាន កន្លែងលក់រថយន្តថ្មីៗ ឬតាមហាងលក់ និងជួសជុលយានយន្តនានាផ្សេងទៀត។

## ការអប់រំ និងការបណ្តុះបណ្តាល

ជាងជួសជុលយានយន្តហាក់មិនត្រូវការការអប់រំចំណេះទូទៅខ្ពស់ពេកទេ អាចត្រឹមកម្រិតមធ្យមសិក្សា អនុវិទ្យាល័យ ឬទាបជាងនេះក៏មាន។ ប៉ុន្តែ ប្រការសំខាន់ពួកគេគួរចេះគិតលេខបែបគណិតវិទ្យា និងមានការយល់ដឹងខ្លះពីប្រព័ន្ធភ្លើង និងគ្រឿងអេឡិកត្រូនិក។ គេសង្កេតឃើញថា ជាងជួសជុលយានយន្តតែងចាប់ផ្តើមអាជីពរបស់ពួកគេតាមរយៈការចូលទៅរៀនអនុវត្ត និងហាត់ការងារដោយផ្ទាល់ពីមិនទាន់ចេះសោះពីយានដ្ឋាន ឬម្ចាស់យានដ្ឋានណាមួយ។ ដូច្នេះ ជំនាញ និងការងាររបស់ពួកគេគឺជាការរៀនដោយអនុវត្តជាក់ស្តែងជាប្រចាំថ្ងៃរហូតដល់ចេះស្ទាត់ ពុំនោះសោតពួកគេត្រូវការពេលវេលាយូរបន្តួរដើម្បីរៀនជំនាញ។ បន្ទាប់ពីរៀនចេះហើយ ជាងខ្លះក៏បន្តធ្វើការយកបទពិសោធន៍មួយរយៈពេលទៀតដើម្បីបង្កើនចំណេះឱ្យកាន់តែច្បាស់ ស្រប ពេលដែលពួកគេអាចរកប្រាក់បានហើយ។ ក្រៅពីនេះ ក៏មានសាលាបច្ចេកទេសបណ្តុះបណ្តាលវិជ្ជាជីវៈរបស់រដ្ឋ ឯកជន





និងអង្គការក្រៅរដ្ឋាភិបាលមួយចំនួនបានបង្ហាត់លើមុខវិជ្ជាជួសជុលយានយន្ត និងមុខវិជ្ជាអគ្គិសនី ឬអេឡិកត្រូនិកផងដែរ ឧទា: សាលាអប់រំបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ (Technical Vocational Education Training) ទាំងអស់ដែលស្ថិតនៅក្រោមឱវាទក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជា - ជីវៈ។ ប្រការសំខាន់ដែលជាងជួសជុលត្រូវត្រងត្រាប់គឺការព្យាយាមពង្រីកចំណេះដឹងទៅតាមការវិវឌ្ឍថ្មីៗនៃបច្ចេកវិទ្យារបស់យានយន្តដែលកាន់តែមានភាពជឿនលឿនខាងបច្ចេក-វិទ្យាកុំព្យូទ័រ ទោះបីជាគេទទួលបានការអប់រំពីទីកន្លែងណា ឬមានបទពិសោធន៍រយៈពេលយូរប៉ុណ្ណាក៏ដោយ។

### គួរយល់ដឹង!

- **មុខវិជ្ជាសិក្សាក្នុងសាលា:**

ផ្នែកជំនួញ ផ្នែកបច្ចេកទេស និងយានដ្ឋាន

- **កម្រិតអប់រំទាបបំផុត:**

អនុវិទ្យាល័យ ឬវិទ្យាល័យ

- **ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នា:**

កម្មករផ្នែកឧស្សាហកម្មយានយន្ត

អ្នកត្រួតពិនិត្យយានយន្ត

ជាងជួសជុលយានយន្តដែលទទួលរងគ្រោះថ្នាក់ ។ល។



តទៅទំព័របន្ទាប់

# អ្នកគិតបញ្ជី ឬគិតលុយ

( Cashiers )

## សង្ខេបអំពីជំនាញ

### តើអ្នកគិតបញ្ជីធ្វើការងារអ្វីខ្លះ?

- បែងចែកសាច់ប្រាក់ និងធនធាន
- ជួយកិច្ចការដល់ភ្ញៀវ និងអតិថិជន
- ជ្រើសរើស និងប្រើប្រាស់ឧបករណ៍ ឬបច្ចេកវិទ្យា

## ជំនាញដែលត្រូវការប្រើ៖

- ស្លូតបូត និងស្មោះត្រង់
- គណិតវិទ្យា
- និយាយ និងស្តាប់ (ប្រាស្រ័យទាក់ទងជាមួយភ្ញៀវ)

## តើអ្នកគិតបញ្ជីបំពេញកិច្ចការអ្វីខ្លះ?

អ្នកគិតលុយធ្វើការប្រមូលប្រាក់ និងទទួលប្រាក់ពីភ្ញៀវ ឬអតិថិជនបន្ទាប់ពីការទិញឥវ៉ាន់ ឬបានប្រើប្រាស់សេវារួចហើយ។ ពួកគេក៏មានភារៈប្តូរលុយ និងអាប់លុយដែលនៅសេសសល់ បំពេញបែបបទសម្រាប់ភ្ញៀវដែលប្រើបណ្ណធនាគារ (Credit card) ព្រមទាំងផ្តល់ត្រលប់ទៅភ្ញៀវវិញនូវតារាងចំណាយ (Receipt)។ អ្នកគិតប្រាក់ដែលធ្វើការនៅតាមទីកន្លែងផ្សេងៗគ្នាតែងមានមុខងារ និងតួនាទីមិនដូចគ្នានោះទេ ឯឈ្មោះទៀតសោតក៏និយមហៅប្លែកៗគ្នាដែរ ឧទាហរណ៍ អ្នកគិតលុយនៅកន្លែងរោងមហោស្រព ឬរោងកុន អាចហៅថាជាអ្នកលក់សំបុត្រ។ អ្នកគិតលុយដែលបម្រើការនៅកន្លែងស្ថានីយ៍ឡានក្រុង ឬមធ្យោបាយធ្វើដំណើរផ្សេងៗ អាចហៅថាភ្នាក់ងារលក់សំបុត្រ ឬភ្នាក់ងារធ្វើដំណើរ ។ល។ ប៉ុន្តែទោះបីជាពួកគេបម្រើការងារនៅទីកន្លែងប្លែកៗគ្នា និងកាលៈទេសៈខុសគ្នាយ៉ាងណាក្តី គេសង្កេតឃើញថាការងាររួមមួយដែលពួកគេត្រូវយកចិត្តទុកដាក់គឺ ការរក្សាទុកដាក់បញ្ជីចំណូលចំណាយ ការទូទាត់សាច់ប្រាក់ និងការបិទបញ្ជីប្រចាំថ្ងៃ ប្រចាំអាទិត្យ ឬប្រចាំខែ។

លើសពីនេះ គេសង្កេតឃើញថាអ្នកគិតលុយដែលធ្វើការនៅក្នុងកន្លែងលក់ឱសថ ហាងលក់បន្លែ ផ្សារទំនើប អាចជួយកិច្ចការច្រក ឬវេចខ្ចប់ទំនិញដែលភ្ញៀវបានទិញ និងបន្ទាប់ពីបានគិតលុយរួចរាល់។ ពេលខ្លះទៀត ពួកគេក៏ជួយបិតផ្លាកតម្លៃ និងផ្លាកលើមុខទំនិញនានា រៀបចំឥវ៉ាន់ដាក់លើធ្នើដែលមាននៅក្នុងហាង ឬធ្វើកិច្ចការបន្ទាប់បន្សំផ្សេងទៀត។ ចំណែកអ្នកគិតលុយនៅក្នុងកិច្ចការជំនួញឯទៀតៗ អាចធ្វើកិច្ចការផ្នែកដាក់តម្កល់សាច់ប្រាក់ក្នុងធនាគារ (Bank deposits) រៀបចំតារាងពន្ធ និងរៀបចំបញ្ជីបើកប្រាក់សម្រាប់បុគ្គលិក ជាដើម។ អ្នកគិតលុយក៏អាចធ្វើការនៅក្នុងភោជនីយដ្ឋាន និងសណ្ឋាគារផងដែរ ក្នុងករណីនេះពួកគេខ្លះអាចមានភារៈជាអ្នកទទួលការកុម្ម៉ង់ ឬកក់ទំនិញនិងកន្លែងតាមការហៅទូរសព្ទ។

អ្នកគិតលុយច្រើនតែប្រើប្រាស់ម៉ាស៊ីនគិតលុយ (Cash register) ជាមធ្យោបាយងាយស្រួលក្នុងការងាររបស់ពួកគេ។ គេសង្កេតឃើញថា នៅកម្ពុជាពីមុន ការគិតប្រាក់ច្រើនតែប្រើម៉ាស៊ីនគិតលេខធម្មតា ឬពេលខ្លះមិនទាំងមានផង។ បច្ចុប្បន្ននេះ បច្ចេកវិទ្យាទំនើបបាននាំមកនូវម៉ាស៊ីនគិតលុយដែលឃើញមានប្រើជាហូរហែរនៅតាមហាងលក់ទំនិញ និង



តទៅទំព័របន្ទាប់

ទីកន្លែងបម្រើសេវាកម្មទំនើបៗ។ បន្ថែមលើនេះ អ្នកគិតលុយក៏អនុវត្តកិច្ចការរបស់គេជាមួយម៉ាស៊ីនកុំព្យូទ័រ ដើម្បីរក្សាទុកព័ត៌មាន ពិនិត្យតម្លៃទំនិញ និងផ្តល់តារាងចំណាយលម្អិតសម្រាប់ភ្ញៀវផងដែរ។ ពេលខ្លះទៀត អ្នកគិតលុយប្រើឧបករណ៍សម្រាប់ស្កែន (Optical scanner) ដើម្បីគិតលុយពីមុខទំនិញនីមួយៗ។



## ការអប់រំ និងការបណ្តុះបណ្តាល

និយោជកខ្លះតម្រូវថា អ្នកគិតលុយត្រូវមានកម្រិតអប់រំថ្នាក់មធ្យមសិក្សាទុតិយភូមិ ឬខ្លះមិនតម្រូវនោះទេ។ ជម្មតាអ្នកមានកម្រិតអប់រំបែបនេះអាចយល់ដឹងកិច្ចការកម្រិតមូលដ្ឋានមួយចំនួនដែលអាចជួយដល់ការងារជាអ្នកគិតលុយដូចជាការរៀបចំទុកដាក់សៀវភៅ ឥវ៉ាន់ ការនិយាយប្រាស្រ័យជាមួយអតិថិជន ចេះប្រើប្រាស់កុំព្យូទ័រ ឬម៉ាស៊ីនគិតលុយចេះលេខនព្វន្ត និងអាចចេះភាសាបរទេសខ្លះៗ។ ដោយឡែកសម្រាប់កិច្ចការគិតលុយបែបស្មុគស្មាញ ឬក្នុងកិច្ចការជំនួញធំៗ និយោជកតម្រូវឱ្យបេក្ខជនមានសញ្ញាបត្រខ្ពស់ទៅតាមបែបផែននោះដែរ។



ជាទូទៅ អ្នកគិតលុយធ្វើការងារប្រចាំថ្ងៃដោយទំនាក់ទំនងជាមួយអតិថិជន ហេតុនេះពួកគេគួរមានឥរិយាបថរួសរាយរាក់ទាក់ ពូកែទំនាក់ទំនង និងអត់ធ្មត់។ បន្ថែមពីលើនេះ ពួកគេក៏គួរមានចំណេះច្បាស់លាស់ផ្នែកគណិតវិទ្យាក្នុងការបូកដក និងគិតបញ្ជី។ ចំណែកកិច្ចអត់ធ្មត់ខាងកម្លាំងកាយវិញ ពួកគេត្រូវស៊ូទ្រាំក្នុងការឈររយៈពេលយូរ ឬនៅមួយកន្លែងក្នុងពេលបំពេញការងារ។

### គួរយល់ដឹង!

✦ **មុខវិជ្ជាសិក្សាក្នុងសាលា:**

ផ្នែកជំនួញ និងគណិតវិទ្យា

✦ **កម្រិតអប់រំទាបបំផុត:**

មធ្យមសិក្សាទុតិយភូមិ

✦ **ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នា:**

អ្នកបម្រើសេវាកម្មវិស័យធនាគារ

អ្នកតំណាងផ្នែកលក់

អ្នកគ្រប់គ្រងអគារទំនិញ

តទៅទំព័របន្ទាប់

# ពេទ្យធ្មេញ (ទន្តពេទ្យ)

(Dentists)

## សង្ខេបអំពីជំនាញ

### តើពេទ្យធ្មេញធ្វើការងារអ្វីខ្លះ?

- ទំនាក់ទំនងផ្នែកគំនិត
- ជួយកិច្ចការដល់ភ្ញៀវ និងអតិថិជន
- ជ្រើសរើស និងប្រើប្រាស់ឧបករណ៍ ឬបច្ចេកវិទ្យា

### ជំនាញដែលត្រូវការប្រើ៖

- ការធ្វើសេចក្តីសម្រេចចិត្ត
- ការដោះស្រាយបញ្ហា
- ការទទួលខុសត្រូវ

## តើពេទ្យធ្មេញបំពេញកិច្ចការអ្វីខ្លះ?

ទន្តពេទ្យមានភារៈ និងជំនាញពិសេសក្នុងការជួយឱ្យមនុស្សទូទៅមានភាពប្រសើរខាងសុខភាពមាត់ធ្មេញ។ ពួកគេត្រូវលាងសម្អាត ជួសជុល ផ្លាស់ប្តូរ និងធ្វើឱ្យធ្មេញត្រង់ល្អ។ ទន្តពេទ្យដែលមានឯកទេសទូទៅនឹងត្រូវធ្វើកិច្ចការបន្ទាប់បន្សំជាច្រើនទៀត ឧទាហរណ៍ កិច្ចការផ្នែកថតឆ្លុះធ្មេញដោយប្រើកាំរស្មីអ៊ិច (X Rays) ជួសជុលបំពេញធ្មេញដែលខូចខាត ឬចន្លោះប្រហោង លាងសម្អាតធ្មេញដែលកាន់ក្អែរ ឬជាតិកំបោរ ព្រមទាំងដកធ្មេញដែលឈឺ ឬដែលមានដង្កូវស៊ី។ ពេទ្យធ្មេញ នឹងមានភារៈពន្យល់អំពីបញ្ហាដែលនាំឱ្យមានជម្ងឺមាត់ធ្មេញ និងឱ្យដំបូន្មានទៅដល់អតិថិជន ឬអ្នកជម្ងឺរបស់ពួកគេឱ្យបានយល់ដឹងអំពីការថែរក្សាសុខភាពមាត់ធ្មេញ ដូចជាការដុសធ្មេញឱ្យបានត្រឹមត្រូវតាមក្បួនបច្ចេកទេស ការប្រើប្រាស់អំបោះសម្អាតធ្មេញ (Floss) ទឹកថ្នាំខ្ពុរមាត់ ព្រមទាំងពន្យល់អំពីប្រភេទអាហារផ្សេងៗដែលមានផលល្អ និងផលអាក្រក់សម្រាប់ធ្មេញ។

ជម្មតា ទន្តពេទ្យអាចពិនិត្យ និងព្យាបាលអ្នកជម្ងឺច្រើននាក់ក្នុងមួយថ្ងៃអាស្រ័យទៅតាមកាលវិភាគរបស់ពួកគេ។ អ្នកជម្ងឺខ្លះគ្រាន់តែពិនិត្យធ្មេញ អ្នកខ្លះត្រូវការជួសជុល ឬព្យាបាលទៅតាមប្រភេទនៃសភាពនីមួយៗ។ ពេលពិនិត្យ និងពិគ្រោះរួចហើយ ករណីត្រូវការព្យាបាល ឬជួសជុល នោះអ្នកជម្ងឺត្រូវធ្វើកាលវិភាគសម្រាប់ការណាត់ជួបជាដំណាក់កាលៗទៅតាមការសម្រេចរបស់គ្រូពេទ្យ។ ទន្តពេទ្យមានចែកចេញជាឯកទេសលំអិតតូចៗទៀតដូចជា៖

- ឯកទេសខាងតម្រង់ធ្មេញដែលដុះមិនស្មើ និងមិនល្អ (Orthodontists)
- ឯកទេសខាងវះកាត់ ឬដកឫសធ្មេញដែលឈឺ និងជួសជុលថ្គាម (Oral surgeons)
- ឯកទេសខាងព្យាបាលអញ្ចាញធ្មេញដែលមានជម្ងឺ (Periodontists)
- ឯកទេសខាងធ្វើធ្មេញសិប្បនិម្មិត និងធ្មេញសម្រាប់ពាក់ (Prosthodontists)
- ឯកទេសខាងព្យាបាលជម្ងឺធ្មេញសម្រាប់កុមារ (Pedodontists)
- ឯកទេសខាងពិនិត្យរោគសញ្ញាជម្ងឺក្នុងមាត់ (Oral pathologist)
- ឯកទេសខាងព្យាបាលឫសធ្មេញ (Endodontists)



តទៅទំព័របន្ទាប់

គេសង្កេតឃើញថា ទន្តពេទ្យអាចជាបុគ្គលិកដែលបម្រើការនៅតាមមន្ទីរពេទ្យសាធារណៈរបស់រដ្ឋ តាមគ្លីនិក និងខ្លះទៀតជាគ្រូបង្រៀន ជាអ្នកស្រាវជ្រាវ ។ល។ បច្ចុប្បន្ននៅកម្ពុជាបញ្ហាសុខភាពមាត់ធ្មេញគឺជាចំណុចគួរឱ្យមានការយកចិត្តទុកដាក់ និងស្វែងយល់ជាខ្លាំង ដោយហេតុថាក្នុងចំណោមប្រជាពលរដ្ឋភាគច្រើន ជាពិសេសអ្នករស់នៅជនបទមិនទាន់យល់ច្បាស់ពីសារសំខាន់នៃការថែទាំសុខភាពមាត់-ធ្មេញឱ្យបានល្អនៅឡើយ។ ដោយឡែក ខាងផ្នែកសេវាទន្តពេទ្យក៏ឃើញមានការរីកដុលដាលច្រើនដែរ ទាំងផ្នែកសេវាសាធារណៈ និងសេវាទន្តពេទ្យឯកជន។

ទន្តពេទ្យដែលបម្រើសេវាឯកជនត្រូវគ្រប់គ្រងការងារជាអ្នកឯកទេសផង និងត្រូវគិតអំពីការគ្រប់គ្រងគ្លីនិក ទីតាំងសម្ភារបរិក្ខា ការជួលបុគ្គលិកឱ្យបម្រើការ ការធានាដំណើរការរបស់គ្លីនិក ការបម្រើ និងទាក់ទាញជំនឿចិត្តពីអតិថិជន ជា-ដើម។ អាស្រ័យដោយកិច្ចការមានភាពមមាញឹក ហេតុនេះទន្តពេទ្យអាចធ្វើការពេញម៉ោងក្នុងមួយសប្តាហ៍។ គួរកត់សម្គាល់ថា ក្រៅអំពីការចំណាយពេលយូរសម្រាប់ការសិក្សា និងទទួលបានឯកទេសខាងផ្នែកនេះ ការចំណាយទៅលើបរិក្ខាពេទ្យ និងសម្ភារប្រើប្រាស់ក៏មានតម្លៃខ្ពស់ផងដែរ ជាពិសេសសម្រាប់ទន្តពេទ្យឯកជនដែលត្រូវចំណាយផ្ទាល់ខ្លួន។

## ការអប់រំ និងការបណ្តុះបណ្តាល

ជាទូទៅ មុខវិជ្ជាសិក្សាផ្នែកវិទ្យាសាស្ត្រ និង គណិតវិទ្យាគឺជាមុខវិជ្ជាចាំបាច់សម្រាប់ត្រៀមខ្លួនសិក្សា និងក្លាយជាទន្តពេទ្យអាជីព។ ក្រៅពីនេះ មុខវិជ្ជាសំខាន់ដែលអាចជួយក្នុងកិច្ចការទន្តពេទ្យរួមមាន ការមើលឃើញបានល្អ ការអាចធ្វើកិច្ចការដោយដៃដោយសន្សឹមៗ ព្រមទាំងមានសិល្បៈក្នុងការជួសជុល ព្យាបាល និងថែទាំអ្នកជម្ងឺ។ ទន្តពេទ្យត្រូវមានការអប់រំកម្រិតបរិញ្ញាបត្រ ឬខ្ពស់ជាងនេះ។

### គួរយល់ដឹង!

✦ **មុខវិជ្ជាសិក្សាក្នុងសាលា:**

ផ្នែកគីមីវិទ្យា និងផ្នែកសុខភាព

✦ **កម្រិតអប់រំទាបបំផុត:**

សញ្ញាបត្រវេជ្ជសាស្ត្រ (Medical degree)

✦ **ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នា:**

ពេទ្យផ្នែកជម្ងឺឆ្អឹងខ្នង

ពេទ្យភ្នែក

ពេទ្យឯកទេសផ្នែកតម្រង់ ឬធ្វើឱ្យធ្មេញត្រង់ជួរ

អ្នកឯកទេសរូបវិទ្យា

### តើអ្នកដឹងឬទេ?

នៅកម្ពុជា គេសង្កេតឃើញថានៅទីជនបទតែងមានសេវាជួសជុល និងដាក់ធ្មេញ ដែលក្នុងចំណោមនោះ គេមិនដឹងថាអ្នកឯកទេសដែលបម្រើសេវានេះភាគច្រើនជាទន្តពេទ្យដែលទទួលបានការអប់រំផ្លូវការ ឬក៏គ្រាន់តែជាអ្នកជំនាញដែលអនុវត្តការងារនេះតាមរយៈបទពិសោធន៍ ឬការចេះចាំកម្រិតបែបណានោះទេ។ ហេតុនេះ ប្រសិនធ្វើការកត់សម្គាល់ នោះគេនឹងឃើញមានទីតាំងខ្លះសរសេរស្លាកថា «**ជាងដាក់ធ្មេញ ឬដាក់ធ្មេញ**» តើពាក្យ «**ជាង**» សំដៅអ្នកចេះដាក់ ដក ឬជួលជុលធ្មេញ ឬក៏អ្នកបានសិក្សាវិជ្ជាខាងទន្តពេទ្យ? សូមបញ្ជាក់ថា នេះគឺគ្រាន់តែជាការកត់សម្គាល់តែប៉ុណ្ណោះ ជាក់ស្តែងប្រជាពលរដ្ឋតែងប្រើសេវាទាំងពីរប្រភេទនេះ ទោះជាគ្លីនិកទន្តពេទ្យ ឬក៏ជាជាងដាក់ធ្មេញក្តី។

**ចេះពីរៀន មានពីរក**




# ការរៀបចំមូលដ្ឋានគ្រឹះ ក្នុងការស្វែងរកការងារធ្វើ

តើអ្នកធ្លាប់ចេញដំណើរទៅកាន់កន្លែងថ្មីមួយដោយមិនចាំបាច់មានផែនទី ឬដោយមិនស្គាល់ផ្លូវដែរឬទេ? តើលទ្ធផលចុងក្រោយនឹងទៅជាយ៉ាងណា? យ៉ាងហោចណាស់អ្នកត្រូវតែមានញាណពិសេសដែលអាចដឹងអំពីទិស ឬការចំណាំផ្សេងៗ ពុំនោះសោតអ្នកនឹងវង្វេងវិលវល់ដោយមិនដឹងទិសតំបន់នោះឡើយ។ ក្នុងលក្ខខណ្ឌបែបនេះ ប្រហែលជានៅទីបញ្ចប់អ្នកបានទៅដល់ទីដៅយឺតជាងការរំពឹងទុក ឬក៏អ្នកអាចនឹងបោះបង់ចោលការធ្វើដំណើរនោះ ហើយវិលត្រលប់មកផ្ទះវិញ។ ទោះជានៅក្នុងករណីណាក៏ដោយ ការមកដល់ទីដៅដោយមិនមានការកំណត់ទិស ឬផ្លូវធ្វើដំណើរជាក់លាក់ ទំនងជាជួបប្រទះនូវការលំបាកខ្លាំងណាស់។ យ៉ាងណាមិញ *«ការស្វែងរកការងារធ្វើ»* ដែលមិនមានកំណត់ទិសដៅជាក់លាក់ និងមិនបានត្រៀមខ្លួនជាមុន គឺប្រៀបបាននឹងការធ្វើដំណើរដែលមិនមានគោលបំណងច្បាស់លាស់ដូច្នោះដែរ។ អ្នកនឹងយល់មិនបានល្អិតល្អន់អំពីចំណុចដែលត្រូវចាប់ផ្តើម ហើយអ្នកនឹងមានគំនិតតិចតួច ឬភាពស្រពិចស្រពិលអំពីផ្លូវ ឬវិធីដែលអាចឈានទៅដល់ការទទួលបានការងារដ៏សមគួរមួយ។ អ្នកស្វែងរកការងារណាម្នាក់ដែលមិនបានរៀបចំត្រៀមលក្ខណៈជាមុននឹងឃើញថាជាចុងក្រោយគេមិន បានទទួលនូវអ្វីស្របតាមបំណងប្រាថ្នាឡើយ។ ប្រការនេះ ប្រហែលជាអាចបណ្តាលមកពីហេតុថាគេមានការព្រួយបារម្ភជាមួយស្ថានការណ៍នោះខ្លាំងពេក ប៉ុន្តែផ្ទុយទៅវិញស្ថានភាពបែបនោះនឹងមិនបានផ្តល់នូវការរីកចំរើនអ្វីសោះទេ។ ជានិច្ចកាលគេនឹងចំណាយពេលយូរអង្វែងដើម្បីទៅឱ្យដល់គោលដៅ ប្រសិនបើគេអាចមានឱកាសបែបនោះ។ ជាញឹកញយ គេនឹងសម្រេចចិត្តទទួលយកអ្វីមួយផ្សេងក្រៅពីអ្វីដែលគេពិតជាចង់បាន។ អាស្រ័យហេតុនេះ អ្នកត្រូវតែមាន **«ផែនការយុទ្ធសាស្ត្រ»** ក្នុងការកំណត់ទិសដៅដើម្បីឈានដល់បំណងចុងក្រោយក្នុងការស្វែងរកការងារ។ នៅក្នុងខណៈពេលដែលស្ថានភាពសេដ្ឋកិច្ចមានសភាពតានតឹង ឬមានវិបត្តិនោះក៏ជាចំណុចសំខាន់ពិសេសមួយសម្រាប់ទាញយកប្រយោជន៍ពីការប្រកួតប្រជែងក្នុងទីផ្សារការងារផងដែរ។ បានន័យថាតម្រូវការការងារអាចត្រូវបានកាត់បន្ថយ ដូច្នេះប្រសិនអ្នកមានសមត្ថភាពពិតប្រាកដ នោះនឹងក្លាយជាបេក្ខជនដ៏មានសក្តានុពលព្រមទាំងឱកាសច្រើនជាងអ្នកដទៃជាក់ជាពុំខាន។

ដូច្នេះឥឡូវនេះអ្នកដឹងអំពីមូលដ្ឋានគ្រឹះ និងផែនការសកម្មភាពជាក់លាក់ ថាតើអ្នកនឹងជ្រើសយកផ្លូវណាសម្រាប់ការអភិវឌ្ឍ និងអនុវត្តផែនការនោះ? ខាងក្រោមនេះគឺជាចំណុចគន្លឹះដែលជួយណែនាំអ្នកឱ្យអភិវឌ្ឍនូវមូលដ្ឋានគ្រឹះដែលអ្នកនឹងចាប់ផ្តើមការស្វែងរកការងារ ហើយនឹងផ្តល់ឱ្យរូបអ្នកនូវមធ្យោបាយអនុវត្តប្រកបដោយប្រសិទ្ធភាពព្រមទាំងត្រូវចំទិសដៅដែលត្រូវស្វែងរក។

តទៅទំព័របន្ទាប់

*អត្ថបទដកស្រង់ និងប្រែសម្រួលដោយ **ហៃ ហ៊ុនឡេង** ចេញពីឯកសារ* Alan De Back, Get Hired in a Tough Market: Insider Secrets to Find and Land the Job You Need Now. Mc Graw Hill. *លោកអ្នក និងមិត្តអ្នកអានទាំងអស់អាចរកអាន និងសិក្សាស្រាវជ្រាវឯកសារអំពីអាជីព និងការងារជាច្រើនប្រភេទដែលមានតម្កល់ទុកនៅក្នុងបណ្ណាល័យការងារ របស់ទីភ្នាក់ងារជាតិមុខរបរ និងការងារ គ្រប់ពេលម៉ោងធ្វើការ។*

## តើ «មូលដ្ឋានគ្រឹះ» មានន័យដូចម្តេច?

មុនពេលចាប់ផ្តើមបង្កើតមូលដ្ឋានគ្រឹះ និងអភិវឌ្ឍផែនការ អ្នកត្រូវតែដោះស្រាយបញ្ហាជាក់ស្តែងចំពោះមុខមួយចំនួនដែលជាប់ពាក់ព័ន្ធជាមួយកិច្ចការស្វែងរកការងារធ្វើ។ ការព្រងើយកន្តើយជាមួយបញ្ហាទាំងនោះអាចបណ្តាលឱ្យខូចផែនការមុនការចាប់ផ្តើមចេញដំណើរទៅទៀត។ ខាងក្រោមនេះជាសំណួរមួយចំនួនដែលអ្នកត្រូវតែឆ្លើយ ឬព្យាយាមដោះស្រាយឱ្យខាងតែបាន៖

## តើអ្នកគួរចំណាយពេលប៉ុន្មានដើម្បីផ្តោតលើការស្វែងរកការងារ?

ចម្លើយគឺងាយបំផុត អ្នកត្រូវចំណាយពេលច្រើនបំផុតតាមដែលអ្នកអាចធ្វើទៅបាន។ យើងទាំងអស់គ្នាដឹងថានេះជារឿងពិបាកក្នុងការលៃលកពេលវេលា។ ជាការជាក់ស្តែង សំណួរថាតើរយៈពេលប៉ុន្មានដែលអ្នកគួរ និងផ្តោតចំពោះការស្វែងរកការងារធ្វើ វាមានការពាក់ព័ន្ធជាមួយនឹងស្ថានភាពផ្ទាល់ខ្លួនរបស់អ្នក។ តើអ្នកមានការទទួលខុសត្រូវផ្ទាល់ខ្លួនដែរឬទេ? ឧទាហរណ៍ កូនតូចៗ ឪពុកម្តាយចាស់ៗ ឬកិច្ចការផ្ទះ ជាដើម ដែលត្រូវការពេលវេលានឹងការយកចិត្តទុកដាក់ពីរូបអ្នក។ អ្នកត្រូវយកចិត្តទុកដាក់ និងប្រុងប្រយ័ត្នដោយរក្សាឱ្យបាននូវតុល្យភាពរវាងភារកិច្ចផ្សេងៗដែលត្រូវបំពេញ និងពេលវេលាដែលអ្នកត្រូវផ្តោតអារម្មណ៍សម្រាប់ការស្វែងរកការងារ។

អ្នកប្រឹក្សាផ្នែកការងារខ្លះនឹងប្រាប់អ្នកថា **«ការបំពេញកិច្ចការក្នុងអំឡុងពេលកំពុងស្វែងរកការងារនេះហើយ គឺជាការងារពេញម៉ោងរបស់អ្នក»** ហើយអ្នកត្រូវតែយកចិត្តទុកដាក់ចំពោះកិច្ចការនេះឱ្យមែនទែន។ អ្នកត្រូវកំណត់ថាពេលណាជាម៉ោងពិតប្រាកដរបស់អ្នក ហើយរៀបចំកម្មវិធីទៅតាមនោះ។ នេះគឺជាចំណុចសំខាន់ដែលអ្នកអាចធ្វើការតាមរបៀបដែលបានកំណត់ទុកដោយមានសភាពទៀងទាត់ប្រចាំថ្ងៃ។ ប្រហែលជាចំណាយពេល ៦ម៉ោងក្នុង ១ថ្ងៃគឺជាប្រការដែលអ្នកអាចធ្វើបាន។ ក្នុងករណីនេះ អ្នកខ្លះជ្រើសយកម៉ោង៩ ដល់ម៉ោង១២ព្រឹក ហើយសម្រាកញ៉ាំបាយថ្ងៃត្រង់បន្តិច។ បន្ទាប់មក ចាប់ផ្តើមបន្តពីម៉ោង១ ដល់ម៉ោង៤ល្ងាច។ ការផ្សារភ្ជាប់ទៅនឹងម៉ោងពេលដោយជាក់លាក់បែបនេះរៀងរាល់ថ្ងៃ អាចជួយឱ្យអ្នកបង្កើននូវលទ្ធផលថ្មីៗក្នុងការស្វែងរកការងារ ជាជាងធ្វើការពេញ១ថ្ងៃដោយមិនមានកាលវិភាគច្បាស់លាស់។ ទោះជាយ៉ាងណាក្តី អ្នកមិនត្រូវភ្លេចអំពីការសម្រាក ឬការជជែកកំសាន្តជាមួយក្រុមញាតិ និងមិត្តភ័ក្តិនោះទេ។



## តើអ្នកគួរផ្តល់រង្វាន់លើកទឹកចិត្ត និងថែទាំខ្លួនឯងយ៉ាងម៉េចក្នុងពេលកំពុងស្វែងរកការងារ?

គោលបំណងចុងក្រោយរបស់អ្នកគឺរកការងារដែលអ្នកចូលចិត្តឱ្យទាល់តែបាន។ កិច្ចការនេះទំនងជាចំណាយពេល និងការខំប្រឹងប្រែងអស់ជាច្រើន ប៉ុន្តែការឱ្យរង្វាន់លើកទឹកចិត្តដល់ខ្លួនឯងគឺជាប្រការដ៏គួរឱ្យរីករាយដែលអ្នកគួរតែអនុវត្ត។ ស្របគ្នាជាមួយនឹងគោលបំណងរយៈពេលយូរអង្វែង អ្នកត្រូវតែកំណត់នូវពេលវេលាប្រាកដមួយសម្រាប់ខ្លួនឯងនៅក្នុងដំណើរស្វែងរកការងារនោះ៖ ឧទាហរណ៍ ដកឃ្លាសម្រាក ឬលំហែរប្រចាំសប្តាហ៍។ ម្យ៉ាងទៀត អ្នកគួរផ្តល់នូវរង្វាន់លើកទឹកចិត្តសាមញ្ញៗដល់ខ្លួនឯងនៅគ្រាដែលអ្នកបានបំពេញកិច្ច

តទៅទំព័របន្ទាប់

ការណាមួយស្របទៅតាមកាលកំណត់ក្នុងកាលវិភាគ។ ឧទាហរណ៍ នារីម្នាក់បានផ្តល់នូវរង្វាន់លើកទឹកចិត្តឱ្យទៅខ្លួនគាត់ ដោយការចេញទៅញ៉ាំបាយល្ងាចនៅក្នុងហាងមួយក្បែរផ្ទះ។ បុរសម្នាក់ទៀតបានឱ្យរង្វាន់លើកទឹកចិត្តដល់ខ្លួនគាត់ដោយការសម្រាកលេងកីឡាផ្សេងៗជាដើម។ អាស្រ័យហេតុនេះ សូមជ្រើសរើសនូវរង្វាន់លើកទឹកចិត្តណាមួយដែលអ្នកចូលចិត្តសម្រាប់ខ្លួនអ្នក ប៉ុន្តែត្រូវតែកំណត់ក្នុងចិត្តថា ទង្វើបែបនេះនឹងនាំឱ្យអ្នកទទួលបានលទ្ធផលមកវិញតាមរយៈការសម្រេចគោលដៅណាមួយដូចបានកំណត់ទុកក្នុងកាលវិភាគស្វែងរកការងារធ្វើ។






## តើអ្នកនឹងយកទីតាំងណាសំរាប់ធ្វើការពេលកំពុងស្វែងរកការងារ?

អ្នកត្រូវមានកន្លែង ឬបន្ទប់មួយនៅក្នុងផ្ទះដែលបានកំណត់ថាជា «**កន្លែងសំរាប់ធ្វើការ**» របស់អ្នក។ ប្រសិនអ្នកមានបន្ទប់រៀន ឬបន្ទប់ធ្វើការនៅក្នុងផ្ទះនោះគឺជាប្រការសំខាន់ណាស់ ព្រោះអ្នកអាចធ្វើការទីនោះបាន។ ប្រសិនបើមិនមានទេ អ្នកត្រូវតែកំណត់ទីតាំងមួយឱ្យច្បាស់ ទោះបីវាជាកន្លែង






តូចចង្អៀត ឬធំទូលាយក៏ដោយចុះ។ នៅពេលបានកំណត់ទីតាំងរួចហើយអ្នកអាចចំណាយពេលគ្រប់គ្រាន់ដើម្បីធ្វើកិច្ច-ការស្វែងរកការងារ។ ការរៀបចំបន្ទាប់មកទៀតគឺត្រៀមបំរុងសម្ភារប្រើប្រាស់ចាំបាច់ខ្លះៗដូចជា ប៊ិច ខ្មៅដៃ សៀវភៅកំណត់ហេតុជាដើម។ គួរចងចាំថាអំឡុងពេលធ្វើការងារនេះ អ្នកត្រូវហាមដាច់ខាតមិនឱ្យមានមនុស្សណាម្នាក់មកប៉ះពាល់ទីកន្លែងរបស់អ្នកនោះទេ ព្រោះវានាំមានការច្រឡំ ឬច្របូកច្របល់ដល់កិច្ចការ និងកំណត់ចំណាំផ្សេងៗរបស់អ្នក។

## តើអ្នកគួរប្រាប់មនុស្សដែលអ្នករស់នៅជាមួយគ្នាយ៉ាងម៉េច?

គឺជាប្រការសំខាន់ដែលអ្នកគួរតែប្រាប់មនុស្សរស់នៅជាមួយគ្នាអំពីកិច្ចការដែលអ្នកកំពុងតែបំពេញ គឺ «**ស្វែងរកការងារធ្វើ**»។ មានអ្នកស្វែងរកការងារជាច្រើននិយាយថា ដោយសារតែគេស្ថិតនៅក្នុងផ្ទះមិនសូវចេញទៅខាងក្រៅ ដូច្នេះតែងតែមានការរំខានពីអ្នកនៅជុំវិញខ្លួនដោយប្រការផ្សេងៗ។ ហេតុនេះ ការប្រាប់ឱ្យអ្នកនៅជុំវិញខ្លួនដឹងអំពីការងារស្រាវជ្រាវរបស់អ្នក គឺជាផ្នែកមួយជួយសម្រួលដល់ការងាររបស់អ្នកផងដែរ។ អំឡុងពេលស្វែងរកការងារ អាចជាបុព្វហេតុនាំឱ្យរាំង

តទៅទំព័របន្ទាប់

ស្ទះមួយដល់ទំនាក់ទំនងទូទៅរវាងមនុស្សក្នុងគ្រួសារ ដូចជាបងប្អូន ប្ដី ឬប្រពន្ធជាដើម។ ដូច្នេះអ្នកគួរតែផ្ដល់ព័ត៌មានជាចាំបាច់អំពីស្ថានភាពជាក់ស្ដែងដែលអ្នកកំពុងជួបប្រទះ និងគោលបំណងជាបន្តបន្ទាប់ដល់អ្នកទាំងនោះតាំងពីដំបូង។




## តើអ្នកណាខ្លះដែលអ្នកគួរមានទំនុកចិត្ត?

ចម្លើយយ៉ាងសាមញ្ញបំផុតគឺរូបអ្នកត្រូវតែមានទំនុកចិត្តចំពោះខ្លួនឯងជាចម្បង។ អ្នកស្វែងរកការងារខ្លះ ក៏បានស្វែងរកទំនុកចិត្តពីមិត្តភ័ក្ដិ ឬសហការីផងដែរ ដើម្បីឱ្យអ្នកទាំងនោះជួយផ្ដល់យោបល់ ឬការកែលំអលើចំណុចខ្វះខាតក្នុងដំណើរការរកការងារ។ អ្នកទាំងនោះមិនចាំបាច់ត្រូវតែជាអ្នកឯកទេសនោះទេ ប៉ុន្តែត្រូវតែជាមនុស្សដែលមានបំណងផ្ដល់នូវយោបល់ដោយស្មោះត្រង់អំពីការរីកចំរើននៃដំណើរការការងាររបស់អ្នក។ ម្យ៉ាងវិញទៀត អ្នកមិនត្រូវជ្រើសយកមនុស្សដែលជិតដិតជាមួយអ្នកពេកទេ ឧទាហរណ៍ ប្ដី ឬប្រពន្ធ និងក្រុមញាតិផ្សេងៗទៀត។ នៅពេលអ្នកអាចរកដៃគូពិភាក្សាបានហើយ បន្ទាប់មកត្រូវរៀបចំកាលវិភាគទៀងទាត់សម្រាប់តាមដានការវិវត្តនៃដំណើរការការងារ។ ប្រហែលជាការប្រសើរ ប្រសិនអ្នកអាចជួបនិយាយគ្នារៀងរាល់មួយអាទិត្យម្ដង នៅទីកន្លែងសមរម្យណាមួយក៏បាន ឧទាហរណ៍នៅក្នុងហាងកាហ្វេ ហាងបាយ ជាដើម។ អ្នកត្រូវប្រើប្រាស់ពេលវេលានោះសម្រាប់រំឭកអំពីកិច្ចការដែលបានបំពេញក្នុងរយៈពេលមួយអាទិត្យកន្លងមក ហើយទន្ទឹមនឹងនោះអ្នកត្រូវឆ្លៀតពេលពិភាក្សាផែនការសម្រាប់អាទិត្យក្រោយផងដែរ។




សូមលោកអ្នកដែលកំពុងតែស្វែងរកការងារធ្វើសាកល្បងអនុវត្តតាមបទពិសោធន៍ ឬសេចក្ដីណែនាំខាងលើដោយតម្រូវទៅតាមស្ថានភាព និងលក្ខខណ្ឌជាក់ស្ដែងរបស់ខ្លួន ដើម្បីឈានទៅទទួលបានការងារដែលកំពុងចង់បាន។ មិនមានការធានាថានឹងទទួលបានលទ្ធផលដូចក្ដីប៉ងអាស្រ័យដោយការប្រតិបត្តិតាមវិធីខាងលើនេះទេ ប៉ុន្តែសេចក្ដីដូចបានជម្រាបមកនេះគឺគ្រាន់តែជាគន្លឹះ និងការបង្ហាញផ្លូវខ្លះៗតែប៉ុណ្ណោះ ដោយហេតុថាការការស្វែងរក និងទទួលបានការងារពិតប្រាកដ តម្រូវឱ្យមានចំណេះ និងជំនាញ សេចក្ដីអំណត់ ការយល់ និងប្រមូលព័ត៌មានបានគ្រប់គ្រាន់ ឱកាសការងារ ព្រមទាំងការមានបណ្ដាញសង្គមទូលំទូលាយ ជាដើម។

ទោះជាយ៉ាងណាក្ដី យើងខ្ញុំសូមជូនពរឱ្យលោកអ្នកទទួលបានការងារមួយដ៏គាប់ប្រសើរបន្ទាប់ពីបានធ្វើការសម្រេចចិត្ត និងជ្រើសរើសតាមបែបបច្ចេកទេសនៃការស្វែងរកការងារធ្វើ៕



# ការរៀបចំខ្លួនសម្រាប់ចូលសម្ភាសន៍ការងារ

ការត្រៀមខ្លួនដើម្បីចូលទៅសម្ភាសន៍វាមិនមានអ្វីដែលត្រូវរៀបចំច្រើននោះឡើយ។ វាមិនមែនដូចជាការត្រៀមខ្លួនសម្រាប់ព្រឹត្តិការណ៍កីឡានោះទេ ប៉ុន្តែ អ្នកគួរគិតឱ្យបានល្អិតល្អន់ថាការរៀបចំនេះប្រៀបបានទៅនឹងការធ្វើវិនិយោគសម្រាប់អាជីពអនាគតរបស់អ្នកដូច្នោះដែរ។ គួរចងចាំពាក្យដែលតែងតែនិយាយថា «**ការបរាជ័យដោយមិនបានត្រៀមរៀបចំ បន្ទាប់មកត្រៀមរៀបចំសម្រាប់ការបរាជ័យ**»។ តើអ្នកគួរចាប់ផ្តើមត្រៀមរៀបចំនៅពេលណា? មានការរំពឹងទុកថា អ្នកបានរៀបចំខ្លះៗហើយពេលដែលអ្នកបានសម្រេចចិត្តដាក់ពាក្យសុំ ឬស្វែងរកការងារធ្វើ និងនៅពេលដែលអ្នកទទួលបានលិខិតអញ្ជើញឱ្យចូលខ្លួនទៅសម្ភាសន៍។ ដើម្បីត្រៀមរៀបចំឱ្យបានត្រឹមត្រូវ ក្នុងន័យថាអ្នកធ្វើការសិក្សាអំពីស្ថាប័ននោះ និងការវិភាគអំពីខ្លួនឯង អ្នកត្រូវតែកំណត់ពេលឱ្យគ្រប់គ្រាន់ដើម្បីផ្តោតការសិក្សាវិភាគ ព្រមទាំងជៀសវាងការរំខានផ្សេងៗ។ ប្រហែលជាសំណាងល្អមែនទែន ប្រសិនអ្នកចូលរួមសម្ភាសន៍ហើយទទួលជោគជ័យដោយមិនបានត្រៀមរៀបចំអ្វីសោះនោះ។ នៅក្នុងស្ថានភាពជាក់ស្តែងអ្នកត្រូវចងចាំថា អ្នកនឹងមិនមានឱកាសម្តងទៀត ឬពេលក្រោយសម្រាប់ការសម្ភាសន៍នោះទេ។ អ្នកត្រូវតែគ្រប់គ្រងឱ្យបាននូវឱកាស ហើយត្រៀមរៀបចំដើម្បីឆ្លើយនូវសំណួរដែលពិបាកៗ ហើយបរិយាយនៅក្នុងពាក្យពេចន៍សំខាន់ដែលចេញពីចិត្ត និងខ្លួនអ្នក។ វាមិនមែនជាពេលដែលអ្នកត្រូវលាក់លៀមសមត្ថភាព និងភាពឆ្លាតវៃរបស់អ្នកទៀតទេ។ ប៉ុន្តែ វាប្រៀបបានទៅនឹងការដែលអ្នកពពាយនាយលក់ឥវ៉ាន់ដូច្នោះដែរ គឺបានន័យថាអ្នកខិតខំយ៉ាងណាដើម្បីឱ្យលក់ដាច់ និងមានអ្នកទិញច្រើនចាប់អារម្មណ៍ជាមួយទំនិញរបស់អ្នក។ ត្រលប់មកវិញ គឺចង់ប្រៀបថាអ្នកបានលក់ពលកម្ម ចំណេះ ជំនាញ លទ្ធភាពការងារ ចាប់តាំងពីពេលដែលអ្នកបានដាក់ពាក្យស្វែងរកការងារ ដោយភ្ជាប់នូវប្រវត្តិរូបសង្ខេបរបស់អ្នកមកម៉្លេះ។

## ពេលវេលាជាមាសប្រាក់

មានពាក្យមួយឃ្លាតែងពោលទាក់ទងនឹងការទៅចូលសម្ភាសន៍ថា៖ «**ប្រសិនបើអ្នកមិនទៅដល់កន្លែងឱ្យបានមុនដប់នាទីទេ គឺមានន័យថាអ្នកនឹងប្រឈមនឹងការយឺតដប់នាទី**»។ ប្រសិនអ្នកទៅដល់លឿនពេកក៏អាចមានន័យថា៖ (ក) អ្នកមិនបានសិក្សាពីពេលវេលាធ្វើដំណើរ (ខ) អ្នកមិនសូវបានផ្តោតការយកចិត្តទុកដាក់ដល់កិច្ចការ (គ) អ្នកមិនមានជំនាញគ្រប់គ្រងពេលវេលាឱ្យបានល្អ។ ត្រូវតែយល់ដឹងអំពីបញ្ហាចរាចរ និងផ្លូវធ្វើដំណើរ ប្រសិនអ្នកប្រើមធ្យោបាយរថយន្តត្រូវតែកត់សម្គាល់ឱ្យច្បាស់ថាអ្នកមានពេលវេលាគ្រប់គ្រាន់ទៅដល់ក្រុមហ៊ុន ឬកន្លែងសម្ភាសន៍។



តទៅទំព័របន្ទាប់

ពេលចូលទៅសម្ភាសន៍ អ្នកត្រូវយកទៅជាមួយនូវឯកសារដើមនៃលិខិតអញ្ជើញពីក្រុមហ៊ុន ឬស្ថាប័នដែលហៅអ្នកទៅសម្ភាសន៍ (ប្រសិនបើមាន) ពីព្រោះនៅក្នុងលិខិតនោះនឹងមានលេខទូរសព្ទទាក់ទង ក្នុងករណីអ្នកចង់ទំនាក់ទំនងជាមុនទៅស្ថាប័នដើម្បីជំរាបពីការយឺតយ៉ាវ ឬក្នុងករណីមានកើតហេតុបន្ទាន់ផ្សេងៗ។ ដូច្នេះត្រូវត្រៀមថាអ្នកនឹងមានមធ្យោបាយអ្វីដែលអាចទំនាក់ទំនងបាន ដូចជាទូរសព្ទផ្ទាល់ខ្លួន ឬទូរសព្ទសាធារណៈ ឬវិធីផ្សេងៗទៀត។ ការទៅដល់លឿនមុនដប់នាទីជាប្រការល្អ គឺក្នុងករណីអ្នកសម្ភាសន៍មិនទាន់បានរៀបចំស្រេចបាច់នូវឯកសាររបស់គេ អញ្ចឹងពេលចាប់ផ្ដើមអ្នកនឹងក្លាយជាមនុស្សទី១ដែលចូលសម្ភាសន៍មុនគេ។

## តើគួរស្លៀកពាក់ដូចម្ដេច?

ឥឡូវនេះ ពេលវេលាសម្រាប់ការសម្ភាសន៍នឹងឈានកមដល់ឆាប់ៗខាងមុខ អ្នកប្រាកដជាមានសំណួរថា តើគួររៀបចំខ្លួនជាមួយសំលៀកបំពាក់ប្រភេទដូម្ដេច? តើអ្នកគួរតែងខ្លួនបែបផ្លូវការ ឬក៏តែងខ្លួនតាមរបៀបដែលអ្នកចូលចិត្ត? តើគួរតែពាក់គ្រឿងអលង្ការដែរឬទេ? ជាទូទៅ ការស្លៀកពាក់សម្រាប់ការចូលសម្ភាសន៍ គឺជាប្រការសំខាន់ដែលត្រូវយល់ដឹង។ អ្នកខ្វះមានការយល់ខុសចំពោះចំណុចនេះ។ ចម្លើយទៅនឹងសំណួរទាំងនោះគឺសាមញ្ញបំផុត។ ជាតុពិត ការសម្ភាសន៍ការងារ គឺជាការប្រជុំបែបផ្លូវការរវាងមនុស្សដែលនឹងត្រូវស្វែងយល់ពីសមត្ថភាព និងភាពសមស្របរបស់គ្នាទៅវិញទៅមក ដើម្បីបំពេញការងារជាអាជីពជាមួយគ្នា ហើយអាចនឹងឈានទៅដល់ការចុះកិច្ចសន្យាការងារតាមផ្លូវច្បាប់រវាងនិយោជក និងនិយោជិត។ ហេតុដូច្នេះ អ្នកត្រូវរៀបចំដោយប្រុងប្រយត្ន័នូវចំណុចដែលសំខាន់ៗទាំងឡាយ ដើម្បីជាការទាក់ទាញ និងបង្ហាញឱ្យឃើញថាអ្នកជាមនុស្សមានការទទួលខុសត្រូវ និងជាធនធានដ៏ចាំបាច់មួយសម្រាប់ការងារ។ ត្រង់ចំណុចនេះមានន័យថា ការស្លៀកពាក់បែបធម្មតា ឧទាហរណ៍ ខោខូវប៊ិយ អាវយឺត គឺមិនអាចទទួលយកបានទេ។ គឺចង់បញ្ជាក់ថាការស្លៀកពាក់ត្រូវឱ្យសមរម្យដោយមិនប្រកាន់លើប្រភេទនៃការងារ។ ឧទាហរណ៍៖ ទោះបីជាអ្នកនឹងសម្ភាសចូលធ្វើការនៅក្នុងមជ្ឈមណ្ឌលទទួលការហៅទូរសព្ទចូល (Call center) ដែលមិនមានការទាក់ទងជាមួយមនុស្សម្នាខាងក្រៅក្ដី វានឹងមានសភាពសំខាន់ខុសប្លែកគ្នាពីអ្នកដទៃ ប្រសិនអ្នកបានស្លៀកពាក់បែបផ្លូវការពេលចូលសម្ភាសន៍។ ចំណុចសំខាន់មួយដែលក្រុមជនធ្វើការផ្នែកជ្រើសរើសបុគ្គលិក និងផ្នែកធនធានមនុស្សប្រាថ្នាចង់បានគឺថា ពេលបេក្ខជនចូលសម្ភាសន៍ គេគួរស្លៀកពាក់ឱ្យបានស្អាតបាទ ហាក់បីដូចគេចូលសម្ភាសន៍ក្នុងមុខតំណែងខ្ពស់ជាងមួយកម្រិត បើប្រៀបធៀបនឹងមុខតំណែងដែលគេកំពុងដាក់ពាក្យស្នើសុំការងារ។ ការស្លៀកពាក់បានស្អាតល្អនាពេលចូលសម្ភាសន៍ នឹងបង្កឱ្យមានការចាប់អារម្មណ៍ចំពោះការរៀបចំខ្លួនរបស់អ្នក និងបន្សល់ទុកនូវចំណុចល្អៗសម្រាប់ជាការពិចារណាថាអ្នកជាមនុស្សស័ក្តិសមដើម្បីបំពេញការងារ។ ខាងក្រោមនេះជាចំណុចសំខាន់ៗមួយចំនួនដែលបេក្ខជនចូលទៅសម្ភាសន៍គួរជៀសវាង ឬប្រុងប្រយ័ត្នចំពោះសំលៀកបំពាក់របស់ខ្លួន។





តទៅទំព័របន្ទាប់

## ប្រការគួរជៀសវាងចំពោះនារី

- កុំពាក់គ្រឿងអលង្ការច្រើនពេក (ត្រូវដោះចេញឱ្យអស់រាល់ក្រវិលដែលចោះពាក់តាមកន្លែងផ្សេងៗ)
- កុំស្លៀកពាក់សំលៀកបំពាក់ពណ៌ឆើតពេក
- កុំប្រើថ្នាំលាបក្រចកពណ៌ឆើតពេក
- កុំផ្ញើស ឬខាំក្រចកពេលសម្ភាសន៍
- កុំស្លៀកសំពត់ខ្លីពេក ឬខោអាវដែលរឹបរឹតរាងខ្លាំងពេក
- កុំប្រើគ្រឿងអលង្ការដែលមានពណ៌ឆើត ឬមានលំអច្រើនពេក
- កុំពាក់ស្បែកជើងដែលមិនសមរម្យ (ឧទាហរណ៍៖ កែងវែងពេក)
- កុំពាក់អាវដែលអត់មានក
- កុំបាញ់ទឹកអប់ដែលមានក្លិនឆួលខ្លាំងពេក







## ប្រការគួរជៀសវាងចំពោះបុរស

- កុំពាក់អាវធំពណ៌ស្រាល ឬពណ៌ឆើត
- កុំលាត់ដៃអាវឡើងលើ
- កុំបង្ហាញកន្លែងដែលមានសាក់លើខ្លួន
- កុំកោរពុកមាត់ និងពុកចង្កាមិនបានស្អាតល្អ
- កុំពាក់ស្បែកជើងពណ៌ឆើត
- កុំពាក់ស្រោមជើងពណ៌ស ជាមួយសំលៀកបំពាក់ពណ៌ផ្សេងៗ
- កុំពាក់ស្បែកជើងផ្ទាត់

ចំណុចទាំងអម្បាលដែលបានពោលមកនេះ គឺចង់បង្ហាញថាអ្នកពិតជាយកចិត្តទុកដាក់ចំពោះការងារ ហើយអ្វីដែលអ្នកបារម្ភគឺអាកប្បកិរិយាផ្ទាល់ខ្លួនរបស់អ្នកៗ ទាំងអស់នេះនឹងក្លាយជាការឃោសនាបង្ហាញអំពីរូបអ្នក ក៏ដូចជាសមត្ថភាពរបស់អ្នកទៅដល់អ្នកជ្រើសរើសការងារដែលមានបំណងចង់បានមនុស្សដែលសមស្របជាមួយការងាររបស់ពួកគេៗ ខាងក្រោមនេះជាចំណុចដែលអ្នកគួរចង់ចាំពេលស្លៀកពាក់ចូលទៅសម្ភាសន៍ការងារ៖

## បុរសគួរស្លៀកពាក់

- អាវពណ៌ស (លាត ឬឆ្នូត)
- ក្រវ៉ាត់ក (ម៉ូតដែលមានផ្កាល្អិតៗ ឬក្បាច់លំអតូចៗ)
- អាវធំ (បើមានជាការប្រសើរ)

## នារីគួរស្លៀកពាក់

- អាវឈុតបែបការងារក្នុងការិយាល័យ (ប្រសិនបើអាច)
- អាវធំ សំពត់ ឬខោដែលមានសភាពរម្យទមដោយមិនរឹបរាងខ្លាំង ឬខើចលើ ខើចក្រោម

## ប្រការខ្លះៗទៀតដែលគួរជៀសវាង និងចងចាំ

- កុំបរិភោគខ្ទឹមស ឬប្រភេទខ្ទឹមផ្សេងៗក្នុងអំឡុងពេល៤៨ម៉ោងមុនការសម្ភាសន៍
- កុំជក់បារីរយៈពេល១ម៉ោងមុនការសម្ភាសន៍ (ប្រសិនបើជក់ សូមលាងដៃ និងខ្ពុរមាត់ឱ្យបានស្អាតជាមុន)
- កុំទំពារស្ករកៅស៊ូឱ្យសោះនាខណៈពេលកំពុងសម្ភាសន៍





## តើអ្វីខ្លះដែលអ្នកគួរយកទៅជាមួយ?

នៅក្នុងចំណុចនេះគឺអាស្រ័យទៅលើតួនាទីក្នុងការងារដែលអ្នកបានដាក់ពាក្យសុំ។ ប្រហែលអ្នកនឹងត្រូវធ្វើបទបង្ហាញផ្សេងៗពីសមត្ថភាព ឬជំនាញរបស់អ្នកផងក៏មិនដឹង។ ជាការល្អអ្នកគួរយកទៅជាមួយនូវប្រវត្តិរូបសង្ខេបមួយច្បាប់ បង្ការក្រែងអ្នកត្រូវការមើល ឬយោងទៅលើខ្លឹមសារខ្លះៗដែលអ្នកមិនបានចាំ។ មានអ្នកខ្លះប្រឈមនឹងការលំបាកដោយនិយោជក ឬអ្នកសម្ភាសន៍តម្រូវឱ្យនិយាយពីចំណុចមួយចំនួននៅក្នុងប្រវត្តិរូប ដោយថាហេតុគេមានការភិតភ័យ ឬគ្រប់គ្រងឥរិយាបថមិនបានល្អអាស្រ័យដោយគេមិនបានចាំនូវរាល់សេចក្តីទាំងអស់នោះ។ ប្រសិនបើមានហេតុការណ៍បែបនេះកើតឡើង ហើយអ្នកមិនអាចឆ្លើយសំណួរដែលបានចោទសួរ នោះនឹងបង្ហាញថាអ្នកជាមនុស្សមិនមានការប្រុងប្រយ័ត្នចំពោះពាក្យពេចន៍ ឬខ្លឹមសារក្នុងប្រវត្តិរូបដែលអ្នកបានសរសេរ។ ជាងនេះទៀតអ្នកសម្ភាសន៍អាចនឹងកាត់យល់ថាអ្នកជាមនុស្សមិនអាចទុកចិត្តបាន អាស្រ័យដោយការឆ្លើយសំណួរ ឬបកស្រាយសេចក្តីមិនបានច្បាស់លាស់ដូចអ្វីដែលបានសរសេរ។

ម៉្យាងទៀតចំពោះអ្នកដែលធ្លាប់ធ្វើការពីមុន គេអាចនាំយកទៅជាមួយនូវរាល់ឯកសារចម្លងអំពីស្នាដៃ ឬសមិទ្ធិផលការងារដែលបានបំពេញនាពេលកន្លងមក ដើម្បីបង្ហាញជូនដល់ក្រុមអ្នកសម្ភាសន៍។ ក្រៅពីនេះអ្នកអាចយកប៊ិច និងសៀវភៅកំណត់ត្រាទៅជាមួយ ករណីអ្នកត្រូវការកត់ចំណាំចំណុចផ្សេងៗដែលបានចោទសួរ ប៉ុន្តែត្រូវសុំការអនុញ្ញាតជាមុនថាតើអ្នកអាចកត់ត្រាអ្វីផ្សេងៗបានដែរឬទេ?

## នៅកន្លែង ឬបន្ទប់រង់ចាំ

ពេលនៅក្នុងបន្ទប់ ឬកន្លែងរង់ចាំសូមរក្សាភាពស្ងៀមស្ងាត់ មានភាពអោនលំទោននិងចេះគួរសមទៅកាន់បុគ្គលិកដែលនាំផ្លូវ ឬបុគ្គលិកដទៃទៀតដែលអ្នកបានជួបក្នុងពេលនោះ។ ត្រូវចេះពិនិត្យពិច័យដោយការមើល និងការស្តាប់ក្នុងស្ថានភាពនោះ។ ធម្មតានៅក្នុងបន្ទប់អាចមានប្រកាស ឬព័ត៌មានផ្សេងៗរបស់ក្រុមហ៊ុនដែលអ្នកមិនបានដឹងពីមុនមក។ ដូច្នេះសូមពិនិត្យមើលក្រែងមានរបស់ទាំងនោះដែលអ្នកអាចអាន ឬស្វែងយល់បន្ថែមពីក្រុមហ៊ុន ឬស្ថាប័ននោះ ម្យ៉ាងទៀតព័ត៌មានបែបនោះអាចជួយបង្កើនចំណេះដឹងទូទៅមួយកម្រិតទៀតពេលអ្នកចូលទៅសម្ភាសន៍។

អង្គុយក្នុងឥរិយាបថសមរម្យ ដោយដងខ្លួនត្រង់ និងមិនរំខានអ្នកក្បែរខាង។ ប្រសិនអ្នកអង្គុយមិនបានសមរម្យបែបទំរេត ឬផ្តេកខ្លួនលើកៅអីសាឡុង នៅពេលអ្នកនាំផ្លូវហៅឈ្មោះអ្នកចូលទៅកាន់កន្លែងសម្ភាសន៍បានឥរិយាបថបែបនេះ វាអាចនឹងបង្ហាញនូវរូបភាពមិនល្អ ក៏ដូចជាការវាយតម្លៃទាបចំពោះរូបអ្នក។ ដូច្នេះចូរអ្នកគិតថា អ្នកកំពុងស្ថិតនៅក្នុងស្ថានភាពនៃការធ្វើសម្ភាសន៍ចាប់តាំងពីពេលអ្នកបានឈានជើងចូលទៅក្នុងអគារ ឬទីកន្លែងសម្ភាសន៍មកម្ល៉េះ។



**សូមរង់ចាំអានបន្តនៅក្នុងការផ្សាយលេខក្រោយ ស្តីពីប្រភេទនៃសំណួរក្នុងពេលសម្ភាសន៍**

---

*អត្ថបទដកស្រង់ចេញពីឯកសារឈ្មោះ Charlie Gibbs, 2009. How To Answer Hard Interview Questions and everything else you need to know to get the job you want. 2nd Edition.  ប្រែសម្រួលដោយ **ហៃ ហ៊ុនឡេង**។*



លិខិតបទដ្ឋានគតិយុត្ត

# កិច្ចសន្យាការងារ

ចាប់តាំងពីទីភ្នាក់ងារជាតិមុខរបរ និងការងារ បានបោះផ្សាយព្រឹត្តិបត្រការងារកន្លងមក ក្រុមការីនិពន្ធលើ ប្រធានបទស្តីពីលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការងារ បានខិតខំប្រឹងប្រែងធ្វើការជ្រើសរើសប្រធានបទមួយចំនួនដែលមានសារៈសំខាន់សម្រាប់និយោជក និយោជិត និងបុគ្គលទាំងឡាយដែលកំពុងស្វែងរកការងារនៅក្នុង វិស័យឯកជន និងកំពុងដំណើរការអាជីវកម្មរបស់ខ្លួន ហើយមានបំណងជួលកម្មករនិយោជិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដូចជា *កាតព្វកិច្ចនិយោជក ការជ្រើសរើសកម្មករនិយោជិតឱ្យចូលធ្វើការ*។ ហេតុដូច្នេះ ដើម្បីគ្រប់គ្រងទំនាក់ទំនង និងការពារផលប្រយោជន៍របស់កម្មករនិយោជិត និងនិយោជក ចាំបាច់ភាគីទាំងពីរត្រូវតែរៀបចំបង្កើតឱ្យមាន *«កិច្ចសន្យាការងារ»* មួយ។ កិច្ចសន្យានេះ គឺហាក់បីដូចជាច្បាប់របស់ភាគីទាំងសងខាង។ ហេតុដូច្នេះ នៅក្នុងព្រឹត្តិបត្រលេខនេះ យើងនឹងផ្តោតអារម្មណ៍លើតម្រូវការតាមផ្លូវច្បាប់ចំពោះកិច្ចសន្យាការងារ និងការបែងចែកប្រភេទនៃកិច្ចសន្យាការងារទៅតាមច្បាប់ស្តីពីការងារ។




នៅក្នុងនីតិការងារ កិច្ចសន្យាការងារ និងអនុសញ្ញារួមគឺជាឯកសារដ៏មានសារៈសំខាន់ដើម្បីគ្រប់គ្រង ទំនាក់ទំនងការងាររវាងនិយោជក និងកម្មករនិយោជិត។ ម្យ៉ាងទៀតយើងអាច សន្និដ្ឋានថា កិច្ចសន្យាការងារគឺជា កិច្ចព្រមព្រៀងមួយដែលបុគ្គលម្នាក់ ហៅថា *«កម្មករនិយោជិត»* យល់ព្រមធ្វើការ ឬផ្តល់សេវាសម្រាប់រយៈពេលណាមួយដើម្បីទទួលប្រាក់ឈ្នួលពីបុគ្គលម្នាក់ទៀត ឬក្រុមហ៊ុន ហៅថា «និយោជក» នៅក្នុងប្រទេសកម្ពុជា។

ដោយអនុលោមតាមច្បាប់ស្តីពីការងារ កិច្ចសន្យាការងារនៃនីតិឯកជន មិនអនុវត្តចំពោះអ្នកបម្រើក្នុងផ្ទះ បុគ្គលិកទាំងអស់ ដែលស្ថិតនៅក្រោមលក្ខន្តិកៈអ្នករាជការ (ដែលមានដូចជា មន្ត្រីរាជការ ចៅក្រម មន្ត្រីនគរបាល យោធា និងកងរាជអាវុធ) ឬលក្ខន្តិកៈអ្នកការទូត។ ផ្អែកតាមច្បាប់ស្តីពីការងារ កិច្ចសន្យាការងារអាចធ្វើជាលាយលក្ខណ៍អក្សរ ឬធ្វើដោយផ្ទាល់មាត់។ ដូច្នេះ កិច្ចសន្យាការងារដែលធ្វើឡើងដោយផ្ទាល់មាត់ ត្រូវទុកដូចជាមានការព្រមព្រៀងរវាង និយោជក និងកម្មករនិយោជិត តាមលក្ខខណ្ឌដែលមានចែងក្នុងបទបញ្ញាការងារ ទោះបីមិនបានបញ្ជាក់ច្បាស់លាស់ក៏ដោយ។ [១]




ផ្អែកតាមមាត្រា៦៦ នៃច្បាប់ស្តីពីការងារ កិច្ចសន្យាការងារត្រូវបានចែកជាពីរប្រភេទគឺ ***កិច្ចសន្យាការងារ ដែលមានថិរវេលាកំណត់ និងកិច្ចសន្យាការងារដែលមានថិរវេលាមិនកំណត់***។ កិច្ចសន្យាដែលមានថិរវេលាកំណត់ គឺជាកិច្ចសន្យាដែលធ្វើឡើងដោយការព្រមព្រៀងគ្នាមានកំណត់អំពីកាល-

(១) មាត្រា ៦៥ នៃច្បាប់ស្តីពីការងារ

*អត្ថបទរៀបចំដោយ លោក សុខុន ដាវីដ (អនុប្រធានផ្នែកប្រមូល និងផ្សព្វផ្សាយ នៃទីភ្នាក់ងារជាតិមុខរបរ និងការងារ*

តទៅទំព័របន្ទាប់

បរិច្ឆេទច្បាស់លាស់នៃការចាប់ផ្តើម និង ការបញ្ចប់កិច្ចសន្យានោះ។ ផ្ទុយមកវិញ កិច្ចសន្យាការងារដែលមានថិរវេលាមិនកំណត់ គឺជាកិច្ចសន្យាដែលធ្វើឡើងដោយការព្រមព្រៀងគ្នាមិនកំណត់ថាចប់នៅពេលណា ហើយម្យ៉ាងទៀត កិច្ចសន្យាប្រភេទនេះ ភាគច្រើនគឺជាកិច្ចសន្យាដែលធ្វើឡើងដោយផ្ទាល់មាត់។



បន្ថែមលើនេះ រយៈពេលនៃការអនុវត្តកិច្ចសន្យាការងារដែលមានថិរវេលាកំណត់ មិនអាចមានរយៈពេលលើស ពីពីរឆ្នាំបានឡើយ ប៉ុន្តែកិច្ចសន្យានេះអាចបន្តសារជាថ្មីម្តង ឬច្រើនដងបាន ដ៏រាបណា ការបន្តសារជាថ្មីនោះមាន ថិរវេលាអតិបរិមាមិនលើសពី ២ឆ្នាំ។ កិច្ចសន្យាការងារដែលមានកំណត់ថិរវេលាមានរយៈពេលតិចជាង ឬស្មើនឹងពីរឆ្នាំ ហើយត្រូវធ្វើបន្តដោយស្ងៀមស្ងាត់នៅពេលផុតកំណត់ក្នុងកាលៈទេសៈណាមួយ កិច្ចសន្យានោះត្រូវចាត់ទុកជាកិច្ច សន្យាគ្មានកំណត់ថិរវេលាពិតប្រាកដ។

ចំពោះការចុះកិច្ចសន្យាការងារធ្វើការសាកល្បងដើម្បីឱ្យនិយោជកវិនិច្ឆ័យវិជ្ជាជីវៈនៃកម្មករនិយោជិត ថិរវេលានៃកិច្ចសន្យាប្រភេទនេះមិនអាចមានលើសពីបីខែទេចំពោះនិយោជិត ២ខែចំពោះកម្មករឯកទេស និង១ខែ ចំពោះកម្មករធម្មតា។ នៅក្នុងរយៈពេលនៃការធ្វើការសាកល្បង សោហ៊ុយទៅមកសម្រាប់កម្មករនិយោជិត ដែលត្រូវទៅធ្វើការឆ្ងាយពីលំនៅដ្ឋាន ត្រូវស្ថិតនៅក្នុងបន្ទុករបស់និយោជក។(២)

គោលដៅនៃកិច្ចសន្យាការងាររវាងកម្មករនិយោជិតនិងនិយោជក គឺផ្តោតសំខាន់ទៅលើលទ្ធផលនៃការងារ ហេតុដូច្នេះ កម្មករនិយោជិតត្រូវបញ្ចេញគ្រប់សកម្មភាពវិជ្ជាជីវៈរបស់ខ្លួនដល់សហគ្រាស។

ដើម្បីឱ្យកិច្ចសន្យាការងារមួយមានសុពល និងផ្តល់នូវការការពារផលប្រយោជន៍របស់ភាគីទាំងសងខាង កិច្ចសន្យាការងារត្រូវបញ្ជាក់ពីលក្ខខណ្ឌផ្សេងៗ រួមមាន៖

- លក្ខខណ្ឌទទួលយកកម្មករនិយោជិតឱ្យចូលធ្វើការ ហ្វឹកហ្វឺនកូនជាង និងការសាកល្បងការងារ
- ភារកិច្ចការងារអ្វីខ្លះដែលត្រូវបំពេញនៅក្នុងថ្ងៃធ្វើការ និងថ្ងៃឈប់សម្រាកបុណ្យ
- ការពិនិត្យសុខភាព
- ម៉ោងធ្វើការ ការឈប់សម្រាកប្រចាំសប្តាហ៍ ការឈប់សម្រាកក្នុងថ្ងៃបុណ្យសាធារណៈ ការឈប់សម្រាកពេលមានជំងឺ
- ប្រាក់ឈ្នួល ប្រាក់រង្វាន់ និងផលប្រយោជន៍ផ្សេងៗទៀត
- អវត្តមានរបស់កម្មករនិយោជិត
- ការប្រើប្រាស់សម្ភារ និងឧបករណ៍ផ្សេងៗរបស់សហគ្រាសក្នុងពេលបំពេញការងារ
- ការប្រើប្រាស់អាគារ ឬមូលដ្ឋានរបស់សហគ្រាស
- ការចេញចូលសហគ្រាស
- ទោសវិន័យនានា បើសិនជាកម្មករនិយោជិតរំលោភបញ្ញាផ្ទៃក្នុង ឬមានកំហុស
- សិទ្ធិការពារខ្លួនរបស់កម្មករនិយោជិតមុនពេលត្រូវទទួលទោសវិន័យ
- អនាម័យ និងសន្តិសុខការងារ ។

(២) មាត្រា ៦៨ នៃច្បាប់ស្តីពីការងារ

**សូមរង់ចាំអានក្នុងការផ្សាយលេខក្រោយ**

**ស្តីពីការបង្កើត និងការបញ្ចប់កិច្ចសន្យាការងារ**



# ព័ត៌មានទីផ្សារការងារនៅកម្ពុជា

## ទិន្នន័យសង្ខេបសំខាន់ៗស្តីពីចំនួនសិស្សដែលបានប្រលងជាប់ មធ្យមសិក្សាទុតិយភូមិ និងនិស្សិតដែលបានសិក្សានៅគ្រឹះស្ថានឧត្តមសិក្សា

នៅក្នុងការផ្សាយលេខមុនៗនៃព្រឹត្តិបត្រការងារ បានលើកយកនូវទិន្នន័យស្តីពីអ្នកស្វែងរកការងារធ្វើ និងព័ត៌មានជ្រើសរើសបុគ្គលិក ដែលបានប្រមូលដោយទីភ្នាក់ងារជាតិមុខរបរ និងការងារ (ទ.ជ.ម.ក)។ បន្ថែមលើទិន្នន័យនេះ នៅក្នុងលេខនេះ យើងសូមលើកយកទិន្នន័យសំខាន់មួយទៀតមកធ្វើការបង្ហាញជូនដល់សិស្ស និស្សិត អ្នកស្វែងរកការងារធ្វើ និយោជក និងអ្នកផ្តល់ការអប់រំបណ្តុះបណ្តាល ក៏ដូចជាសាធារណជនទាំងអស់បានជ្រាប ពោលគឺ «ទិន្នន័យស្តីអំពីចំនួនសិស្សដែលបានប្រលកជាប់មធ្យមសិក្សាទុតិយភូមិ និងចំនួននិស្សិតដែលបានចុះឈ្មោះសិក្សានៅតាមគ្រឹះស្ថានឧត្តមសិក្សានៅក្នុងប្រទេសកម្ពុជា។»

### ១. ចំនួន និងសន្ទស្សន៍នៃចំនួនសិស្សដែលបានប្រលងជាប់មធ្យមសិក្សាទុតិយភូមិ

តារាងទី១ បង្ហាញថាចំនួនសិស្សសរុបដែលបានប្រលងជាប់មធ្យមសិក្សាទុតិយភូមិ បានកើនឡើងជាប្រចាំចាប់ពី ១៤.៣៦០នាក់ក្នុងឆ្នាំ ២០០៣ ដល់ ៥៩.២៩២នាក់ ក្នុងឆ្នាំ២០០៩ លើកលែងតែឆ្នាំ២០០៧ ដែលបានថយចុះបន្តិចពី ៤១.៨៧២ នាក់ទៅ ៣៩.៧២៦នាក់។ ទន្ទឹមនឹងការកើនឡើងនៃចំនួនសិស្សសរុបដែលបានប្រលងជាប់មធ្យមសិក្សាទុតិយភូមិនេះ យើងឃើញថាក៏មានការគួរឱ្យចាប់អារម្មណ៍ផងដែរ ចំពោះកំណើនសិស្សនារីដែលបានប្រលងជាប់សញ្ញាបត្រនេះក៏មានការកើនឡើងស្របគ្នាផងដែរ ពោលគឺពី ៤.៨៦៨នាក់ ក្នុងឆ្នាំ ២០០៣ ទៅ២៥.៨៦៩នាក់ ក្នុងឆ្នាំ២០០៩។ បើពិនិត្យមើលទៅលើសន្ទស្សន៍នៃចំនួនវិញ ឃើញថា ក្នុងរយៈពេល ៦ឆ្នាំនេះ ចំនួនសិស្សសរុបដែលបានប្រលងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិបានកើនឡើងជាងបីដង ចំនែកចំនួនសិស្សនារីវិញបានកើនឡើងរហូតដល់ជាងបួនដង ដែលធ្វើឱ្យសមាមាត្រនៃសិស្សនារីដែលបានប្រលងជាប់សញ្ញាបត្រនេះមានការកើនឡើង ដែលនេះស្តែងឱ្យឃើញពីជំរុញឱ្យសមភាពយ៉េនឌ័ និងការរីកចម្រើនខាងសមត្ថភាពរបស់សិស្សនារី។

តារាងទី១ ចំនួន និងសន្ទស្សន៍ចំនួនសិស្សដែលបានប្រលងជាប់សញ្ញាបត្រមធ្យសិក្សាទុតិយភូមិ

| ឆ្នាំសិក្សា | សិស្សប្រលងជាប់មធ្យមសិក្សាទុតិយភូមិ | | | |
|---|---|---|---|---|
| | សរុប | សន្ទស្សន៍ | ចំនួនសិស្សស្រី | សន្ទស្សន៍ |
| 2002-2003 | 14360 | 100.0 | 4868 | 100.0 |
| 2003-2004 | 18883 | 131.5 | 7155 | 147.0 |
| 2004-2005 | 33423 | 232.8 | 13290 | 273.0 |
| 2005-2006 | 41872 | 291.6 | 16698 | 343.0 |
| 2006-2007 | 39726 | 276.6 | 16748 | 344.0 |
| 2007-2008 | 51565 | 359.1 | 22394 | 460.0 |
| 2008-2009 | 59292 | 412.9 | 25869 | 531.4 |

តទៅទំព័របន្ទាប់

## ២. ចំនួននិស្សិតដែលបានចុះឈ្មោះចូលរៀនឆ្នាំទីមួយនៅតាមគ្រឹះស្ថានឧត្តមសិក្សា

ប្រហាក់ប្រហែលគ្នាទៅនឹងចំនួនសិស្សដែលបានប្រលងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិដែរ តារាងទី២ ទី៣ និងរូបទី១ បង្ហាញថាចំនួននិស្សិតដែលបានចុះឈ្មោះនៅថ្នាក់បរិញ្ញាបត្រឆ្នាំទី១ បានកើនឡើងជាប្រចាំចាប់ពី ១៣.៧១៥នាក់ ក្នុងឆ្នាំ២០០៣ រហូតដល់ ៤៩.៤៥៧នាក់ ក្នុងឆ្នាំ២០០៩។ ជាមួយគ្នានេះផងដែរ ចំនួននិស្សិតដែលបានចូលរៀនថ្នាក់បរិញ្ញាបត្ររង ក៏មានការកើនឡើងជាប្រចាំផងដែរពី ៧.៧៣៥នាក់ក្នុង ឆ្នាំ២០០៦ រហូតដល់ ៩.៨៩៤នាក់ ក្នុងឆ្នាំ២០០៨ និងធ្លាក់ចុះវិញបន្តិចមកនៅត្រឹម ៩.៥៥២នាក់ ក្នុងឆ្នាំ ២០០៩។ បន្ថែមលើនេះ រូបទី២ បង្ហាញកាន់តែច្បាស់ថែមទៀតថា ចំនួនសិស្សដែលបប្រលងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ និងចំនួននិស្សិតដែលចុះឈ្មោះចូលរៀនថ្នាក់បរិញ្ញាបត្រឆ្នាំទី១មាននិន្នាការកើនឡើងព្រមគ្នាពីឆ្នាំ២០០៣ ដល់ឆ្នាំ ២០០៩។ បើពិនិត្យមើលទៅលើសន្ទស្សន៍នៃចំនួនវិញ ឃើញថាចំនួននិស្សិតដែលចុះឈ្មោះចូលរៀនថ្នាក់បរិញ្ញាបត្របានកើនឡើងជាង ២,៦ដង ក្នុងរយៈពេល៦ឆ្នាំ ក្នុងនោះនិស្សិតនារីបានកើនឡើងរហូតដល់ជាង ៣,៤ដង។ ដែលនេះក៏ជាសូចនាករមួយ ដែលបង្ហាញពីសមភាពយេនឌ័ និងការពង្រីកសមត្ថភាព និងចំណេះដឹងរបស់នារីនៅក្នុងសង្គម។

តារាងទី២ ចំនួន និងសន្ទស្សន៍ចំនួននិស្សិតដែលបានចុះឈ្មោះចូលរៀនថ្នាក់បរិញ្ញាបត្រឆ្នាំទី១

| ឆ្នាំសិក្សា | សិស្សចុះឈ្មោះចូលរៀនថ្នាក់បរិញ្ញាបត្រឆ្នាំទី១ | | | |
|---|---|---|---|---|
| | សរុប | សន្ទស្សន៍ | ចំនួនសិស្សស្រី | សន្ទស្សន៍ |
| 2003-2004 | 13715 | 100.0 | 4525 | 100.0 |
| 2004-2005 | 19315 | 140.8 | 6241 | 137.9 |
| 2005-2006 | 29659 | 216.3 | 10283 | 227.2 |
| 2006-2007 | 34783 | 253.6 | 12945 | 286.1 |
| 2007-2008 | 39305 | 286.6 | 15043 | 332.4 |
| 2008-2009 | 45650 | 332.8 | 18417 | 407.0 |
| 2009-2010 | 49457 | 360.6 | 20003 | 442.1 |

រូបទី១ អត្រាកំណើនចំនួននិស្សិតចុះឈ្មោះចូលរៀនថ្នាក់បរិញ្ញាបត្រឆ្នាំទី១





តទៅទំព័របន្ទាប់...

## រូបទី២ ចំនួនសិស្សដែលបានប្រលងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ និងនិស្សិតដែលបានចុះឈ្មោះចូលរៀនថ្នាក់បរិញ្ញាបត្រឆ្នាំទី១




| | 2003-2004 | 2004-2005 | 2005-2006 | 2006-2007 | 2007-2008 | 2008-2009 | 2009-2010 |
|---|---|---|---|---|---|---|---|
| ចំនួនសិស្សប្រលងជាប់មធ្យមសិក្សាទុតិយភូមិ | 14360 | 18883 | 33423 | 41872 | 39726 | 51565 | 59292 |
| និស្សិតចុះឈ្មោះចូលរៀនថ្នាក់បរិញ្ញាបត្រឆ្នាំទី១ | 13715 | 19315 | 29659 | 34783 | 39305 | 45650 | 49457 |

### តារាងទី៣ ចំនួន និងសន្ទស្សន៍ចំនួននិស្សិតដែលបានចុះឈ្មោះចូលរៀនថ្នាក់បរិញ្ញាបត្ររងឆ្នាំទី១

| ឆ្នាំសិក្សា | សិស្សចុះឈ្មោះចូលរៀនថ្នាក់បរិញ្ញាបត្ររងឆ្នាំទី១ | | | |
|---|---|---|---|---|
| | សរុប | សន្ទស្សន៍ | ចំនួនសិស្សស្រី | សន្ទស្សន៍ |
| 2006-2007 | 7735 | 100.0 | 2380 | 100.0 |
| 2007-2008 | 8227 | 106.4 | 2322 | 97.6 |
| 2008-2009 | 9894 | 127.9 | 2949 | 123.9 |
| 2009-2010 | 9552 | 123.5 | 2922 | 122.8 |

បន្ថែមលើទិន្នន័យដូចដែលបានបង្ហាញក្នុងតារាងទី២ និងទី៣ ដែលជាចំនួននិស្សិតទាំងថ្នាក់បរិញ្ញាបត្រ និងបរិញ្ញាបត្ររងមានការកើនឡើងជាប្រចាំ រូបទី២ បានបង្ហាញបន្ថែមទៀតថាមួយភាគធំនៃកំណើននិស្សិតនៅតាមបណ្ដាគ្រឹះស្ថានឧត្ដមសិក្សាគឺជាកំណើននិស្សិតថ្នាក់បរិញ្ញាបត្រ។ ក្នុងនោះ គេសង្កេតឃើញថា និស្សិតដែលបានចុះឈ្មោះនៅថ្នាក់បរិញ្ញាបត្រសរុបបានកើនពី ៩២.៣៤០នាក់ ក្នុងឆ្នាំ២០០៦ ទៅ ១៦១.៥១៦នាក់ ក្នុងឆ្នាំ២០០៩។ ចំណែកឯនិស្សិតដែលបានចុះឈ្មោះនៅថ្នាក់បរិញ្ញាបត្ររងបានកើនឡើងពី ១៥.៨៥១នាក់ ក្នុងឆ្នាំ២០០៦ ទៅ ២០.០២០នាក់ ក្នុងឆ្នាំ២០០៩។

## រូបទី៣ ចំនួននិស្សិតដែលបានចុះឈ្មោះចូលរៀនថ្នាក់បរិញ្ញាបត្រ និងបរិញ្ញាបត្ររង




| | 2006-2007 | 2007-2008 | 2008-2009 | 2009-2010 |
|---|---|---|---|---|
| បរិញ្ញាបត្ររង | 15851 | 14857 | 16994 | 20020 |
| បរិញ្ញាបត្រ | 92340 | 110090 | 137253 | 161516 |
| សរុប | 108191 | 124947 | 154247 | 181536 |

តទៅទំព័របន្ទាប់

## ៣. អត្រាលំហូរនៃនិស្សិត

តារាងទី៤ និងទី៥ បង្ហាញពីអត្រាលំហូរនៃសិស្សដែលបានប្រលងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិទៅថ្នាក់បរិញ្ញាបត្រឆ្នាំទី១ ទី២ ទី៣ និងទី៤ និងបរិញ្ញាបត្ររងឆ្នាំទី១ ទី២ និងទី៣។ ជាទិដ្ឋភាពទូទៅឃើញថា អត្រាលំហូរនៃសិស្សដែលបានប្រលងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ មានកម្រិតខ្ពស់គួរឱ្យកត់សំគាល់ ពោលគឺ ខ្ពស់ជាង ៨៣% សម្រាប់លំហូរចូលទៅក្នុងថ្នាក់បរិញ្ញាបត្រ និងខ្ពស់ជាង ១៦%សម្រាប់លំហូរចូលទៅក្នុងថ្នាក់បរិញ្ញាបត្ររង។ ដែលនេះឆ្លុះបញ្ចាំងឱ្យឃើញថាមួយភាគធំនៃសិស្សដែលបានប្រលងជាប់សញ្ញាបត្រមធ្យសិក្សាទុតិយភូមិបានបន្តការសិក្សារបស់គេនៅតាមគ្រឹះស្ថានឧត្តមសិក្សា។ ដោយឡែកអត្រាលំហូរដដែលនេះសម្រាប់សិស្សនារី ហាក់មានកម្រិតទាបជាងបន្តិចបើធៀបទៅនឹងអត្រានៃសិស្សសរុប។

បើពិនិត្យមើលទៅលើអត្រាលំហូរពីឆ្នាំសិក្សានិមួយៗក្នុងកម្រិតបរិញ្ញាបត្រវិញ ឃើញថាសម្រាប់អត្រាលំហូរពីឆ្នាំទី១ទៅឆ្នាំទី២មានកម្រិតខ្ពស់ជាង ៨៦,៧%សម្រាប់និស្សិតសរុប និងខ្ពស់ជាង ៨៧,៨% សម្រាប់សិស្សនារី។ រីឯអត្រាលំហូរពីឆ្នាំទី២ទៅឆ្នាំទី៣ មានកម្រិតខ្ពស់ជាង ៨៥,១% សម្រាប់និស្សិតសរុប និង ខ្ពស់ជាង ៨៧,៤% សម្រាប់និស្សិតនារី។ ហើយអត្រាលំហូរពីឆ្នាំទី៣ទៅឆ្នាំទី៤ មានកម្រិតខ្ពស់ជាង ៩០,៨% សម្រាប់និស្សិតសរុប និងខ្ពស់ជាង ៨៥,៨%។ បើសង្កេតមើលទៅលើបម្រែបម្រួលនៃអត្រាលំហូរពីឆ្នាំទី៣ទៅឆ្នាំទី៤ចាប់ពីឆ្នាំ២០០៤ ដល់ឆ្នាំ២០០៩ ឃើញថាទាំងអត្រាលំហូរសរុប និងអត្រាលំហូរនៃនិស្សិតនារីមានការកើនឡើងជាប្រចាំពី៩៣,១% ក្នុងឆ្នាំ២០០៤ ទៅ១០៣,៨% ក្នុងឆ្នាំ២០០៩ សម្រាប់និស្សិតសរុប និង ពី៨៥,៨% ក្នុងឆ្នាំ២០០៤ ទៅ ១០៣,៨% ក្នុងឆ្នាំ២០០៩ សម្រាប់និស្សិតនារី។

បើពិនិត្យទៅលើអត្រាលំហូរនិស្សិតថ្នាក់បរិញ្ញាបត្ររងវិញ ឃើញថាមានកម្រិតប្រហាក់ប្រហែលគ្នានឹងនិស្សិតថ្នាក់បរិញ្ញាបត្រដែរ ពោលគឺ អត្រាលំហូរនៃនិស្សិតសរុបពីឆ្នាំទី១ ទៅឆ្នាំទី២មានកម្រិតខ្ពស់ជាង ៨៣,២% និងអត្រាលំហូរនៃនិស្សិតនារីមានកម្រិតខ្ពស់ជាង ៨១%។ ហើយអត្រាលំហូរទាំងពីរនេះបានកើនឡើងព្រមគ្នាជាប្រចាំចាប់ពីឆ្នាំ២០០៧ ដល់ឆ្នាំ២០០៩។

### តារាងទី៤ អត្រាលំហូរនៃនិស្សិតថ្នាក់បរិញ្ញាបត្រ

| ឆ្នាំសិក្សា | អត្រាលំហូរនិស្សិតបរិញ្ញាបត្រ | | | | | | | |
|---|---|---|---|---|---|---|---|---|
| | មធ្យមសិក្សាទុតិយភូមិទៅឆ្នាំទី១ | | ឆ្នាំទី១ ទៅទី២ | | ឆ្នាំទី២ ទៅទី៣ | | ឆ្នាំទី៣ ទៅទី៤ | |
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| 2003-2004 | 95.5 | 93.0 | - | - | - | - | - | - |
| 2004-2005 | 102.3 | 87.2 | 111.0 | 105.7 | 101.3 | 103.1 | 93.1 | 85.8 |
| 2005-2006 | 88.7 | 77.4 | 94.7 | 97.1 | 104.1 | 100.4 | 95.9 | 98.8 |
| 2006-2007 | 83.1 | 77.5 | 87.3 | 87.8 | 94.4 | 99.3 | 90.8 | 93.3 |
| 2007-2008 | 98.9 | 89.8 | 92.9 | 90.2 | 85.1 | 87.4 | 95.2 | 92.9 |
| 2008-2009 | 88.5 | 82.2 | 86.7 | 88.4 | 98.0 | 97.8 | 117.4 | 122.5 |
| 2009-2010 | 83.4 | 77.3 | 99.4 | 99.4 | 99.2 | 102.0 | 103.8 | 103.1 |


តទៅទំព័របន្ទាប់

តារាងទី៥ អត្រាលំហូរនៃនិស្សិតថ្នាក់បរិញ្ញាបត្ររង

| ឆ្នាំសិក្សា | អត្រាលំហូរនិស្សិតបរិញ្ញាបត្ររង | | | | | |
|---|---|---|---|---|---|---|
| | មធ្យមសិក្សាទុតិយភូមិទៅឆ្នាំទី១ | | ឆ្នាំទី១ ទៅទី២ | | ឆ្នាំទី២ ទៅទី៣ | |
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| 2003-2004 | - | - | - | - | - | - |
| 2004-2005 | - | - | - | - | - | - |
| 2005-2006 | - | - | - | - | - | - |
| 2006-2007 | 18.5 | 14.3 | - | - | - | - |
| 2007-2008 | 20.7 | 13.9 | 83.2 | 81.0 | 2.5 | 3.5 |
| 2008-2009 | 19.2 | 13.2 | 84.0 | 85.7 | 3.0 | 5.3 |
| 2009-2010 | 16.1 | 11.3 | 97.0 | 103.0 | 12.6 | 22.6 |

## ៥. អត្រាចុះឈ្មោះចូលរៀនសរុបនៃនិស្សិតថ្នាក់បរិញ្ញាបត្រ

តាមរយៈតារាងក៏ដូចជារូបដែលបានបង្ហាញខាងលើឃើញថា ទាំងចំនួនសិស្សដែលប្រលងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ក៏ដូចជានិស្សិតដែលបានចុះឈ្មោះចូលរៀនថ្នាក់បរិញ្ញាបត្រឆ្នាំទី១ មានការកើនឡើងជាលំដាប់ចាប់ពីឆ្នាំ២០០៣ រហូតដល់ឆ្នាំ២០០៩។ ប៉ុន្តែបើពិនិត្យមើលទៅលើចំនួនប្រជាជនដែលស្ថិតនៅក្នុងក្រុមអាយុដែលត្រូវសិក្សាថ្នាក់បរិញ្ញាបត្រវិញ (១៩-២២ឆ្នាំ) ឃើញថាចំនួនប្រជាជនដែលស្ថិតនៅក្នុងក្រុមអាយុនេះមានការកើនឡើងពី ១.១៥៨.៦៥៦នាក់ ក្នុងឆ្នាំ២០០៣ ទៅ ១.២៩៣.៦០០នាក់ ក្នុងឆ្នាំ២០០៥ និងចាប់ផ្តើមថយចុះមកវិញរហូតដល់ ១.២៦៧.១៦៨នាក់ក្នុងឆ្នាំ២០០៩។ ប្រហាក់ប្រហែលគ្នាទៅនឹងចំនួនប្រជាជនសរុបដែរ ចំនួនប៉ាន់ស្មានដែលជានារីមានការកើនឡើងពី ៥៧៦.០៤៨នាក់ក្នុងឆ្នាំ២០០៣ ទៅ ៦៤២.០០០នាក់ ក្នុងឆ្នាំ២០០៥ និងចាប់ផ្តើមថយចុះមកវិញរហូតដល់ ៦២៦.៥១២នាក់ក្នុងឆ្នាំ២០០៩។ ដូចនេះ ទិន្នន័យបង្ហាញថាប្រជាជនដែលជំនាន់ក្រោយដែលស្ថិតក្នុងក្រុមអាយុ១៩-២២ឆ្នាំចាប់ផ្តើមបង្កើនការវិនិយោគលើការអប់រំកម្រិតឧត្តមរបស់ពួកគេ។ ជាមួយគ្នានេះដែរ រូបទី៣ ក៏បង្ហាញផងដែរអំពីអត្រាចុះឈ្មោះចូលរៀននៅថ្នាក់បរិញ្ញាបត្រសរុប (Gross enrollment ratio) ក្នុងនោះលទ្ធផលបង្ហាញថា អត្រាចុះឈ្មោះចូលរៀនថ្នាក់បរិញ្ញាបត្រសរុបបានកើនឡើងជាប្រចាំផងដែរចាប់ពីឆ្នាំ២០០៣ រហូតដល់ឆ្នាំ២០០៩។ បើយើងពិនិត្យមើលទៅលើអត្រាចុះឈ្មោះចូលរៀនសរុបសម្រាប់និស្សិតប្រុស ឃើញថាមានការកើនឡើងពី ៥,៣% ក្នុងឆ្នាំ២០០៣ទៅ ១៥,៣% ក្នុងឆ្នាំ២០០៩ ចំណែកឯអត្រាចុះឈ្មោះចូលរៀនដុលសម្រាប់និស្សិតនារីមានការកើនឡើងពី២,៤% ក្នុងឆ្នាំ២០០៣ ទៅ១០,២% ក្នុងឆ្នាំ២០០៩។ ដូចនេះ ហាក់បង្ហាញថាកម្លាំងពលកម្មដែលមានកម្រិតអប់រំខ្ពស់ចាប់ផ្តើមកើនឡើងជាប្រចាំ និងបន្តកើនឡើងទោះបីជាចំនួនប្រជាជនដែលស្ថិតនៅក្នុងក្រុមអាយុ ១៩-២២ឆ្នាំ ហាក់មានការថយចុះក៏ដោយ។

## តារាងទី៦ ចំនួននិស្សិតចុះឈ្មោះចូលរៀននៅថ្នាក់បរិញ្ញាបត្រ និងចំនួនប៉ាន់ស្មានប្រជាជនដែលមាអាយុពី១៩-២២ឆ្នាំ

| ឆ្នាំសិក្សា | ចំនួននិស្សិតសរុប | ចំនួនប៉ាន់ស្មានប្រជាជន | ចំនួននិស្សិតស្រី | ចំនួនប៉ាន់ស្មានប្រជាជន(ស្រី) | ចំនួននិស្សិតប្រុស | ចំនួនប៉ាន់ស្មានប្រជាជន(ប្រុស) |
|---|---|---|---|---|---|---|
| 2003-2004 | 44,855 | 1158,656 | 14,056 | 576,048 | 30,799 | 582,608 |
| 2004-2005 | 57,117 | 1226,944 | 17,981 | 609,472 | 39,136 | 617,472 |
| 2005-2006 | 75,986 | 1293,600 | 25,195 | 642,000 | 50,791 | 651,600 |
| 2006-2007 | 92,340 | 1286,848 | 32,472 | 639,232 | 59,868 | 647,616 |
| 2007-2008 | 110,090 | 1280,192 | 40,204 | 635,728 | 69,886 | 644,464 |
| 2008-2009 | 137,253 | 1273,632 | 52,807 | 631,488 | 84,446 | 642,144 |
| 2009-2010 | 161,516 | 1267,168 | 63,662 | 626,512 | 97,854 | 640,656 |

## រូបទី៨ អត្រាចុះឈ្មោះចូលរៀនសរុបនៃនិស្សិតថ្នាក់បរិញ្ញាបត្រឆ្នាំទី១




---

អត្ថបទរៀបចំ និងចងក្រងដោយ លោក តាំង ហ៊ាងថារិទ្ធ (ទីប្រឹក្សា NEA) និងលោក ជីម សុជាតិ (អតីតមន្ត្រី NEA)



# ព័ត៌មានជ្រើសរើសបុគ្គលិក

## Vacancy Announcement

លោកអ្នកដែលមានបំណងដាក់ពាក្យសុំការងារ និងចង់ដឹងព័ត៌មានអំពីឱកាសការងារជាច្រើនប្រភេទផ្សេងទៀតអាចទំនាក់ទំនងមកកាន់ «**មជ្ឈមណ្ឌលការងារ**» ណាមួយរបស់ទីភ្នាក់ងារជាតិមុខរបរ និងការងារ ឬអាចស្វែងរក និងទាញយកព័ត៌មានទាំងអស់នេះពីគេហទំព័ររបស់យើង www.nea.gov.kh/jobshop

### ក្រុមហ៊ុនម៉ាស៊ីនភ្លើង

**ថ្ងៃផុតកំណត់:** ២០-មករា-២០១២

**ទីកន្លែងធ្វើការ:** រាជធានីភ្នំពេញ

**មុខតំណែង:**

១- ផ្នែកជាងម៉ាស៊ីនភ្លើង (ចំនួន ៧នាក់)

២- ផ្នែកបើកឡានតូច (ចំនួន ៥នាក់)

៣- ផ្នែកបើកឡានស្ទូច (ចំនួន ៥នាក់)

**លក្ខខណ្ឌជ្រើសរើស:**

- បទពិសោធន៍ការងារ:
  - ត្រូវមានបទពិសោធន៍ការងារ (គ្រប់មុខតំណែង)
- តម្រូវការភាសា:
  - គ្រប់មុខតំណែងបើភាសាផ្សេងៗ កាន់តែប្រសើរ

**ទំនាក់ទំនងតាមរយៈ:**

- លេខទូរស័ព្ទ: ០១១ ៩៥០ ២៩៥/០១១ ៤៣៦ ០៩៨

---

### ក្រុមហ៊ុន ជិនហ្វា លក់សំភ្ពសីជំម្ពូល

**ថ្ងៃផុតកំណត់:** ៣០-មករា-២០១១

**ទីកន្លែងធ្វើការ:** រាជធានីភ្នំពេញ

**មុខតំណែង:** បុគ្គលិកផ្នែកដើរលក់

**លក្ខខណ្ឌជ្រើសរើស:**

- តម្រូវការការសិក្សា:
  - ត្រូវចេះនិយាយភាសា អង់គ្លេស
- បទពិសោធន៍ការងារ:
  - ត្រូវមានបទពិសោធន៍ការងារចាប់ពី១ឆ្នាំឡើងទៅ

**ទំនាក់ទំនងតាមរយៈ:**

- លេខទូរស័ព្ទ: ០៩២ ៦៦៦ ០២៣

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក.»

---

ដើម្បីទទួលបានសេវាទាំងអស់នេះដោយឥតគិតថ្លៃសូមទំនាក់ទំនង ឬផ្ញើលិខិតមកកាន់:

**មជ្ឈមណ្ឌលការងាររាជធានីភ្នំពេញ**
វិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ
០២៣ ៦៣៣ ២០០២
០៧៧ ២៣២ ៣៧៨
០១៦ ៧៨៦ ៦៥៥
jc_pp@nea.gov.kh

**មជ្ឈមណ្ឌលការងារខេត្តបាត់ដំបង**
វិទ្យាស្ថានពហុបច្ចេកទេសខេត្តបាត់ដំបង ផ្លូវលេខ១ ភូមិព្រែកមហាទេព សង្កាត់ស្វាយប៉ោ ក្រុងបាត់ដំបង
០៥៣ ៩៥៣ ៥៨០
០១៦ ៩២៦ ៦៥៥
jc_battambang@nea.gov.kh

**មជ្ឈមណ្ឌលការងារខេត្តសៀមរាប**
មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តសៀមរាប សង្កាត់ស្វាក្រាម ក្រុងសៀមរាប
០៦៣ ៩៦៩ ៣៩៦
០១៦ ៥៣៦ ៦៥៥
jc_siemreap@nea.gov.kh

**មជ្ឈមណ្ឌលការងារខេត្តកំពត**
វិទ្យាស្ថានពហុបច្ចេកទេសខេត្តកំពត ភូមិ០១ ឧសភា សង្កាត់កំពង់កណ្តាល ក្រុងកំពត
០៣៣ ៩៣២ ១២២
០១៦ ៥០៦ ៦៥៥
jc_kampot@nea.gov.kh

**មជ្ឈមណ្ឌលការងារខេត្តស្វាយរៀង**
មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តស្វាយរៀង ភូមិមេភ្លើង សង្កាត់ស្វាយរៀង ក្រុងស្វាយរៀង
០៤៤ ៩៤៥ ២៧៥
០១៦ ៦៤៦ ៦៥៥
jc_svayrieng@nea.gov.kh

ឥឡូវនេះ អតិថិជនរបស់ Hello អាចធ្វើការហៅចូលដោយឥតគិតថ្លៃមកកាន់មជ្ឈមណ្ឌលការងារណាមួយក៏បាន ដើម្បីសាកសួរព័ត៌មានបន្ថែម!

តទៅទំព័របន្ទាប់

សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនងមកកាន់ «មជ្ឈមណ្ឌលការងារ» ណាមួយរបស់ ទ.ជ.ម.ក ឬតាមរយៈគេហទំព័រ www.nea.gov.kh/jobshop

## ហាងសៀវភៅ ឌីស ប៊ុក

**ថ្ងៃផុតកំណត់:** ៣០-មករា-២០១១

**ទីកន្លែងធ្វើការ:** រាជធានីភ្នំពេញ

**មុខតំណែង:** បុគ្គលិកផ្នែកលក់ក្នុងហាង (ចំនួនច្រើននាក់)

**លក្ខខណ្ឌជ្រើសរើស:**

- តម្រូវការបទពិសោធន៍:
  - ត្រូវមានបទពិសោធន៍ការងារ ១ឆ្នាំឡើងទៅ
- តម្រូវការភាសា:
  - ចេះភាសាអង់គ្លេសប្រើការបានកាន់តែប្រសើរ
- តម្រូវការផ្សេងៗ:
  - ត្រូវមានភាពស្មោះត្រង់ តស៊ូ អត់ធ្មត់

**សូមទំនាក់ទំនង:**

- អាសយដ្ឋាន: ផ្ទះលេខ ៧៩ ផ្លូវ ២៤០
- លេខទូរស័ព្ទ: ០១២ ៧២៦ ៣៥៥/០១២ ៩៤៤ ៧៨៤

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

---

## ភោជនីយដ្ឋាន

**ថ្ងៃផុតកំណត់:** ១៥-មករា-២០១២

**ទីកន្លែងធ្វើការ:** រាជធានីភ្នំពេញ

**មុខតំណែង:**

១- បុគ្គលិកផ្នែកចុងភៅ (ចំនួន ៣នាក់)

២- កូនកាំបិត (ចំនួន ៦នាក់)

៣- អ្នករត់តុ (ភេទស្រី ចំនួន ១២នាក់)

៤- អ្នកអនាម័យ (ចំនួន ៣នាក់)

**សូមទំនាក់ទំនង:**

- លេខទូរស័ព្ទ: ០៩៣ ៣៣ ០២ ៣៣

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

---

## ក្រុមហ៊ុន

**ថ្ងៃផុតកំណត់:** ២៥-មករា-២០១១

**ទីកន្លែងធ្វើការ:** រាជធានីភ្នំពេញ

**មុខតំណែង:**

១- ផ្នែកកាន់ស្តុក (ទាំងពីរភេទ)

២- ផ្នែកលក់ (ទាំងពីរភេទ)

៣- ផ្នែកទីផ្សារ (ទាំងពីរភេទ)

**លក្ខខណ្ឌជ្រើសរើស**

- តម្រូវការបទពិសោធន៍ការងារ:
  - ត្រូវមានបទពិសោធន៍ការងារយ៉ាងតិច ១ឆ្នាំឡើងទៅ
- តម្រូវការផ្សេងៗ:
  - មានពេលវេលាគ្រប់គ្រាន់ និងមិនជាប់រវល់ក្នុងការសិក្សា

**សូមទំនាក់ទំនង:**

- លេខទូរស័ព្ទ: ០១២ ៨៣២ ៣៥៨/០២៣ ៨៨១ ៤២៩

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

---

## ក្រុមហ៊ុនខ៊ាន់លី ត្រាវែល

**ថ្ងៃផុតកំណត់:** ៣០-មករា-២០១២

**ទីកន្លែងធ្វើការ:** រាជធានីភ្នំពេញ

**មុខតំណែង:**

១- ផ្នែក Graphics Designer

២- ផ្នែក IT

**លក្ខខណ្ឌជ្រើសរើស:**

- បទពិសោធន៍ការងារ:
  - ត្រូវមានបទពិសោធន៍ការងារ

**ទំនាក់ទំនងតាមរយៈ:**

- អាសយដ្ឋាន: ផ្ទះលេខ ២៣៩Eo ផ្លូវព្រះមុន្នីវង្ស
- លេខទូរស័ព្ទ: ០២៣ ៤២៨ ៧៧៧/០២៣ ២១៨ ៩៩៩

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

---

## ក្លឹបកំសាន្ត Fever Club

**ថ្ងៃផុតកំណត់:** ៣០-មករា-២០១១

**ទីកន្លែងធ្វើការ:** រាជធានីភ្នំពេញ

**មុខតំណែង:**

១- អ្នកទទួលភ្ញៀវ

២- ប្រធានផ្នែកក្រឡុកស្រា

៣- អ្នកក្រឡុកស្រា

៤- ផ្នែកសេវាកម្ម

៥- អ្នកសំអាត

**លក្ខខណ្ឌជ្រើសរើស:**

- តម្រូវការបទពិសោធន៍:
  - ត្រូវមានបទពិសោធន៍ការងារ ២ឆ្នាំឡើងទៅ



តទៅទំព័របន្ទាប់

ព័ត៌មានជ្រើសរើសបុគ្គលិកទាំងអស់នេះមានសុពលភាពនៅក្នុងមករា ឆ្នាំ២០១២

- តម្រូវការភាសា:
  - ភាសាអង់គ្លេសអាចប្រើការបានល្អ
- តម្រូវការផ្សេងៗ:
  - ត្រូវមានភាពស្មោះត្រង់ តស៊ូ អត់ធ្មត់

សូមទំនាក់ទំនង:

- អាសយដ្ឋាន: ផ្សារផេនសុលមាត់ទន្លេជាន់ទី ១
- លេខទូរស័ព្ទ: ០១២ ៧៩៦ ៩០៩/០១៥ ៨៨៧ ០០០

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក.»

## ក្រុមហ៊ុន ណារិន សំណាងទេសចរណ៍

ថ្ងៃផុតកំណត់: ៣០-មករា-២០១១

ទីកន្លែងធ្វើការ: រាជធានីភ្នំពេញ

មុខតំណែង:

១- ផ្នែក Inbound

២- ផ្នែក Messenger

៣-Ticketing

លក្ខខណ្ឌជ្រើសរើស:

- តម្រូវការបទពិសោធន៍ការងារ:
  - ត្រូវមានបទពិសោធន៍ការងារ (គ្រប់មុខតំណែង)

សូមទំនាក់ទំនង:

- លេខទូរស័ព្ទ: ០១២ ២៦៦ ៦៦១/០២៣ ៨៨២ ៥៨៥

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក.»

## ROCK SPA

ថ្ងៃផុតកំណត់: ៣១-មករា-២០១១

ទីកន្លែងធ្វើការ: រាជធានីភ្នំពេញ

មុខតំណែង:

១-ផ្នែកម៉ាស្សា (ភេទស្រី)

២- ផ្នែកទទួលភ្ញៀវពេលយប់ (ភេទស្រី)

លក្ខខណ្ឌជ្រើសរើស:

- បទពិសោធន៍ការងារ:
  - ត្រូវមានបទពិសោធន៍ការងារទាក់ទងនឹងជំនាញ
- តម្រូវការផ្សេងៗ:
  - ត្រូវមានភាពស្មោះត្រង់ចំពោះក្រុមហ៊ុន

សូមទំនាក់ទំនង:

- លេខទូរស័ព្ទ: ០៨៩ ៩៦៨ ៩៩៩

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក.»

## ណាហ្គាវើល

ថ្ងៃផុតកំណត់: ២៥-មករា-២០១២

ទីកន្លែងធ្វើការ: រាជធានីភ្នំពេញ

មុខតំណែង:

១- អ្នកគ្រប់គ្រងផ្នែកដឹកជញ្ជូន

២- អ្នកមើលការខុសត្រូវផ្នែកដឹកជញ្ជូន

សូមទំនាក់ទំនង:

- អាសយដ្ឋាន: ណាហ្គាវើល សួនច្បារសម្តេចតេជោ ហ៊ុន សែន
- លេខទូរស័ព្ទ: ០២៣ ២២៨ ៨២២

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក.»

## មន្ទីរព្យាបាលធ្មេញសេរ៉ាមិច

ថ្ងៃផុតកំណត់: ២៥-មករា-២០១១

ទីកន្លែងធ្វើការ: រាជធានីភ្នំពេញ

មុខតំណែង: ជំនួយការ (ភេទស្រី)

លក្ខខណ្ឌជ្រើសរើស

- តម្រូវការបទពិសោធន៍ការងារ:
  - ត្រូវមានបទពិសោធន៍ការងារយ៉ាងតិច ១ឆ្នាំឡើងទៅ
- តម្រូវការផ្សេងៗ:
  - ត្រូវមានពេលគ្រប់គ្រាន់ និងមិនជាប់រវល់ក្នុងការសិក្សា

សូមទំនាក់ទំនង:

- អាសយដ្ឋាន: ផ្ទះលេខ ២A1 ផ្លូវ ៥១កែង១១៨ (ខាងក្រោយឈៀងខាងលិចមន្ទីរពេទ្យព្រះអង្គឌួង)
- លេខទូរស័ព្ទ: ០២៣ ៩៩៨ ០៨១/០១២ ៩០៥ ៣២៤

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក.»

## គ្លីនិកព្យាបាលធ្មេញ គ្រួច ទន្តៈ

ថ្ងៃផុតកំណត់: ៣១-មករា-២០១១

ទីកន្លែងធ្វើការ: រាជធានីភ្នំពេញ

មុខតំណែង: ផ្នែកទីផ្សារ (ជាច្រើននាក់ ទាំងពីរភេទ)

លក្ខខណ្ឌជ្រើសរើស:

- តម្រូវការភាសា:

តទៅទំព័របន្ទាប់

សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនងមកកាន់ «មជ្ឈមណ្ឌលការងារ» ណាមួយរបស់ ទ.ជ.ម.ក ឬតាមរយៈគេហទំព័រ www.nea.gov.kh/jobshop

- ត្រូវចេះភាសាអង់គ្លេស អាចប្រើការបាន
- **តម្រូវការបទពិសោធន៍ការងារ:**
- ត្រូវមានបទពិសោធន៍ការងារយ៉ាងតិច ១ឆ្នាំឡើងទៅ

**សូមទំនាក់ទំនង:**

- **អាសយដ្ឋាន:** ផ្ទះលេខ ១៧៩ ផ្លូវ ៥ សង្កាត់ទួលទំពូង១ ខណ្ឌចំការមន រាជធានីភ្នំពេញ
- **អ៊ីម៉ែល:** kvndetal@yahoo.com
- **លេខទូរស័ព្ទ:** ០៨៩ ៩៩០ ៨៨៦/០៩៩ ៣២១ ៩៧៦ ០២៣ ២១២ ៧៥៧

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

### ក្រុមហ៊ុន S L

**ថ្ងៃផុតកំណត់:** ៣១-មករា-២០១១

**ទីកន្លែងធ្វើការ:** រាជធានីភ្នំពេញ

**មុខតំណែង:** ជាងអគ្គិសនី និងជាងម៉ាស៊ីន

**លក្ខខណ្ឌជ្រើសរើស:**

- **តម្រូវការការសិក្សា:**
- កំរិតវប្បធម៌ចាប់ពីថ្នាក់ទី ១២ឡើងទៅ និង
- ធ្លាប់រៀនជំនាញដែលពាក់ព័ន្ធ
- **តម្រូវការបទពិសោធន៍ការងារ:**
- មានបទពិសោធន៍ការងារយ៉ាងតិច ១ឆ្នាំឡើងទៅ

**សូមទំនាក់ទំនង:**

- **អាសយដ្ឋាន:** ផ្ទះលេខ ៨១៥ ផ្លូវ ៣៧១ ភូមិឬស្សី សង្កាត់ស្ទឹងមានជ័យ ខណ្ឌចំការមន រាជធានីភ្នំពេញ
- **លេខទូរស័ព្ទ:** ០១២ ៣៩៩ ៨៦៦

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

### ភោជនីយដ្ឋាន CAFÉ SUSHI

**ថ្ងៃផុតកំណត់:** ៣១-មករា-២០១១

**ទីកន្លែងធ្វើការ:** រាជធានីភ្នំពេញ

**មុខតំណែង:**

១- ផ្នែកគណនេយ្យ
២- ផ្នែកចុងភៅ

**សូមទំនាក់ទំនង:**

- **អ៊ីម៉ែល:** saikosacmintel.com
- **លេខទូរស័ព្ទ:** ០១៦ ៤៨៧ ៨៦៦

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

### ក្រុមហ៊ុនឡោសេខខ្ញុន ទ្រេឌីង

**ថ្ងៃផុតកំណត់:** ៣១-មករា-២០១១

**ទីកន្លែងធ្វើការ:** រាជធានីភ្នំពេញ

**មុខតំណែង:**

១- បុគ្គលិកផ្នែកលក់
២- បុគ្គលិកផ្នែកគណនេយ្យ
៣- បុគ្គលិកផ្នែកស្តុក

**លក្ខខណ្ឌជ្រើសរើស:**

- **តម្រូវការបទពិសោធន៍ការងារ:**
- ត្រូវមានបទពិសោធន៍ការងារយ៉ាងតិច២ឆ្នាំឡើងទៅ (មុខតំណែងទី១.២.៣)
- **តម្រូវការភាសា:**
- អាចនិយាយភាសាចិន និងភាសាអង់គ្លេសបានខ្លះៗ (មុខតំណែងទី ១.២.៣)
- **តម្រូវការផ្សេងៗ:**
- មានអាយុចាប់ពី១៨ ដល់២៨ឆ្នាំ

**សូមទំនាក់ទំនង:**

- **អាសយដ្ឋាន:** អគារលេខ ២៣៩ វិថីឧកញ៉ាទេពផន សង្កាត់ទឹកល្អក់២ ខណ្ឌទួលគោក
- **លេខទូរស័ព្ទ:** ០១១ ២៦០ ៥៧៣

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

### ក្រុមហ៊ុន Loretta Garment

**ថ្ងៃផុតកំណត់:** ៣១-មករា-២០១១

**ទីកន្លែងធ្វើការ:** រាជធានីភ្នំពេញ

**មុខតំណែង:**

១- បុគ្គលិកការិយាល័យ
២- អ្នកបកប្រែភាសាចិន
៣- ផ្នែកពិនិត្យគុណភាព (QC)
៤- Merchandiser (ត្រូវចេះភាសាចិន)
៥- សន្តិសុខ
៦- បុគ្គលិកឃ្លាំង



តទៅទំព័របន្ទាប់

ព័ត៌មានជ្រើសរើសបុគ្គលិកទាំងអស់នេះមានសុពលភាពនៅក្នុងមករា ឆ្នាំ២០១២

៧- ជាងជួសជុលម៉ាស៊ីនដេរ

លក្ខខណ្ឌជ្រើសរើស:

- តម្រូវការបទពិសោធន៍ការងារ:
  - មានបទពិសោធន៍ការងារយ៉ាងតិច២ឆ្នាំ(គ្រប់មុខតំណែង)

លេខទូរស័ព្ទ: ០៧៦ ៧៣៥ ២២ ៨៨

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

---

## ក្រុមហ៊ុន

ថ្ងៃផុតកំណត់: ១៤-មករា-២០១១

ទីកន្លែងធ្វើការ: រាជធានីភ្នំពេញ

មុខតំណែង:

១- អ្នកអនាម័យ និងចុងភៅតាមផ្ទះ (ចំនួន៥នាក់)

២- ចុងភៅម្ហូបខ្មែរ បរទេស (ចំនួន៥នាក់)

៣- អ្នកតេគុ និងមេការ (ចំនួន៥នាក់)

៤- ព្រួឡាន និងអ្នកបើកបរឡានសណ្តោង (ចំនួន១០នាក់)

៥- ប្រធានផ្នែកទីផ្សារ

លក្ខខណ្ឌជ្រើសរើស:

- តម្រូវការបទពិសោធន៍ការងារ:
  - ត្រូវមានបទពិសោធន៍ការងារ១ឆ្នាំឡើង (មុខតំណែងទី៥)
- តម្រូវការផ្សេងៗ:
  - ចេះធ្វើផែនការ និង
  - ចេះកុំព្យូទ័រ Photoshop និងExcel (មុខតំណែងទី៥)

លេខទូរស័ព្ទ: ០៩៣ ៤៦២ ៦៥៩/០១៧ ៤៦២ ៦៥៧

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

---

## រោងចក្រកាត់ដេរ

ថ្ងៃផុតកំណត់: ១៤-មករា-២០១១

ទីកន្លែងធ្វើការ: រាជធានីភ្នំពេញ

មុខតំណែង:

១- ប្រធានផ្នែកគំរូ (ភេទស្រី)

២- ប្រធានផ្នែក QA (ភេទស្រី)

២- ប្រធានផ្នែក QC (ទាំងពីរភេទ)

លក្ខខណ្ឌជ្រើសរើស

- តម្រូវការភាសា:
  - ត្រូវចេះភាសាខ្មែរ និងចិន

លេខទូរស័ព្ទ: ០១៦ ៨៣៨ ០៨៨/០១២ ៦១១ ២៥៩

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

---

## សណ្ឋាគារ អង្គរ ហូលីដេ

ថ្ងៃផុតកំណត់: ៣០-មករា-២០១១

ទីកន្លែងធ្វើការ: រាជធានីភ្នំពេញ

មុខតំណែង: អ្នកបើកបរ

លក្ខខណ្ឌជ្រើសរើស:

- កម្រិតភាសា:
  - ត្រូវចេះអាន និងសរសេរភាសាខ្មែរ បើចេះភាសាអង់គ្លេសកាន់តែល្អ
- តម្រូវការបទពិសោធន៍ការងារ:
  - ត្រូវមានបទពិសោធន៍ការងារច្បាស់លាស់

សូមទំនាក់ទំនង:

- អាសយដ្ឋាន: ផ្ទះលេខ ៩៨ មហាវិថីព្រះមន្នីវង្ស(៩៣)
- លេខទូរស័ព្ទ: ០២៣ ២១៨ ៩៦៩/០៩៧ ៧ ៦៤៧ ៤៤៥

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

---

## ទីភ្នាក់ងារទេសចរណ៍ អឹម អេស

ថ្ងៃផុតកំណត់: ៣១-មករា-២០១១

ទីកន្លែងធ្វើការ: ខេត្តសៀមរាប

មុខតំណែង: ប្រធាន ផ្នែកម៉ាស្សា

លក្ខខណ្ឌជ្រើសរើស:

- កម្រិតការសិក្សា:
  - ត្រូវបានបញ្ចប់ថ្នាក់ទី ១២ ឬបរិញ្ញាបត្រឡើងទៅ
- បទពិសោធន៍ការងារ:
  - ត្រូវមានបទពិសោធន៍ការងារទាក់ទងនឹងជំនាញ
- តម្រូវការផ្សេងៗ:
  - ត្រូវមានភាពស្មោះត្រង់ចំពោះអង្គភាព

សូមទំនាក់ទំនង:

- អាសយដ្ឋាន: ផ្ទះលេខ ០៥០៧ ភូមិវត្តដំណាក់ សង្កាត់សាលាកំរើក ស្រុកសៀមរាប ខេត្តសៀមរាប

សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនងមកកាន់ «មជ្ឈមណ្ឌលការងារ» ណាមួយរបស់ ទ.ជ.ម.ក ឬតាមរយៈគេហទំព័រ www.nea.gov.kh/jobshop

- លេខទូរស័ព្ទ: ០៦៣ ៩៦៣ ៧៧៤/០៦៣៩៦៣ ៥១៩

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

### ក្រុមហ៊ុន GELEX Cambodia

**ថ្ងៃផុតកំណត់:** ៣១-មករា-២០១១

**ទីកន្លែងធ្វើការ:** រាជធានីភ្នំពេញ

**មុខតំណែង:** បុគ្គលិកនារីផ្នែកម៉ាស្សា

**សូមទំនាក់ទំនង:**

- លេខទូរស័ព្ទ: ០៧៧ ៦៨៦ ៨២២/០៨១ ៣៣០ ៣៦៨

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

### ក្រុមហ៊ុន សន្តិសុខ រិគីសាគ្វាំជម៉ុន

**ថ្ងៃផុតកំណត់:** ៣១-មករា-២០១១

**ទីកន្លែងធ្វើការ:** រាជធានីភ្នំពេញ

**មុខតំណែង:**

១- អ្នកគ្រប់គ្រងសន្តិសុខ

២- សន្តិសុខទាំងពីរភេទ

៣-បុគ្គលិកការិយាល័យ

**លក្ខខណ្ឌជ្រើសរើស**

- តម្រូវការបទពិសោធន៍ការងារ:
  - ត្រូវមានបទពិសោធន៍ការងារចាប់ពី ២ឆ្នាំឡើងទៅ
- តម្រូវការផ្សេងៗ:

**សូមទំនាក់ទំនង:**

- លេខទូរស័ព្ទ: ០២៣ ៨៨២ ១០៦/០១៧ ៥១៣ ៩០៧

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

### ភោជនីយដ្ឋាន SURA

**ថ្ងៃផុតកំណត់:** ៣១-មករា-២០១១

**ទីកន្លែងធ្វើការ:** រាជធានីភ្នំពេញ

**មុខតំណែង:**

១-អ្នករត់តុ (ភេទស្រី)

២-អ្នកគ្រប់គ្រង (ចំនួន ១នាក់)

**សូមទំនាក់ទំនង:**

- លេខទូរស័ព្ទ: ០៧៧ ៨៤៨ ៧០៧/០៨៣ ៧០៧ ០៧៧

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

### ក្រុមហ៊ុន ស៊ីអិន ទេសចរណ៍

**ថ្ងៃផុតកំណត់:** ៣០-មករា-២០១១

**ទីកន្លែងធ្វើការ:** រាជធានីភ្នំពេញ

**មុខតំណែង:** អ្នកបើកបរ

**លក្ខខណ្ឌជ្រើសរើស:**

- កម្រិតភាសា:
  - ត្រូវមានបណ្ណបើកបរក្បាល ៣
- តម្រូវការបទពិសោធន៍ការងារ:
  - ត្រូវមានបទពិសោធន៍ការងារយ៉ាងតិច ៥ឆ្នាំ

**សូមទំនាក់ទំនង:**

- អាសយដ្ឋាន: ផ្ទះលេខ ៩៨ មហាវិថីព្រះមន្នីវង្ស(៩៣)
- លេខទូរស័ព្ទ: ០២៣ ២១៨ ៩៦៩/០៩៧ ៧ ៦៤៧ ៤៤៥

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

ព័ត៌មានជ្រើសរើសបុគ្គលិកទាំងអស់នេះបានប្រមូល និងផ្សព្វផ្សាយដោយ ទ.ជ.ម.ក ពីបណ្តាញសារព័ត៌មាន និងប្រភពនានាផ្សេងទៀត។ សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនងដោយផ្ទាល់មកយើងខ្ញុំនៅគ្រប់មជ្ឈមណ្ឌលការងារទាំងអស់ និងគ្រប់ពេលម៉ោងធ្វើការ។



# បទពិសោធន៍

# ក្នុងការស្វែងរកការងារធ្វើ

| | |
|---|---|
| ឈ្មោះ | **ជាង វ៉ាឈុត** |
| អាយុ: | **២៣ឆ្នាំ** |
| ស្ថាប័នការងារ: | **ក្រុមហ៊ុន ICE Electronics** |
| តួនាទីក្នុងការងារ: | **ផ្នែកលក់នៅបន្ទប់តាំងផលិតផលនៅហាងកុំព្យូទ័រ អាយស៊ីអ៊ី** |
| អាសយដ្ឋាន: | **ទីក្រុងភ្នំពេញ** |



ស្ថិតក្នុងវ័យសិក្សានៅសកលវិទ្យាល័យ យុវជន **ជាង វ៉ាឈុត** ពោរពេញដោយការតស៊ូក្នុងជីវិត។ ដោយមានស្រុកកំណើតនៅឃុំព្រែកគួច ស្រុកមោងឫស្សី ខេត្តបាត់ដំបង **វ៉ាឈុត** បានបញ្ចប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ហើយបានចាកចេញពីស្រុកកំណើតមកបន្តការសិក្សាកម្រិតមហាវិទ្យាល័យនៅទីក្រុងភ្នំពេញ។

ដោយសារជីវភាពមានការខ្វះខាតពីព្រោះត្រូវបង់ថ្លៃសិក្សា **វ៉ាឈុត** បានសម្រេចចិត្តដាក់ពាក្យស្វែងរកការងារធ្វើតាមរយៈទីភ្នាក់ជាតិមុខរបរ - និងការងារ។ ទីបំផុត **វ៉ាឈុត** ទទួលបាននូវការងារមួយដែលខ្លួនពេញចិត្ត។ "ធ្វើការបណ្តើរ រៀនបណ្តើរ" គឺជាមាគ៌ាមួយដែល **វ៉ាឈុត** គិតថានឹងទទួលបាននូវលទ្ធផលល្អសម្រាប់ពេលអនាគតបន្ទាប់ពីខ្លួនទទួលបានបរិញ្ញាបត្រ។ ដោយសារបញ្ហាជីវភាព និងការចង់ទទួលបានបទពិសោធន៍ការងារផងនោះ **វ៉ាឈុត** បានសម្រេចចិត្តទទួលយកការងារពេញម៉ោងមួយនៅហាងកុំព្យូទ័រ ICE Electronics ។ **វ៉ាឈុត** បានចូលបំរើការងារដំបូងរបស់ខ្លួនបានរយៈពេលជិតមួយឆ្នាំហើយ។ យុវជន **ជាង វ៉ាឈុត** អាចចាត់ទុកថាជាយុវជនគំរូមួយរូបដែលគួរយកតម្រាប់តាម ដោយសារភាពតស៊ូក្នុងជីវិត។ សព្វថ្ងៃនេះ **វ៉ាឈុត** ធ្វើការពេញម៉ោងចាប់ពីម៉ោង ៨ ព្រឹករហូតដល់ម៉ោង ៥:៣០ល្ងាច ហើយបន្ទាប់មកត្រូវធ្វើដំណើរដោយទោចក្រយានយន្តទៅបន្តការសិក្សាឆ្នាំទី៣ ផ្នែកទេសចរណ៍ និងបដិសណ្ឋារកិច្ច នៅឯសកលវិទ្យាល័យមេគង្គកម្ពុជារហូតដល់ម៉ោង ៨:៣០ យប់ទើបអាចត្រលប់ទៅផ្ទះសម្រាក។

នៅពេលដែលសួរថាតើសព្វថ្ងៃមានការនឿយហត់ និងធុញទ្រាន់ដែរឬទេដែលរៀនផង ហើយធ្វើការផង? យុវជនវ៉ាឈុតបានឆ្លើយទាំងទឹកមុខរីករាយថា "ខ្ញុំមិនហត់ឡើយព្រោះជីវិតត្រូវតែតស៊ូ។ ខ្ញុំចង់បានជីវិតឯករាជ្យមួយដោយមិនពឹងពាក់ថវិការបស់ប៉ាម៉ាក់ ហើយណាមួយចង់បានបទពិសោធន៍ការងារខ្លះនៅពេលរៀនចប់" ។

ដោយសារការខិតខំប្រឹងប្រែង យុវជន **វ៉ាឈុត** បានសម្រេចចិត្តដាក់ពាក្យស្វែងរកការងារធ្វើតាមរយៈទីភ្នាក់ងារជាតិមុខរបរ និងការងារកាលពីខែឧសភា ឆ្នាំ ២០១១។ ការដាក់ពាក្យសុំធ្វើការ គឺជាចំណុចចាប់ផ្តើម និងលើកដំបូងសម្រាប់ វ៉ាឈុត ក្នុងការចូលប្រឡូកក្នុងរបត់ជីវិតមួយដែលខ្លួនមិនធ្លាប់បានធ្វើពីមុន។ ក្រោយពីដាក់ពាក្យបានមួយសប្តាហ៍ **វ៉ាឈុត**បានទទួលទូរស័ព្ទពីទីភ្នាក់ងារជាតិមុខរបរ និងការងារ ហៅរូបខ្លួនមកបង្រៀនពីរបៀបក្នុងពេលសម្ភាសន៍ការងារ ការរៀបចំអាកប្បកិរិយា និងការស្លៀកសំលៀកបំពាក់ឱ្យសមរម្យ។

ក្រោយពីទទួលការពន្យល់ណែនាំទាក់ទងទៅនឹងការការសម្ភាសន៍ការងារ **វ៉ាឈុត** បានទៅក្រុមហ៊ុន ICE Electronics ដើម្បីទទួលការសម្ភាសន៍ពី គណៈដឹកនាំរបស់ក្រុមហ៊ុន។ អ្វីដែលគួរឱ្យចាប់អារម្មណ៍នោះគឺសំណួរមួយដែលធ្វើឱ្យ **វ៉ាឈុត** គាំងមួយសន្ទុះ គឺទាក់ទងទៅនឹងប្រវត្តិការរៀនសូត្រ ជាមួយនឹងជំនាញការងារដែល **វ៉ាឈុត** កំពុងដាក់ពាក្យ។ បញ្ហានៅត្រង់ថា វ៉ាឈុតកំពុងសិក្សាផ្នែកទេសចរណ៍ ប៉ុន្តែ

តទៅទំព័របន្ទាប់

ការងារដែលខ្លួនកំពុងដាក់ពាក្យមកនេះ គឺផ្នែកលក់ទៅវិញ។ សំណួរដែលត្រូវបានលើកឡើងនៅក្នុងពេលសម្ភាសន៍នោះគឺ "តើហេតុអ្វីបានជាប្អូនដាក់ពាក្យមកធ្វើជាតំណាងផ្នែកលក់សំភារៈកុំព្យូទ័រ នៅពេលដែលប្អូនកំពុងសិក្សាជំនាញទេសចរណ៍? តើប្អូនមិនគិតថាវាខុសជំនាញទេឬ?"

សំណួរមួយនេះពិតជាធ្វើឱ្យ វ៉ាឈុត ពិបាកនឹងឆ្លើយតប។ ទោះបីជាយ៉ាងណាក៏ដោយ វ៉ាឈុត បានឆ្លើយតបទាំងមានជំនឿទុកចិត្តថាខ្លួននឹងព្យាយាមស្វែងយល់អំពីសំភារៈកុំព្យូទ័រ និងវិធីសាស្រ្តក្នុងការលក់ឱ្យមានប្រសិទ្ធភាព។ **វ៉ាឈុត** បានឆ្លើយថា *"ខ្ញុំនឹងព្យាយាមសិក្សាស្វែងយល់អំពីព័ត៌មានលំអិតទាក់ទងនឹងសំភារៈកុំព្យូទ័រ និងរបៀបរបបក្នុងការនិយាយស្តីឱ្យមានភាពទាក់ទាញទៅកាន់អតិថិជន។ ខ្ញុំសង្ឃឹមថាបងនឹងទុកឱកាសឱ្យខ្ញុំបីខែក្នុងការហ្វឹកហាត់ដោយមិនចាំបាច់ឱ្យប្រាក់ខែ"*។

ពាក្យសំដីចុងក្រោយដែលពោរពេញដោយជំនឿចិត្ត ភាពក្លាហាន និងឆន្ទៈមោះមុតក្នុងការតស៊ូដើម្បីទទួលបានការងារនេះហើយ ទើបធ្វើឱ្យគណៈគ្រប់គ្រងរបស់ក្រុមហ៊ុន ICE Electronics យល់ព្រមទុកឱកាសឱ្យ វ៉ាឈុត ដើម្បីហ្វឹកហាត់ និងសាកល្បងការងាររយៈពេលបីខែ។

ដោយសេចក្តីឧស្សាហ៍ព្យាយាម និងការតស៊ូរបស់យុវជន **វ៉ាឈុត** ទីបំផុតក្តីបំណងរបស់ខ្លួនត្រូវបានសម្រេច ដោយក្រុមហ៊ុនយល់ព្រមទទួល **វ៉ាឈុត** ជាបុគ្គលិកពេញសិទ្ធិជាមួយប្រាក់បៀវត្សរ៍ដ៏សមរម្យមួយ។ ជាមួយនឹងបទពិសោធន៍ផ្នែកលក់សំភារៈកុំព្យូទ័រ **វ៉ាឈុត** ជួបប្រទះនូវបញ្ហាមួយចំនួនទាក់ទងនឹងភាពលំអិត និងស៊ីជំរៅនៅក្នុងវិស័យនេះ ខ្លួនត្រូវចំណាយពេលស្វែងយល់អំពីប្រភេទនៃផលិតផលទាំងនោះឱ្យបានច្បាស់លាស់ ទើបអាចបរិយាយប្រាប់អតិថិជនបាន។

**វ៉ាឈុត** បានប្រាប់ថា "ដើម្បីក្លាយជាអ្នកលក់សំភារៈកុំព្យូទ័រ យ៉ាងចំណានម្នាក់ យើងត្រូវមានជំនាញផ្នែកលក់ និងទីផ្សារ ដែលរួមមានជំនាញក្នុងការនិយាយទាក់ទាញទឹកចិត្តអតិថិជន ភាពរួសរាយរាក់ទាក់ និងការរៀបចំខ្លួនឱ្យបានសមរម្យ។ លើសពីនេះ យើងត្រូវមានជំនាញ និងចំណេះដឹងទាក់ទងនឹងកុំព្យូទ័រ និងបច្ចេកវិទ្យាទំនើប។ បន្ថែមលើនេះទៀត យើងត្រូវមានគំនិតទាន់សម័យ និងប្រែប្រួលទៅតាមបច្ចេកវិទ្យាសម័យថ្មី"។

## ការងារជាអ្នកបង្រៀនយើង

តាមរយៈបទពិសោធន៍ការងាររបស់យុវជន **វ៉ាឈុត** បានបង្ហាញថាមនុស្សម្នាក់ៗ ត្រូវមានចិត្តអំណត់តស៊ូក្នុងការបំពេញកិច្ចការងារទោះបីការងារនោះពិបាកយ៉ាងណាក៏ដោយ។ លើសពីនេះទៀត យុវជនគ្រប់រូបត្រូវមានជំនឿលើខ្លួនឯងថាការងារអ្វីក៏យើងអាចធ្វើសម្រេចបាន ប្រសិនបើយើងមិនបោះបង់ចោល និងព្យាយាមយកចិត្តទុកដាក់រៀនសូត្រអំពីវាពីព្រោះការងារនឹងបង្រៀនបុគ្គលម្នាក់ៗនៅពេលដែលយើងចូលធ្វើការជាក់ស្តែងដូចករណីយុវជន **វ៉ាឈុត**។

សម្រាប់គម្រោងអនាគត **វ៉ាឈុត** មានបំណងចង់មានមុខរបរផ្ទាល់ខ្លួនមួយ។ នៅពេលសួរថាតើមុខរបរអ្វី និងហេតុអ្វីទើបស្រលាញ់មុខរបរនោះ **វ៉ាឈុត** បានឆ្លើយយ៉ាងរហ័សលាយឡំជាមួយស្នាមញញឹមតិចៗថា "ខ្ញុំចង់បើកជាអាហារដ្ឋានមួយ ព្រោះមិនចង់ធ្វើការឱ្យគេ និងចង់បានប្រាក់ចំណូលខ្ពស់"។ ដោយធ្លាប់មានបទពិសោធន៍ជាអ្នកកត់មុខម្ហូបនៅឯភោជនីយដ្ឋានមួយនៅស្រុកកំណើតនោះ វ៉ាឈុតធ្លាប់បានយល់ និងឃើញអំពីរបៀបរបប ក្នុងការគ្រប់គ្រងភោជនីយដ្ឋានហើយទើបចង់ប្រឡូកនៅក្នុងវិស័យនេះ។

ជាចុងក្រោយ **វ៉ាឈុត** មានពាក្យផ្តាំផ្ញើដល់យុវជនទាំងអស់ឱ្យស្វះស្វែងរកការងារធ្វើ កុំទុកពេលវេលាចោលអត់ប្រយោជន៍។ លើសពីនេះទៀត យុវជនទាំងអស់កុំអស់សង្ឃឹមនៅពេលខ្លួនដាក់ធ្វើការហើយមិនទទួលបានលទ្ធផល ឬមិនចំមុខជំនាញដែលខ្លួនត្រូវការ ពីព្រោះ *"ការព្យាយាមគង់បានសំរេច ហើយការងារជាអ្នកបង្រៀនយើង"*។ ពោលគឺត្រូវតាំងចិត្ត និងតស៊ូឧបសគ្គគ្រប់បែបយ៉ាង។ យុវជន **ជាង វ៉ាឈុត** បានលើកទឹកចិត្តដល់យុវជនទាំងអស់ឱ្យមកប្រើប្រាស់នូវ **«សេវាការងារ»** នៃមជ្ឈមណ្ឌលការងាររបស់ទីភ្នាក់ជាតិមុខរបរ និងការងារ ដោយបានលើកសរសើរអំពីសេវាកម្មរបស់ទីភ្នាក់ងារនេះ ថាមានប្រសិទ្ធភាពខ្ពស់ ជាពិសេស មិនគិតកម្រៃ និងមានព័តមានប្រមូលផ្តុំនៅមួយកន្លែងងាយស្រួលទៀតផង៕

## សេចក្តីព្យាយាមគង់បានសម្រេច

*បទសម្ភាសន៍រវាង លោក សុជាតិ កញ្ញារិទ្ធ (ទីប្រឹក្សា NEA) ជាមួយ លោក ជាង វ៉ាឈុត (បុគ្គលិកក្រុមហ៊ុន ICE Electronics)។*



បទសម្ភាសន៍

# ទស្សនៈពីជ្រុងមួយនៃការសិក្សាជំនាញផ្នែកបច្ចេកទេស

ព្រឹត្តិបត្រការងារមានបំណងនាំមិត្តអ្នកអាន ប្អូនៗសិស្ស-និស្សិត អ្នកដែលកំពុងស្វែងរកការសិក្សាជំនាញបច្ចេកទេស ព្រមទាំងសាធារណជនទាំងអស់ទៅស្វែងយល់ពីជ្រុងមួយនៃព័ត៌មានទីផ្សារការងារ ជាពិសេស អំពីទស្សនៈរបស់អ្នកផ្តល់ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។ អត្ថបទនេះ ជាបទសម្ភាសន៍ជាមួយនាយកវិទ្យាស្ថានបច្ចេកទេសកម្ពុជា (National Polytechnic Institute of Cambodia – NPIC) ក្នុងន័យបង្ហាញជូនពីសារសំខាន់ បទពិសោធន៍ និងសកម្មភាពនៃការបណ្តុះបណ្តាលជំនាញបច្ចេកទេសជាច្រើនប្រភេទ។ ដោយហេតុថាការពិនិត្យលើតម្រូវការទីផ្សារការងារបច្ចុប្បន្ន និងការប្រមើលឆ្ពោះទៅអនាគត គេអាចយល់បានថាតម្រូវការកម្លាំងពលកម្មដែលមានជំនាញបច្ចេកទេស (Technical skills) នឹងមានការកើនឡើង ស្របពេលដែលកម្ពុជាកំពុងមានការខ្វះខាតអ្នកជំនាញបច្ចេកទេសយ៉ាងច្រើនសម្រាប់ជាមូលដ្ឋានគ្រឹះ និងជាសរសរស្តម្ភនៃការកសាងវិស័យឧស្សាហកម្ម ក៏ដូចជាការអភិវឌ្ឍប្រទេសឈានទៅកាន់ភាពរីកចំរើនជឿនលឿនស្របតាមការវិវឌ្ឍថ្មីៗនៃចរន្តទំនើបកម្មផ្នែកបច្ចេកវិទ្យា និងវិទ្យាសាស្ត្រ។

ម៉្យាងទៀត បទសន្ទនានេះក៏មានបំណងផ្ញើសារទៅដល់ ប្អូនៗសិស្ស-និស្សិត អ្នកដែលកំពុងស្វែងរកការសិក្សាជំនាញបច្ចេកទេស ឱ្យផ្តោតការយកចិត្តទុកដាក់កាន់តែខ្លាំងថែមទៀតលើការស្វែងយល់ និងប្រមូលព័ត៌មានពាក់ព័ន្ធផ្នែកនេះ ដើម្បីអាចធ្វើសេចក្តីសម្រេចចិត្ត និងជ្រើសរើសយកការសិក្សាជំនាញបច្ចេកទេសណាមួយដែលស័ក្តិសមនឹងចំណូលចិត្ត ព្រមទាំងលទ្ធភាពផ្ទាល់របស់ខ្លួន ដើម្បីអាចទទួលបានការងារសមរម្យ និងមានសក្តានុពលក្នុងការស្វែងរកការងារក្នុងពេលអនាគតដ៏ខ្លីខាងមុខ។



*ទិដ្ឋភាពនៃវិទ្យាស្ថានពហុបច្ចេកទេសកម្ពុជា (National Polytechnic Institute of Cambodia – NPIC) ដែលជាគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសដ៏ធំ និងប្រកបដោយភាពទំនើបមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា។*

តទៅទំព័របន្ទាប់

# អំពីវិទ្យាស្ថានពហុបច្ចេកទេសកម្ពុជា

(National Polytechnic Institute of Cambodia)

វិទ្យាស្ថានពហុបច្ចេកទេសកម្ពុជា (NPIC) ជាគ្រឹះស្ថានសាធារណៈរបស់រដ្ឋ ស្ថិតក្រោមឱវាទរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ ២០០៥។ NPIC មានទីតាំងស្ថិតនៅភូមិស្រែរាជ្ជៈ សង្កាត់សំរោងក្រោម ខណ្ឌដង្កោ រាជធានីភ្នំពេញ និងស្ថិតនៅក្បែរវត្តពូនភ្នំតាមបណ្តោយផ្លូវទំនប់កប់ស្រូវ។

NPIC កំពុងទទួលសិស្ស-និស្សិតឱ្យចូលរៀននៅក្នុងគ្រឹះស្ថានរបស់ខ្លួនដែលមានមហាវិទ្យាល័យចំនួន ៦គឺ៖

១. មហាវិទ្យាល័យវិស្វកម្មសំណង់ស៊ីវិល

២. មហាវិទ្យាល័យអេឡិកត្រូនិក

៣. មហាវិទ្យាល័យអគ្គិសនី

៤. មហាវិទ្យាល័យព័ត៌មានវិទ្យា

៥. មហាវិទ្យាល័យមេកានិច

៦. មហាវិទ្យាល័យទេសចរណ៍ និងបដិសណ្ឋារកិច្ច

មហាវិទ្យាល័យទាំង ៦ ខាងលើនេះកំពុងទទួលអប់រំ និងបណ្តុះបណ្តាលសិស្ស-និស្សិតចំនួន ១,១០០ នាក់ ដែលផ្តោតការសិក្សារបស់ពួកគេលើមុខជំនាញផ្សេងៗគ្នា។ តាមការឱ្យដឹងរបស់ ឯកឧត្តម **ម៉ុន ឆារិន** នាយកវិទ្យាស្ថាន រហូតមកដល់ពេលនេះមានសិស្ស-និស្សិតចំនួន **៧៦៥** នាក់ដែលបានបញ្ចប់ការសិក្សាជាស្ថាពរពីចំណោមហាវិទ្យាល័យនានាដោយទទួលបានសញ្ញាបត្រវិស្វករ និងអ្នកបច្ចេកទេសជាន់ខ្ពស់។ លើសពីនេះ ឯកឧត្តម បានបន្ថែមឱ្យដឹងទៀតថា ក្នុងចំណោមសិស្ស-និស្សិតដែលបានបញ្ចប់ការសិក្សាទាំងអស់នោះ ភាគច្រើននៃចំនួនរបស់ពួកគេដែលស្មើនឹងប្រមាណ ៨៣% បានចូលបម្រើការងារ ឬទទួលបានការងារសមរម្យនៅតាមស្ថាប័នរដ្ឋ គ្រឹះស្ថានឯកជន រោងចក្រសហគ្រាស ឬក៏ប្រកបមុខរបរដោយខ្លួនឯង។ ក្រៅពីនេះក៏មានសិស្ស-និស្សិតមួយចំនួនផ្សេងទៀតបានចេញទៅបន្តការសិក្សានៅបរទេស ជាពិសេសតាមបណ្តាប្រទេសដែលជាដៃគូសហការរបស់វិទ្យាស្ថានរួមមានប្រទេសឥណ្ឌូនេស៊ី កូរ៉េខាងត្បូង វៀតណាម និងឡាវ ។ល។

## ខ្លឹមសារនៃបទសម្ភាសន៍

*សំ. ជម្រាបសួរឯកឧត្តម ខ្ញុំចង់ដឹងថា ក្នុងចំណោមមហាវិទ្យា - ល័យទាំងអស់របស់ NPIC តើសិស្ស-និស្សិតមានការពេញនិយមសិក្សានៅមហាវិទ្យាល័យណា ឬជំនាញណាមួយជាង គេ?*

ចំ. ប្រសិនយោងតាមចំនួនជាក់ស្តែង គេឃើញថាមហាវិទ្យា-ល័យវិស្វកម្មសំណង់ស៊ីវិលហាក់ទទួលបានបរិមាណសិស្សច្រើនជាងមហាវិទ្យាល័យដទៃទៀត បន្ទាប់មកមានផ្នែកអេឡិកត្រូនិក និងអគ្គិ-សនី ជាដើម។

*សំ. តើឯកឧត្តមយល់ថា ចំនួននេះអាច ឆ្លុះបញ្ចាំងពីសារ-សំខាន់របស់មហាវិទ្យាល័យ ឬជំនាញនីមួយៗដែរឬទេ?*

ចំ. ខ្ញុំយល់ថា វាអាចបញ្ជាក់ពីភាពពេញនិយមរបស់មហាវិទ្យា ឬមុខជំនាញសិក្សាខ្លះៗដែរ។ ប៉ុន្តែ ប្រការសំខាន់គេគួរពិនិត្យទៅលើកត្តារួមផ្សំជាច្រើនទៀតក្នុងការកំណត់អំពីការជ្រើសរើសមុខជំនាញសិក្សា ឬមហាវិទ្យាល័យរបស់សិស្សម្នាក់ៗ។ ឧទាហរណ៍ កត្តាសង្គម និងចរន្តនៃការវិវត្តរបស់សេដ្ឋកិច្ច កន្លងមកថ្មីៗនេះ ជាពិសេសមុនពេលមានវិបត្តិសេដ្ឋកិច្ចសកលលោក វិស័យសំណង់ហាក់មានសន្ទុះរីកចំរើនដុះដាលយ៉ាងលឿន អាស្រ័យដោយទីផ្សារអចលនវត្ថុ និងការសាងសង់ផ្សេងៗមានសកម្មភាពយ៉ាងខ្លាំងក្លា។ ដូច្នេះ សិស្ស-និស្សិត ក៏មានការរំពឹងអំពីឱកាស និងតម្រូវការទីផ្សារការងារនាពេលអនាគតទៅតាមនោះដែរមុននឹងសម្រេចចិត្តសិក្សាជំនាញអ្វីមួយ។ កត្តាមួយផ្សេងទៀត ខ្ញុំគិតថាគឺជាការសម្រេចចិត្តរបស់សិស្ស-និស្សិតដោយយោងទៅតាមចំណង់-ចំណូលចិត្តពិតប្រាកដ និងលទ្ធភាពជាក់ស្តែងរបស់ពួកគេ។ ក្រៅពីនេះក៏នៅមានកត្តាឥទ្ធិពលពីមិត្តភ័ក្តិ និងពីគ្រួសារផងដែរ។





តទៅទំព័របន្ទាប់...

*សំ. ប្រសិន ពិនិត្យពីខាងផ្នែកតម្រូវការជំនាញពីទីផ្សារការងារវិញ តើទីផ្សារការងារបច្ចុប្បន្នមានតម្រូវការជំនាញអ្វីខ្លះខ្លាំងជាងគេ?*

ចំ. តាមបទពិសោធន៍ដែលខ្ញុំបានតាមដាន និងពិនិត្យស្ថានភាពទីផ្សារការងារ និងស្ថានភាពនៃការបណ្តុះបណ្តាលនិស្សិតរបស់វិទ្យាស្ថានផ្ទាល់ ខ្ញុំមានការកត់សម្គាល់ឃើញថាទីផ្សារការងារផ្នែកបច្ចេក-ទេសហាក់មានតម្រូវការច្រើនលើផ្នែកឯកទេសអេឡិកត្រូនិក ប៉ុន្តែវិទ្យា-ស្ថានហាក់មិនទាន់បានឆ្លើយតបតាមរយៈការផលិតសិស្ស-និស្សិតឱ្យស្របតាមតម្រូវការនៅឡើយទេ។

*សំ. ដូច្នេះ មើលទៅហាក់ឃើញថាតម្រូវការ និងការផ្គត់ផ្គង់មិនទាន់សូវស៊ីសង្វាក់គ្នា ឬពោលម្យ៉ាងទៀតថាចំនួនសិស្ស-និស្សិតដែលសិក្សាតាមមហាវិទ្យាល័យទាំង ៦ ហាក់មិនសូវមានតុល្យភាពគ្នា តើឯកឧត្តម យល់ថាអ្វីទៅជាប្រការគួរយកចិត្តទុកដាក់ ឬជាការដែលត្រូវបារម្ភ ជាពិសេសបើមើលពីទស្សនៈរបស់អ្នកផ្តល់ការអប់រំបណ្តុះបណ្តាល?*

ចំ. ខ្ញុំគិតថា ចំណុចនេះជាបញ្ហាស្មុគស្មាញ និងគួរមានការយកចិត្តទុកដាក់ពីគ្រប់ភាគីពាក់ព័ន្ធនានានៅក្នុងទីផ្សារការងាររបស់កម្ពុជា។ ទោះជាយ៉ាងនេះក្តី ក្នុងនាមជាភ្នាក់ងារផ្តល់ការអប់រំបណ្តុះបណ្តាល យើងខ្ញុំមានការចាប់អារម្មណ៍ខ្ពស់ និងខិតខំផ្សព្វផ្សាយ ពន្យល់ណែនាំអំពីសារសំខាន់របស់មុខវិជ្ជា និងជំនាញសិក្សាទាំងអស់ដែលទាក់ទងនឹងផ្នែកបច្ចេកទេស ដោយមិនយល់ថាផ្នែកណាសំខាន់ជាងផ្នែកណាមួយនោះទេ។ យើងខ្ញុំស្វាគមន៍ ផ្តល់នូវឱកាស និងផ្តល់នូវគុណភាពអប់រំបណ្តុះបណ្តាលស្មើៗគ្នាទៅដល់សិស្ស-និស្សិតទាំងអស់របស់វិទ្យា-ស្ថាន និងអ្នកដែលមានបំណងចូលមកសិក្សានៅទីនេះ។





*សំ. តើកន្លងមកវិទ្យាស្ថាន បានប្រើវិធីសាស្ត្រ និងមធ្យោបាយអ្វីខ្លះក្នុងការផ្សព្វផ្សាយទៅក្នុងចំណោមសិស្ស-និស្សិត ក៏ដូចជាមហាជនទូទៅ?*

ចំ. វិទ្យាស្ថានមានគេហទំព័រ (http://npic.edu.kh) បណ្តុំផ្នត់ និងបានបញ្ជូនបុគ្គលិកទៅផ្សព្វផ្សាយដល់គ្រឹះស្ថានសិក្សា និងវិទ្យា-ល័យនានា ជាពិសេសមុនពេលដែលសិស្សប្រលងបញ្ចប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ដើម្បីឱ្យពួកគេយល់អំពីសារសំខាន់ មុខជំនាញ និងបែបផែននៃការសិក្សាជំនាញបច្ចេកទេស។

*សំ. ខ្ញុំដឹងថាមានវិទ្យាស្ថាន និងសាលាអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈជាច្រើនដែលស្ថិតក្រោមឱវាទក្រសួងការងារ និងបណ្តុះ-បណ្តាលវិជ្ជាជីវៈ ទាំងនៅក្នុងរាជធានីភ្នំពេញ និងនៅតាមខេត្តក្រុងនានា ក្នុងករណីនេះ តើសិស្សគួរជ្រើសរើសសាលាបែបណា?*

ចំ. ខ្ញុំយល់ថា ការជ្រើសរើសសាលាណាមួយដើម្បីសិក្សាជំនាញបច្ចេកទេសក៏សុទ្ធសឹងមានសារសំខាន់ និងគុណភាពមួយបែបៗរបស់ខ្លួន។ ធម្មតា គេពិបាកនឹងកំណត់ថាសាលាណា ឬជំនាញណាសំខាន់ជាងជំនាញណាមួយផ្សេងទៀតណាស់ ប៉ុន្តែ អ្វីដែលខ្ញុំចង់គូសបញ្ជាក់គឺការដែលសិស្ស-និស្សិតគួរទទួលបានការអប់រំមួយដែលមានលក្ខណៈទំនើប និងមានភាពស៊ីជម្រៅនៅក្នុងមុខជំនាញរបស់ពួកគេ។ ជាពិសេស ខ្ញុំចង់សង្កត់ធ្ងន់ទៅលើការសិក្សាទាំងឡាយណាដែលពាក់ព័ន្ធនឹងជំនាញបច្ចេកទេស។

មិនថាឡើយតែជំនាញខាងសំណង់ មេកានិច និងអេឡិចត្រូនិចនោះទេ ទោះបីជាជំនាញអ្វីក៏ដោយក៏ សុទ្ធសឹងមានតម្លៃ និងឱកាសក្នុងការទទួលបានការងារសម្រាប់កសាងអាជីពដូចៗគ្នា។

តទៅទំព័របន្ទាប់

*សំ. តើ NPIC មានលក្ខណៈសម្បត្តិបែបណាខ្លះក្នុងការប្រកួតប្រជែងលើវិស័យអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស?*

ចំ. ខ្ញុំគិតថា NPIC មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការផ្តល់នូវសេវាអប់រំដែលប្រកបដោយគុណភាព ភាពប្រកួតប្រជែង និងសម្ភារបរិក្ខាដ៏ទំនើបសម្រាប់ការសិក្សា និងអនុវត្តន៍កិច្ចការរបស់សិស្ស-និស្សិតទាំងអស់។ ម្យ៉ាងទៀត ខ្ញុំអាចបញ្ជាក់បានថា NPIC អាចជាវិទ្យាស្ថានដ៏ធំ និងឈានមុខគេមួយនៅក្នុងប្រទេសកម្ពុជាជាពិសេសខាងផ្នែកកម្មវិធីសិក្សា ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសម្ភារពិសោធន៍។

*សំ. ខ្ញុំសូមអនុញ្ញាតជម្រាបសួរខ្លះៗអំពីខាងភាគីផ្តល់ការអប់រំពោលគឺសាស្ត្រាចារ្យ និងបុគ្គលិកបច្ចេកទេសរបស់វិទ្យាស្ថាន តើវិទ្យាស្ថានបានត្រៀមខ្លួន ឬមានយុទ្ធសាស្ត្រយ៉ាងណាក្នុងការផ្តល់នូវចំណេះដឹង និងចំណេះធ្វើប្រកបដោយប្រសិទ្ធភាពដល់សិស្ស-និស្សិត?*

ចំ. ផ្នែកនេះខាងវិទ្យាស្ថានបានកំពុងយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការផ្តល់នូវអ្នកអប់រំប្រកបដោយសមត្ថភាព និងបទពិសោធន៍ខ្ពស់ ក្រៅពីនេះ យើងខ្ញុំបាន បណ្តុះបណ្តាលសមត្ថភាពរបស់សាស្ត្រាចារ្យ និងបុគ្គលិកបច្ចេកទេសជាប់ជាលំដាប់ ដើម្បីសម្របទៅតាមស្ថានភាពវិវត្តន៍នៃបច្ចេកវិទ្យា វិស័យអប់រំ ទីផ្សារការងារ សង្គម និងសេដ្ឋកិច្ច។ សាស្ត្រាចារ្យ និងបុគ្គលិកខ្លះត្រូវបានបញ្ជូនទៅបណ្តុះបណ្តាលនៅបរទេសក៏មាន ព្រមទាំងមានការអញ្ជើញសាស្ត្រាចារ្យបរទេសនៃប្រទេសដៃគូសហការមកបង្រៀននៅវិទ្យាស្ថានជាលក្ខណៈផ្លាស់ប្តូរបទពិសោធន៍ និងស្ម័គ្រចិត្តផងដែរ។

*សំ. តើឯកឧត្តមយល់ថា សិស្ស-និស្សិតក្នុងអំឡុងពេលសិក្សា និងបន្ទាប់ពីបញ្ចប់ការសិក្សាគួរទទួលបានចំណេះដឹងបែបណាដែរ?*

ចំ. អរគុណចំពោះសំណួរដ៏មានសារសំខាន់នេះ ខ្ញុំគិតថាសិស្ស-និស្សិតរបស់វិទ្យាស្ថានគួរមាន ឬត្រូវបានផ្តល់នូវសមត្ថភាពសំខាន់ៗចំនួន ២ គឺ៖ **ជំនាញបច្ចេកទេស (Hard skills) និងជំនាញអាចផ្ទេរ (Soft skills)**។ បានន័យថាការទទួលបានចំណេះដឹងតែមួយមុខមិនគ្រប់គ្រាន់នោះទេ វិទ្យាស្ថានថែមទាំងបានព្យាយាមផ្តល់ឱ្យសិស្ស-និស្សិតយល់អំពីជំនាញពាក់ព័ន្ធនឹងសីលធម៌ មនសិការវិជ្ជាជីវៈ និងឥរិយាបថក្នុងការធ្វើការងារទៀតផង។

*សំ. ហេតុអ្វីជំនាញអាចផ្ទេរ ឬជំនាញទន់ (Soft skills) មានសារសំខាន់គួរបញ្ចូលទៅក្នុងកម្មវិធីនៃការអប់រំ?*

ចំ. គោលដៅចម្បងរបស់វិទ្យាស្ថានយើង គឺបំប៉នសមត្ថភាពសិស្ស-និស្សិតឱ្យអាចសិក្សា និងធ្វើការដោយខ្លួនឯងបាន។ មានន័យថាពួកគេត្រូវមានជំនាញរួមផ្សំជាច្រើនបញ្ចូលគ្នា (Generic skills) ដើម្បីឈានទៅទទួលជោគជ័យ និងរក្សាបាននូវការងារ ជាពិសេសដើម្បីសម្របទៅតាមការវិវត្តនៃបច្ចេកវិទ្យា សង្គម ទីផ្សារការងារ និងការប្រកួតប្រជែង ។ល។

*សំ. តើកន្លងមកមានមុខវិជ្ជាអ្វីខ្លះដែលបានបញ្ចូលនៅក្នុង Generic skills ដើម្បីជាការឆ្លើយតបទៅនឹងតម្រូវការដូចបានពោលខាងលើ ក៏ដូចជាតម្រូវការរបស់សិស្ស-និស្សិត?*



ចំ. កន្លងមក វិទ្យាស្ថានបានផ្តោតលើការបន្ថែមកិច្ចអប់រំសំខាន់ៗមួយចំនួនដូចជា៖ ជំនាញផ្នែកទំនាក់ទំនង ភាសាបរទេស ការស្រាវជ្រាវ ការពិនិត្យសង្កេត ការសម្រេចចិត្ត ព្រមទាំងការគ្រប់គ្រង និងសហគ្រិនភាព ជាដើម។

*សំ. អ្នកខ្លះ ឬមតិខ្លះពោលថា ការសិក្សាជំនាញនៅសាលាបច្ចេកទេស ឬសាលាបណ្តុះបណ្តាលវិជ្ជាជីវៈ ហាក់មើលទៅមិនសូវមានតម្លៃ និងមិនមានកម្រិតសញ្ញាបត្រខ្ពង់ខ្ពស់ប៉ុន្មានសោះ បើប្រៀបធៀបជាមួយការសិក្សានៅមហាវិទ្យាល័យដទៃ តើឯកឧត្តមយល់យ៉ាងណាដែរចំពោះមតិបែបនេះ?*

ចំ. ខ្ញុំក៏ធ្លាប់បានឮពាក្យនេះដែរ ប៉ុន្តែ ខ្ញុំយល់ថានេះគឺជាការយល់មិនសូវត្រឹមត្រូវ និងប្រកាន់នូវគំនិតមិនព្យាយាមស្វែងយល់ឱ្យបានលម្អិតពីស្ថានភាពជាក់ស្តែងជាមុន។ ជាតុពិត ការសិក្សាជំនាញបច្ចេកទេសគឺមិនមានអ្វីជាការអាប់ឱន ឬមិនមានកិត្តិយសនោះទេ ប៉ុន្តែគឺជាប្រភេទជំនាញដែលអាចបម្រើការងារដ៏មានប្រសិទ្ធភាព សម្បូរណ៍



តទៅទំព័របន្ទាប់

បែប និងមានតួនាទីជួយអភិវឌ្ឍន៍ប្រទេសជាតិបានយ៉ាងទូលំទូលាយ។ គេគួរយល់ថា ការសិក្សាប្រភេទណាក៏ដោយ ប្រសិនបើមិនមានថ្នាក់មូលដ្ឋាន ក៏គេមិនអាចឈោងទៅចាប់យកកម្រិតមធ្យម និងឧត្តមបានដែរ។ ដូច្នេះការចាប់ផ្តើមចេញដំណើរពីកម្រិតអប់រំបច្ចេកទេស ក៏គង់អាចផ្សារភ្ជាប់ទៅកម្រិតខ្ពស់ៗជាងនេះបានផងដែរ ប្រសិនគេមានបំណងដូច្នោះ។ ជាក់ស្តែង NPIC បានបណ្តុះបណ្តាលសិស្ស-និស្សិតដែលមានកម្រិតជាអ្នកបច្ចេកទេសជាន់ខ្ពស់ និងវិស្វករផងដែរ។

ជាពិសេស បច្ចុប្បន្ននេះរាជរដ្ឋាភិបាលកម្ពុជា និងក្រសួងពាក់ព័ន្ធកំពុងយកចិត្តទុកដាក់ធ្វើកំណែទម្រង់ប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (TVET) ដោយអនុញ្ញាតឱ្យសិស្ស-និស្សិតអាចបន្តការសិក្សារហូតដល់បានសញ្ញាបត្រខ្ពស់ៗដូចការសិក្សាក្នុងប្រព័ន្ធអប់រំទូទៅដែរ។

**ឯកឧត្តម ប៊ុន ភារិន**

**នាយកវិទ្យាស្ថានពហុបច្ចេកទេស-កម្ពុជា (National Polytechnic Institute of Cambodia – NPIC)**



បទពិសោធន៍ការងារជាសាស្ត្រាចារ្យរយៈពេលប្រហែល ២៥ឆ្នាំ ដែលក្នុងនោះរួមមាន៖

- ✦ អតីតនាយកវិទ្យាស្ថានជាតិបណ្តុះបណ្តាលពហុបច្ចេកទេស (NTTI)
- ✦ គ្រូបង្រៀនផ្នែកបច្ចេកទេសជួសជុល និងថែទាំរថយន្តនៅវិទ្យាស្ថានបច្ចេកទេសកម្ពុជា-សូវៀត (បច្ចុប្បន្នវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា)

## មតិផ្តាំផ្ញើចំពោះសិស្ស-និស្សិត

សូមប្អូនៗសិស្ស-និស្សិតដែលកំពុងតែស្វែងរកការសិក្សាមុខជំនាញធ្វើការពិចារណា និងគួរចាប់យកការអប់រំផ្នែកបច្ចេកទេស និងបណ្តុះបណ្តាលវិជ្ជាជីវៈឱ្យបានច្រើន។ ប្អូនៗទាំងអស់គ្នាគួរសួរខ្លួនឯងថា តើការសិក្សា និងការទទួលបានចំណេះដឹងយកទៅប្រើសម្រាប់ធ្វើអ្វី? ប្រហែលជាប្អូនៗនឹងឆ្លើយថា សិក្សាដើម្បីទទួលបានចំណេះដឹងសម្រាប់អភិវឌ្ឍន៍ខ្លួន សម្រាប់បំពេញការងារ និងសម្រាប់អភិវឌ្ឍន៍ប្រទេស ជាដើម។ ទោះបីជា ចម្លើយសំដៅដល់ចំណុចណាមួយក៏ដោយ គេគួររិះគិត និងប្រមើលអំពីបរិបទនៃទីផ្សារការងាររបស់កម្ពុជានាពេលបច្ចុប្បន្ន និងក្នុងពេលអនាគតដែលហាក់មានសន្ទុះទៅរកតម្រូវការខាងផ្នែកជំនាញបច្ចេកទេសកាន់តែច្រើនឡើងៗ។ ដោយមិនពោលដល់សេចក្តីចាំបាច់ និងការចូលរួមពីវិស័យឬជំនាញដទៃទៀត ការសិក្សាជំនាញបច្ចេកទេសនឹងក្លាយជាកម្លាំងចលករដ៏សំខាន់មួយ និងដ៏មានប្រសិទ្ធភាពក្នុងការចូលរួមចំណែកបំពេញកង្វះខាតតម្រូវការក្នុងទីផ្សារការងារ និងដើម្បីជួយអភិវឌ្ឍន៍ប្រទេសកម្ពុជាលើវិស័យឧស្សាហកម្ម ព្រមទាំងបច្ចេកវិទ្យាទំនើបៗដទៃទៀត។

ការរីកចំរើនរបស់ប្រទេសរួមទាំងផ្នែកបច្ចេកទេស ទាំងក្នុងផ្នែកសង្គម និងការរស់នៅប្រចាំថ្ងៃ ទោះបីពេលបច្ចុប្បន្ន ឬពេលអនាគត ពោលគឺមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយការវិវត្ត និងការចូលរួមចំណែក ឬការបង្កើតថ្មីពីតម្រូវការផ្នែកបច្ចេកទេសស្ទើរតែទាំងអស់។ ហេតុដូច្នេះ ជំនាញបច្ចេកទេសតែងបានបំពេញនូវរាល់តម្រូវការចាំបាច់ពីសង្គមមនុស្ស តាមរយៈការផ្តល់នូវមធ្យោបាយ និងភាពងាយស្រួលដល់គ្រប់វិស័យទាំងអស់ ដោយរាប់ចាប់ពីការបង្កើតឧបករណ៍ប្រើប្រាស់សាមញ្ញៗ រហូតដល់ការផលិតនូវឧបករណ៍ទំនើបៗ និងមានភាពសម្បូរបែបសម្រាប់សម្រួលដល់ការរស់នៅ បំពេញការងារ ការផលិត និងការថែទាំសុខភាព ជាដើម។

អាស្រ័យហេតុនេះ គេគួរចងចាំថាការងារដែលនៅរង់ចាំយើងទាំងអស់គ្នាភាគច្រើនបំផុត គឺជាការងារបែបបច្ចេកទេស។ ឧទាហរណ៍នៅក្នុងសហគ្រាសផលិតកម្មមួយ ទំនងជាគេត្រូវការជ្រើសរើសមុខងារជាអ្នកគ្រប់គ្រងពីរ ឬបីនាក់ ឬមួយចំនួនតូច ប៉ុន្តែគេប្រាកដជាត្រូវការជ្រើសរើសបុគ្គលិក អ្នកជំនាញផ្នែកបច្ចេកទេសច្រើនប្រភេទ និងច្រើនជំនាញសម្រាប់បម្រើការងារ និងធានានូវដំណើរការរបស់សង្វាក់ផលិតកម្ម៕

---

*បទសម្ភាសន៍ **ឯកឧត្តម ប៊ុន ភារិន** (នាយកវិទ្យាស្ថានពហុបច្ចេកទេសកម្ពុជា- NPIC) ស្តីពីការសិក្សាជំនាញបច្ចេកទេស និងទស្សនវិស័យនៃតម្រូវការជំនាញបច្ចេកទេសសម្រាប់ឱកាសការងារ និងទីផ្សារការងារនៅកម្ពុជា។ រៀបចំដោយ ហៃ ហ៊ុនឡេង (មន្ត្រី NEA) និង ទូច សុផាត (អនុប្រធានផ្នែកប្រមូល និងផ្សព្វផ្សាយនៃទីភ្នាក់ងារជាតិមុខរបរ និងការងារ)។*

# សៀវភៅគម្ពស់នៅក្នុង «បណ្ណាល័យការងារ» របស់ទីភ្នាក់ងារជាតិមុខរបរ និងការងារ




សង្ខេបខ្លឹមសារ៖ សៀវភៅនេះផ្តោតសំខាន់លើៈ

- ការស្វែងរកចំណុចទាក់ទងគ្នារវាងបុគ្គលិកលក្ខណៈ ឬអត្តចរិតទៅនឹងការជ្រើសរើសអាជីព និងការងារ។
- បង្ហាញពីគំរូល្អៗដែលប្រើសម្រាប់ជាមធ្យោបាយក្នុងការជ្រើសរើសអាជីព




សង្ខេបខ្លឹមសារ៖ សៀវភៅនេះមានខ្លឹមសាររួមស្តីពីៈ

- ការវាយតម្លៃទៅលើចំណុចខ្លាំង និងចំណុចខ្សោយរបស់បុគ្គលមុននឹងរៀបចំសរសេរ CV។
- ព័ត៌មាន និងគំរូ CV ជាច្រើនប្រភេទ
- ការប្រើប្រាស់ពាក្យគន្លឹះសំខាន់ៗក្នុងការសរសេរ CV




សង្ខេបខ្លឹមសារ៖ សៀវភៅនេះពន្យល់អំពីករណីការងារ និងអាជីពនៅសហរដ្ឋអាមេរិកដោយផ្តោតទៅលើៈ

- ប្រភេទការងារល្អៗដោយតម្រូវទៅតាមកម្រិតអប់រំ និងជំនាញ
- កម្រិតប្រាក់ខែតាមការងារនីមួយៗ
- និន្នាការនៃការកើនឡើង ឬថយចុះក្នុងអាជីព និងការងារប្រភេទខ្លះ




សង្ខេបខ្លឹមសារ៖ សៀវភៅនេះពន្យល់អំពីៈ

- ដំណើរការនៃការត្រៀមខ្លួនសម្ភាសន៍ការងារ
- របៀបនៃការឆ្លើយសំណួរនៅក្នុងពេលសម្ភាសចូលធ្វើការងារ
- ការស្វែងយល់ពីសំណួរជាច្រើនប្រភេទដែលអាចនាំទៅដល់ការទទួលបានការងារ




សង្ខេបខ្លឹមសារ៖ សៀវភៅនេះបង្ហាញពីៈ

- ពាក្យគន្លឹះសំខាន់ៗក្នុងការសរសេរ CV
- ពាក្យគន្លឹះសម្រាប់ឆ្លើយសំណួរនៅពេលធ្វើសម្ភាសន៍ការងារ
- គំនិតសំខាន់ៗសម្រាប់ប្រើជាឧបករណ៍ក្នុងការរៀបចំ និងត្រៀមខ្លួនដាក់ពាក្យសុំការងារតាមបទពិសោធន៍ និងសភាពជាក់ស្តែងរបស់បុគ្គលម្នាក់ៗ




សង្ខេបខ្លឹមសារ៖ សៀវភៅនេះមានពន្យល់យ៉ាងក្បោះក្បាយអំពីៈ

- ប្រភេទនៃការងារសំខាន់ៗដោយបែងចែកតាមក្រុមអាជីព
- ការសិក្សា និងបទពិសោធន៍សម្រាប់ធ្វើការងារនីមួយៗដែលមានក្នុងក្រុមអាជីព




សង្ខេបខ្លឹមសារ៖ សៀវភៅនេះពិពណ៌នាអំពី

- ក្រុមនៃជំនាញនានាជាច្រើនប្រភេទដែលប្រើក្នុងការធ្វើកិច្ចការប្រចាំថ្ងៃ និងក្នុងជីវិត ហើយដែលមនុស្សគ្រប់រូបគួរចេះ និងធ្វើបានដោយខ្លួនឯង
- ឧទាហរណ៍ និងករណីសិក្សានៅក្នុងសៀវភៅនេះឆ្លុះបញ្ចាំងពីជីវិត និងជំនាញនៅក្នុងសង្គមជឿនលឿន ជាពិសេសសហរដ្ឋអាមេរិក។




សង្ខេបខ្លឹមសារ៖ សៀវភៅនេះបកស្រាយពីរបៀបនៃការធ្វើតេស្តវាស់អំពីៈ

- បុគ្គលិកលក្ខណៈ កម្រិតនៃចំណូលចិត្ត កម្រិតជំនាញ និងគុណតម្លៃរបស់បុគ្គលមុននឹងសម្រេចចិត្តជ្រើសយកការងារ ឬអាជីពប្រភេទណាមួយ
- ផ្តល់នូវទស្សនវិស័យទូលំទូលាយពីការស្វែងយល់អំពីខ្លួនឯង មុននឹងកំណត់យកការងារដែលចូលចិត្តប្រចាំជីវិត

# សួស្តីឆ្នាំថ្មី ឆ្នាំ២០១២

## សូមគោរពប្រសិទ្ធពរជ័យ បវរសួស្តី សិរីមង្គល វិបុលសុខ មហាប្រសើរ
## ជូនចំពោះ



**ឯកឧត្តម វង សូត**

រដ្ឋមន្ត្រី ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

**ក្នុងឱកាសដ៏មហានក្ខត្តឫក្សនៃពិធីចូលឆ្នាំថ្មីឆ្នាំសកល ២០១២**

សូមបួងសួងដល់វត្ថុស័ក្តិសិទ្ធក្នុងលោកជួយប្រសិទ្ធពរជ័យ សិរីមង្គល វិបុលសុខគ្រប់ប្រការជូនដល់ ឯកឧត្តម **វង សូត** ដែលជាកុលបុត្រខ្មែរដ៏ឆ្នើមមួយរូប បានចំណាយកម្លាំងកាយចិត្តក្នុងការចូលរួមចំណែកដឹកនាំ ប្រទេសកម្ពុជាឆ្ពោះទៅកាន់ភាពរីកចម្រើនរុងរឿងថ្កុំថ្កើងៗ

សូមឯកឧត្តម និងលោកជំទាវ ព្រមទាំងក្រុមគ្រួសារពើបប្រទះតែពុទ្ធពរទាំងបួនប្រការគឺ
អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយៗ

គោរពជូនពរដោយសេចក្តីស្មោះអស់ពីដួងចិត្តពី
ប្រធានទីភ្នាក់ងារជាតិមុខរបរ និងការងារ ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រោមឱវាទទាំងអស់

# សួស្តីឆ្នាំថ្មី ឆ្នាំ២០១២

**សូមគោរពប្រសិទ្ធពរជ័យ បវរសួស្តី សិរីមង្គល វិបុលសុខ មហាប្រសើរ**
**ជូនចំពោះ**



**ឯកឧត្តមបណ្ឌិត ពេជ សោភ័ន**

រដ្ឋលេខាធិការ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

និងជាអនុប្រធានគណៈកម្មាធិការជាតិបណ្តុះបណ្តាល

**ក្នុងឱកាសដ៏មហានក្ខត្តឫក្សនៃពិធីចូលឆ្នាំថ្មីឆ្នាំសកល ២០១២**

សូមបួងសួងដល់វត្ថុស័ក្តិសិទ្ធក្នុងលោកជួយប្រសិទ្ធពរជ័យ សិរីមង្គល វិបុលសុខគ្រប់ប្រការជូនដល់
ឯកឧត្តមបណ្ឌិត **ពេជ សោភ័ន** ដែលជាកុលបុត្រខ្មែរដ៏ឈ្លាសវៃមួយរូប បានចំណាយកម្លាំងកាយចិត្តក្នុងការចូលរួមចំណែក
ដឹកនាំប្រទេសកម្ពុជាឆ្ពោះទៅកាន់ភាពរីកចម្រើនរុងរឿងថ្កុំថ្កើងៗ
សូមឯកឧត្តមបណ្ឌិត និងលោកជំទាវ ព្រមទាំងក្រុមគ្រួសារពើបប្រទះតែពុទ្ធពរទាំងបួនប្រការគឺ
អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយៗ

គោរពជូនពរដោយសេចក្តីស្មោះអស់ពីដួងចិត្តពី
ប្រធានទីចាត់ការជាតិមុខរបរ និងការងារ ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រោមឱវាទទាំងអស់

# ដៃគូសហការសំខាន់ៗ

## គ្រឹះស្ថានអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

| | | | | | | |
|---|---|---|---|---|---|---|
| វិទ្យាស្ថានជាតិ ពហុបច្ចេកទេសកម្ពុជា | វិទ្យាស្ថានជាតិ បណ្តុះបណ្តាលបច្ចេកទេស | វិទ្យាស្ថានជាតិ ពាណិជ្ជសាស្ត្រ | វិទ្យាស្ថានពហុបច្ចេកទេស ព្រះកុសុមៈ | មជ្ឈមណ្ឌលអភិវឌ្ឍន៍ សហគ្រិនកម្ពុជា-ឥណ្ឌា | វិទ្យាស្ថានបច្ចេកទេស | វិទ្យាស្ថានពហុបច្ចេកទេស ខេត្តបាត់ដំបង |
| សាកលវិទ្យាល័យបាត់ដំបង | សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច | វិទ្យាស្ថានពហុបច្ចេកទេស ខេត្តកំពត | សាកលវិទ្យាល័យបៀលប្រាយ | សាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច | សាកលវិទ្យាល័យមេគង្គកម្ពុជា | សាកលវិទ្យាល័យអាស៊ីអឺរ៉ុប |
| សាកលវិទ្យាល័យជាតិ គ្រប់គ្រង | សាកលវិទ្យាល័យភ្នំពេញ អន្តរជាតិ | វិទ្យាស្ថានអភិវឌ្ឍន៍អាស៊ីសច្ចៈ | សាកលវិទ្យាល័យធនធានមនុស្ស | វិទ្យាស្ថានសហប្រតិបត្តិការ | សាកលវិទ្យាល័យឯកទេស | សាកលវិទ្យាល័យកម្ពុជា |

## អង្គការ ក្រុមហ៊ុន សហគ្រាស និងស្ថាប័នផ្សេងៗ

# ទីភ្នាក់ងារជាតិមុខរបរ និងការងារ
# នៃគណៈកម្មាធិការជាតិបណ្តុះបណ្តាល

## ជាស្ពានឆ្ពោះទៅកាន់

ការងារ កម្លាំងពលកម្ម ព័ត៌មានទីផ្សារការងារ

## Gateway to

Jobs Work Forces Labour Market Information

# ទូទាំងប្រទេសនៅមួយកន្លែងងាយស្រួល

# NATIONWIDE IN A SINGLE SOURCE

សម្រាប់ព័ត៌មានបន្ថែមអំពីសេវាផ្តល់ជូនសូមមើលគេហទំព័រ:

**www.nea.gov.kh**

ចំណាំ: អតិថិជនរបស់ Hello អាចធ្វើការហៅចូលដោយឥតគិតថ្លៃមកកាន់មជ្ឈមណ្ឌលការងារណាមួយក៏បាន ដើម្បីសាកសួរព័ត៌មានបន្ថែម!

ដើម្បីទទួលបានសេវាទាំងអស់នេះ
ដោយឥតគិតថ្លៃសូមទំនាក់ទំនង:

**មជ្ឈមណ្ឌលការងាររាជធានីភ្នំពេញ**
០២៣ ៦៣៣ ៦០០២
០៧៧ ២៣២ ៣៧៨
០១៦ ៧៨៦ ៦៥៥
jc_pp@nea.gov.kh

**មជ្ឈមណ្ឌលការងារខេត្តបាត់ដំបង**
០៥៣ ៩៥៣ ៥៨០
០១៦ ៩២៦ ៦៥៥
jc_battambang@nea.gov.kh

**មជ្ឈមណ្ឌលការងារខេត្តសៀមរាប**
០៦៣ ៩៦៩ ៣៩៦
០១៦ ៥៣៦ ៦៥៥
jc_siemreap@nea.gov.kh

**មជ្ឈមណ្ឌលការងារខេត្តកំពត**
០៣៣ ៩៣២ ១២២
០១៦ ៥០៦ ៦៥៥
jc_kampot@nea.gov.kh

**មជ្ឈមណ្ឌលការងារខេត្តស្វាយរៀង**
០៤៤ ៩៤៥ ២៧៥
០១៦ ៦៤៦ ៦៥៥
jc_svayrieng@nea.gov.kh

**អាសយដ្ឋានរបស់ទីភ្នាក់ងារជាតិមុខរបរ និងការងារ**

មានទីតាំងស្ថិតនៅក្នុងបរិវេណវិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស(NTTI) មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ
ទូរស័ព្ទ: ០២៣ ៦៣៥ ៧១៧៧ ឬ ០៨៨ ៦៧៨ ៥៦៧៨ ទូរសារ: ០២៣ ៨៨២ ៧៣៤ អ៊ីម៉ែល: info@nea.gov.kh